សារព័ត៌មាន ខ្មែរផុស ស.រ.អា

# KhmerPost USA

E-mail: info@khmerpost.us / Website : khmerpost.us
Advertising: 978-656-8141/ Hotline news: 1 (267) 253-3947

Free

មាតិការរឿង Vol 07 Issue 140-28th Oct- 07th Nov. 2013

១-ខួបលើកទី១៤ នៃអង្គការមិត្តភាពគ្មានព្រំដែន......០៤
២-វីឌីត ហូវ ទទួលផ្ទាន់កោតសរសើរ.................០៦
៣-បោះឆ្នោតនៅឡូវែល ថ្ងៃអង្គារ៍ទី ៥.................០៧
៤-វិស្វាក់ការនៅឯស៊ូន,ទស្សនាប្រទេសបារាំង........០៨
៦-ច្បារញ្ញូនថ្ងៃ ២៣ តុលា ១៩៩១ប្លែក.............០៩
៧-វ័រដែលរដ្ឋម៉ាសាឈ្មួសេតច្បារញ្ញ"គ្រីង...........១៦
៨-ជល់វែកការហៀសជាតិថាវិស.......................១៧
៩-ដេកមិនលក់ប៉ះពាល់សុខភាព.......................១៩

New Office: Tel: (978) 677-7163 Fax: (978) 677-7092
45 Merrimack St. Suite 218A Lowell, MA 01852

## វិចារណកថា

## ថ្ងៃ៥វិច្ឆិកា២០១៣

## ឡូវែល : ចុះបើគ្មានខ្មែរដឹកនាំសាលាក្រុង



**ដោយ: ពិន សំខុន**

បេក្ខជន១៨នាក់បានឈរឈ្មោះឱ្យគេបោះឆ្នោតជ្រើសរើសគណក្រុមប្រឹក្សាក្រុងឡូវែលដែលជាស្ថាប័នកំពូលសម្រាប់ដឹកនាំស្ថាបនាឡូវែលទាំងមូល។ មកទល់ថ្ងៃនេះ សមាជិកខ្មែរម្នាក់ដែលនៅក្នុងក្រុមប្រឹក្សាចាស់ គឺលោក វ៉ាសនា នួន ហើយគាត់បានឈរឈ្មោះឱ្យគេបោះឆ្នោតចូលបំរើក្នុងក្រុមប្រឹក្សាថ្មីម្តងទៀត ។ ស្របគ្នានេះ មានបេក្ខជនខ្មែរម្នាក់ទៀត ឈ្មោះ វ៉ែន ពេជ្រ ដែលបានមកឈរឈ្មោះជាលើកដំបូងបង្អស់ឱ្យគេបោះឆ្នោតចូលបំរើក្រុមប្រឹក្សាសាលាក្រុងដែរ។ ដូច្នេះគួរដែរ! ក្នុងតំបន់ដែលមានខ្មែរច្រើនរហូតដល់១ភាគ៣នៃប្រជាជនទាំងមូលខ្មែរឈរឈ្មោះពីរអ្នកមិនខ្មាស់គេថា (ខ្មែរគ្មានមនុស្សជាមត្តុទេសសោះនោះទេ!) ក្នុងនាមជាអ្នកកាសែតខ្មែរ **តទៅទំព័រទី ២៩**

# ជុំវណ្ណ សូដាជីវី (Belle) តួរាំសំខាន់ក្នុង អម្រឹតាសិល្បៈព្រះរាជាណាចក្រកម្ពុជា





កញ្ញា ជុំវណ្ណ សូដាជីវី ក្នុងការសម្តែងជំនោរអង្គរ ឬ Winds of Angkor

**ដោយ : សុខា**

**ទីក្រុងញូយ៉ក :** កញ្ញា ជុំវណ្ណ សូដាជីវី សិល្បៈការិនីមានរាងកាយទន់ភ្លន់ពូកែពត់ពែនទាំងខ្លួន និងម្រាមដៃទាំងសងខាងតែងបញ្ចេញសមត្ថភាពសិល្បៈរបាំបុរាណ សម័យ និងច្នៃទាំងពីរមុខ រវាងបុរាណ និងសម័យសម្តែងដល់ទស្សនិកជនជាតិ និងអន្តរជាតិទាំងក្នុងព្រះរាជាណាចក្រកម្ពុជា និងបរទេស។ ទន្ទឹមនឹងសកម្មភាពសម្តែងក្នុងប្រទេសសិល្បៈការិនីផ្អែករបាំរូបនេះ តែងលេចមុខមានវត្តមានជារឿយៗនៅទ្វីបអឺរ៉ុប និងអាមេរិកជូនសម្តែងជាទោលជូនពេលខ្លះទៀតសម្តែងរួមគ្នាជាក្រុមរួមនឹងអ្នកសម្តែងសញ្ជាតិខ្មែរ **តទៅទំព័រទី ០៣**

# មហាបាតុកម្មអហិង្សានៅទីលានប្រជាធិបតេយ្យក្រុងភ្នំពេញ



យោងតាមសមាជមហាជនថ្ងៃទី៦ តុលា ដែលទាមទារឱ្យគណបក្សសង្គ្រោះជាតិបន្តស្វែងរកយុត្តិធម៌ជូនម្ចាស់ឆ្នោតតាមរយៈធ្វើមហាបាតុកម្មអហិង្សាទ្រង់ទ្រាយធំ និងដើម្បីរំលឹកខួបឆ្នាំទី២២ នៃកិច្ចព្រមព្រៀងសន្តិភាពក្រុងប៉ារីសមហាបាតុកម្មអហិង្សានៅទីលានប្រជាធិបតេយ្យក្រុងភ្នំពេញកំពុងប្រព្រឹត្តទៅមានរយៈពេល៣ថ្ងៃ គឺថ្ងៃទី២៣-២៤-២៥ខែតុលា២០១៣។ តាមកម្មវិធីបាតុកម្ម៣ថ្ងៃមានការដង្ហែក្បួននាំញត្តិស្នាមមេដៃជាង២លាន៣ម៉ឺនទៅជូនតំណាងឧត្តមស្នងការអ.ស.ប ទទួលបន្ទុកសិទ្ធិមនុស្សនៅប្រទេសកម្ពុជា និងទៅកាន់ស្ថានទូតនៃប្រទេសហត្ថលេខីធំ៧ដូចជាស្ថានទូតប្រទេស: បារាំង - ចក្រភពអង់គ្លេស - ស.រ.អា- រុស្ស៊ី - ជប៉ុន -ឥណ្ឌូណេស៊ី - ចិន។

អ្នករៀបចំរងចាំបាតុករមកពីរាជធានីភ្នំពេញ និងខេត្តនានាមកចូលរួមប្រមាណ៤ម៉ឺននាក់មកចូលរួម។

បដារនៅលើវេទិកាកិច្ចព្រមព្រៀងសន្តិភាពក្រុងប៉ារីសថ្ងៃទី២៣ ខែតុលា ១៩៩១ ជាប្រភពនៃសន្តិភាព និងលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស

មហាបាតុកម្មអហិង្សានៅទីលានប្រជាធិបតេយ្យក្រុងភ្នំពេញ ថ្ងៃទី២៥តុលា២០១៣) នៅខណៈនេះខ្ញុំ សម រង្ស៊ី និងលោក កឹម សុខា កំពុងដឹកនាំក្បួនដង្ហែញត្តិ (ញត្តិស្នើសុំឱ្យប្រទេសជាហត្ថលេខីកិច្ចព្រមព្រៀងទីក្រុងប៉ារីសជួយដោះស្រាយវិបត្តិនយោបាយនៅកម្ពុជា និងឱ្យមានការគោរពពេញលេញនូវកិច្ចព្រមព្រៀងទីក្រុងប៉ារីសថ្ងៃទី២៣ តុលា ១៩៩១) ទៅកាន់ស្ថានទូត អូស្ត្រាលី ស្ថានទូតរុស្ស៊ី ស្ថានទូតជប៉ុន ស្ថាន ទូតឥណ្ឌូនេស៊ី និងស្ថានទូតចិន។

អម្បាញមិញនេះដែរ ខ្ញុំ សម រង្ស៊ី និងលោក កឹម សុខា បានចូលរួមមហាបាតុកម្មអហិង្សាថ្ងៃទី៣ នៅទីលានប្រជាធិបតេយ្យរាជធានីភ្នំពេញ។

អម្បាញមិញនេះដែរ ខ្ញុំ និងលោក កឹម សុខា បានចូលរួមមហាបាតុកម្មអហិង្សាថ្ងៃទី៣ នៅទីលានប្រជាធិបតេយ្យ រាជធានីភ្នំពេញ។

https://www.facebook.com/photo.ph

២៥ តុលា ២០១៣

អម្បាញមិញនេះ វីរបាតុករបានប្រមូលថវិកាជួយឧបត្ថម្ភអ្នកស្រី សៅ ពៅ ដែលបានធ្វើដំណើរថ្មើរជើង (ដើរដោយជើង) ពីខេត្តកំពង់ចាម មកចូលរួមមហាបាតុកម្មអហិង្សានៅទីលានប្រជាធិបតេយ្យ រាជធានីភ្នំពេញ។

https://www.facebook.com/photo

**មហាបាតុកម្មអហិង្សានៅទីលានប្រជាធិបតេយ្យក្រុងភ្នំពេញ ថ្ងៃទី២៤តុលា២០១៣**

បាតុករបក្សសង្គ្រោះជាតិហែញត្តិទៅដាក់នៅស្ថានទូត៣ មហាបាតុកម្មរបស់គណបក្សសង្គ្រោះជាតិនៅព្រឹកថ្ងៃទី២៤ ខែតុលា ដែលជាថ្ងៃបាតុកម្មទី២ លោក កឹម សុខា អនុប្រធានគណបក្ស **តទៅទំព័រទី ១៨**


ប្រើធនាគារឲ្យប្រសើរ
គឺនៅក្នុងកាបូប
FREE
$150 gift card to Coach®
កាតរង្វាន់$150ទិញកាបូបល្បីឈ្មោះ"ខូច"
ជាមួយការបើកសេវាសម្រាប់ប្រើធនាគាររាល់ថ្ងៃ
Washington SAVINGS BANK
washingtonsavings.com
* Restrictions apply
Ask for details.
Customer will receive a free gift within 30 days after redeeming a "FREE GIFT Certificate" and implementing the following combination of new services after 12/10/2012: A monthly direct deposit of at least $1,000 from an unaffiliated third party, at least one monthly automatic withdrawal that is not web or card based and an active debit card with 12 or more completed purchases is eligible for a $150 Coach® gift certificate. Promotion ends 06/30/2013. Coach® is a trademark of Coach, Inc. The program is not endorsed by Coach, Inc. nor is there any actual or implied joint venture, partnership or relationship of any kind between Washington Savings Bank and Coach, Inc. Promotions cannot be combined, one gift per customer, per account, per household. Available to personal accounts only. Fee of $150 applies for account closure or change of services within 6 months of free gift receipt. Washington Savings Bank reserves the right to disqualify any account/ person from this promotion if, in its sole discretion, it determines the account and/or services are solely designed to qualify for the free gift. Limited time offer, while supplies last.

តមកពីទំព័រទី ១

## ជុំវណ្ណ សូដាជីវី (Belle) តួរាំ...

និងបរទេសក្រោមការដឹកនាំរបស់ផលិតករខ្មែរ និងបរទេសទៀតផង។

រំឭកនឹកដល់ស្នាដៃសម្ដែងរបស់នាងកាលពីឆ្នាំ២០១១ ខណៈដែលនាងសម្ដែងនៅមហោស្រពចតុមុខរាជធានីភ្នំពេញក្នុងល្ខោនមួយចំណងជើងថា ជំនោរអង្គរ ឬ វីនស៍ អុហ្វ អង្គរ (Winds of Angkor) មានខ្លឹមសារប្រៀបធៀបសេចក្ដីស្នេហាពីររវាងសេចក្ដីស្នេហាក្នុងសម័យប៉ុលពត និងស្នេហាបន្ទាប់ពី សម័យប៉ុលពតដែលដឹកនាំផលិតដោយ អ្នកស្រី សារ៉ា អូប្រាយ អិន (Sarah O'Brien)។ ក្នុងនោះសូដាជីវី សម្ដែងជាតួរាំស្លិតក្នុងឈុត សសៀតផ្កាចំប៉ា នៅនឹងត្រចៀក ពត់ពែនខ្លួន និងម្រាមដៃយ៉ាងទន់ធ្វើឱ្យទស្សនិកជននឹកស្មានមិនដល់ពីទេពកោសល្យមួយនេះ។



ពិនិត្យទៅលើការសម្ដែងសម្រាប់អម្រឹតាសិល្បៈដែលមានអ្នកគ្រប់គ្រងសញ្ជាតិខ្មែរលោកកង រិទ្ធិសាល កញ្ញា ជុំវណ្ណ សូដាជីវី ជាម្នាក់ក្នុងចំណោមសិល្បៈករទាំង៦នាក់រួមមានជ័យច័ន្ទកិត្យា ផុន សុភាព ខុន ច័ន្ទសិទ្ធិការ្យ ជី រតនា និង នួនសុវិទ្ធ ដែលត្រូវបានទទួលឱកាសសម្ដែងនៅទីក្រុងញូវយ៉កសហរដ្ឋអាមេរិកក្នុងព្រឹត្តិការណ៍រដូវកាលនៃកម្ពុជាអំឡុងខែមេសា និងឧសភា ឆ្នាំ២០១៣។






កញ្ញា ជុំវណ្ណសូដាជីវី និងម្ដាយ

ប្រវត្តិសម្ដែងពីមុនមកក្នុងវិស័យរបាំបុរាណដែលមានវ័យចូរលង់ណាស់មកហើយនោះ កញ្ញាជុំវណ្ណសូដាជីវី ធ្លាប់ដើរជាតួក្នុងទម្រង់បូរាណមានជាអាទិ៍តួនាយរង ស្វា តួនាង តួយាយ និងតួគ្រូចាស់។

សូដាជីវី កើតនៅទីក្រុងភ្នំពេញ។ ឪពុកនាម ជុំវណ្ណ សន និង ម្ដាយនាម នូ សណ្ដាប់ក៏ជាសិល្បៈករមួយរូបផ្នែកល្ខោននិយាយ និងជាមន្ត្រីចូលនិវត្តន៍នៅនាយកដ្ឋានសិល្បៈទស្សនីយភាព។ នាងមានបងប្អូន១១នាក់ ដែលអ្នកទាំងអស់នោះបានស្លាប់នៅសម័យ ប៉ុល ពតអស់ហើយ នៅសល់តែនាង ម្នាក់ជាកូនទោលក្នុងគ្រួសារ។ នៅអាយុ៨ឆ្នាំម្ដាយរបស់នាងបានឱ្យនាងហាត់រៀនរាំរបាំបុរាណ។ កាលដើមឡើយនាងមិនសូវចូលចិត្តរបាំបុរាណនេះទេ ត្បិតពិបាកត្រូវអត់ធ្មត់ទាំង ក្នុងការរាំ សុជីវធម៌ឱ្យសមសួនជាកុលធីតាខ្មែរ ។ បន្តពីប្រវត្តិសិក្សាសូដាជីវីបញ្ចប់មធ្យមសិក្សាទុតិយភូមិឆ្នាំ២០០៣ និងបញ្ចប់បរិញ្ញាប័ត្រផ្នែកដឹកនាំរឿងឆ្នាំ ២០០៧។ បច្ចុប្បន្ននាងជាអ្នកសម្ដែងផង ជាអ្នកតម្លើងស្នាដៃផង និងជាគ្រូបង្រៀនផ្នែកដឹកនាំរឿងផង នៅមហាវិទ្យាល័យសិល្បៈនាដសាស្ត្រឆ្នាំទី២ ។ នារីប្រកប





ដោយទេពកោសល្យ និងឧបនិស្ស័យខាងសិល្បៈរូបនេះ កើតនៅថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ១៩៨៥ ហើយនាងធ្លាប់បានអញ្ជើញទៅប្រទេសនានាក្នុងតំបន់អាស៊ានអាមេរិក ព្រមទាំងទ្វីបអឺរ៉ុបមាន អាល្លឺម៉ង់ ស៊ុយអែត នីដឺលែនដ៍ ស្វ៊ីស ប៊្រុសសែល បារាំង ម៉ូរ៉ូកូ និង ប៉ូឡូញ។ នាងចាប់ផ្ដើមប្រឡូកវិស័យនេះនៅអាយុ១២ឆ្នាំ ហើយនាងមានជំនាញ





សម្ដែងក្នុងផ្នែករបាំបុរាណ គឺតួអង្គនាយរង និងនាង (តួប្រុស និងស្រី) ផ្នែករបាំប្រពៃណីគឺរបាំត្រឡោកនេសាទ គែន គោះអង្រែ កន្សែងស្នេហ៍ ហើយអាចសម្ដែងក្នុងល្ខោនស្បែកធំបានទៀតផង។

កញ្ញាជុំវណ្ណ សូដាជីវី មានសុទិដ្ឋិនិយមអំពីការរីកចម្រើននៃសិល្បៈរបាំខ្មែរដោយនាងបានសម្លឹងឃើញពីសមត្ថភាពទេពកោសល្យ និងគំនិតច្នៃប្រឌិតនៃកូនខ្មែរជំនាន់ក្រោយស្ដែងតាមរយៈការធ្វើការការសម្ដែងរួមគ្នា និងតថភាពសង្គមបច្ចុប្បន្នដែលមនុស្សជំនាន់នេះកំពុងវិវត្ត៕

# ខួបលើកទី១៤ នៃអង្គការមិត្តភាពគ្មានព្រំដែន ឬ Friends Without A Border ប្រមូលថវិកាឧបត្ថម្ភដល់មន្ទីរពេទ្យកុមារអង្គរ





Kenro Izu



(Angkor Hospital For Children)

**ខេត្តសៀមរាប**

**ដោយៈ សុខា**

**រដ្ឋញូជឺស៊ីៈ** នៅថ្ងៃសៅរ៍ណាមួយក្នុងខែតុលា ជារៀងរាល់ឆ្នាំ អង្គការមិត្តភាពគ្មានព្រំដែន ឬ ហ្វ្រិន្ទ្រ វីដ ដៅ អេ បរ ដឺ (Friends without a Border) តែងប្រារព្ធកម្មវិធីក្នុងពេលរាត្រីនៅក្លឹបមួយក្នុងរដ្ឋញូជឺស៊ី ដែលមានការចូលរួមពីបងប្អូនខ្មែរក្នុងសហរដ្ឋអាមេរិក និងសប្បុរសជនសញ្ជាតិដទៃទៀតផងដែរ។ គោលបំណងចម្បងនៃកម្មវិធី គឺប្រមូលថវិកាឧបត្ថម្ភដល់មន្ទីរពេទ្យកុមារអង្គរខេត្តសៀមរាប ក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីផ្តល់ប្រាក់ខែដល់ពេទ្យ គិលានុបដ្ឋយិកា និងបុគ្គលិកនៅទីនោះ ត្បិតអ្នកទាំងអស់នោះត្រូវបំពេញកិច្ចការដ៏សំខាន់នេះជាយូរអង្វែង ព្រោះបញ្ហាសុខភាពកុមារត្រូវការជាចាំបាច់តម្រូវឱ្យមន្ទីរពេទ្យមួយនេះ ត្រូវមានធនធានគ្រប់គ្រាន់ទប់ទល់នឹងការចំណាយសំដៅឱ្យការប្រព្រឹត្តទៅនៃមន្ទីរពេទ្យបានរលូនបម្រើសេវាដល់កុមារនានាជាអចិន្ត្រៃយ៍។ ម្យ៉ាងវិញទៀត មន្ទីរពេទ្យកុមារអង្គរប្រដូចទៅនឹងអង្គការមនុស្សធម៌មិនគិតប្រាក់ចំណេញហេតុផល គឺរាល់ការព្យាបាលដល់កុមារពីអាយុរាប់ពីពេលកើតដល់១៦ឆ្នាំ ដោយមិនគិតថ្លៃ។ លើកលែងតែគ្រួសារដែលមានលទ្ធភាព ហើយមកព្យាបាលនៅមន្ទីរពេទ្យកុមារអង្គរអាចជួយផ្តល់ថវិកាឧបត្ថម្ភដល់មន្ទីរពេទ្យតាមលទ្ធភាពដែលខ្លួនមានដោយមិនមានជាការបង្ខំឡើយ។


Dr ChanPheaktra Ngoun.
អនុប្រធានមន្ទីរពេទ្យកុមារអង្គរ


Mr. Nerou Cheng
គណកម្មការខ្មែរនៅសហរដ្ឋអាមេរិក
សម្រាប់មន្ទីរពេទ្យកុមារអង្គរ

ឆ្នាំនេះខួបលើកទី១៤នៃមិត្តភាពគ្មានព្រំដែនប្រព្រឹត្តទៅនៅល្ងាចថ្ងៃសៅរ៍ទី១៩ខែតុលាឆ្នាំ២០១៣ នៅរដ្ឋញូជឺស៊ី ក្រោមការចូលរួមពីគណកម្មការអ្នកស្ម័គ្រចិត្តជួយរៀបចំកម្មវិធីនិស្សិតខ្មែរដែលមករៀននៅអាមេរិក ព្រមទាំងភ្ញៀវកិត្តិយសអន្តរជាតិ និងខ្មែរជិតឆ្ងាយជុំវិញសហរដ្ឋអាមេរិក ដែលអញ្ជើញមកពីរដ្ឋផ្សេងៗរួមមានហ្វីឡាដែលហ្វៀ (Philadelphia) បសស្តុន (Boston) ញូជឺស៊ី (New Jersey) ញូយ៉ក (New York) និង វ៉ាស៊ីនតោន (Washington)។ តម្លៃសំបុត្រចូលរួមគឺ $៧៥ក្នុងម្នាក់។ ជាមួយគ្នានោះដែរ កម្មវិធីប្រមូលថវិកាឆ្នាំនេះមិនខុសពីឆ្នាំមុនៗឡើយ គឺមានដាក់តាំងលក់ផលិតផលហត្ថកម្មខ្មែរដែលរៀបចំ និងគ្រប់គ្រងដោយអ្នកស្រី អេមី ហ្វាស៍ (Ami Farges) មានកូនស្រីចិញ្ចឹមជាជនជាតិខ្មែររូបគំនូរគូរដោយវិចិត្រករខ្មែរអាហារពេលល្ងាច ការច្រៀងរាំលក្ខណៈខ្មែរ ជាពិសេសគឺការដេញថ្លៃនានាទាំងសាយឡិន (Silent Auction) និងដេញថ្លៃដោយផ្ទាល់(Live Auction) ស្វែងរកអ្នកឧបត្ថម្ភប្រាក់ខែដល់ពេទ្យ និងគិលានុបដ្ឋយិកានៅពេទ្យកុមារអង្គរមានទឹកប្រាក់ឧបត្ថម្ភ៥០០ដុល្លារ មានអ្នកលើកដៃចំនួន៧នាក់ទឹកប្រាក់ឧបត្ថម្ភ២០០ដុល្លារ មានអ្នកលើកដៃជិត១០នាក់ បន្តដល់ តទៅទំព័រទី ០៥




KhmerPost USA, LLC
សារពត៌មានខ្មែរផុសសហរដ្ឋអាមេរិក
អាស័យដ្ឋាន 45 Merrimack St. Suite 218A. Lowell, MA 01852
លេខទូរស័ព្ទ Phone: 978 677-7163 | Fax: (978) 677-7092
អ៊ីម៉ែល info@khmerpost.us
អានកាសែតនៅគេហទំព័រ www.khmerpost.us
តាមដានយើងនៅទំព័រហ្វេសប៊ុក Like us at: www.facebook.com/KhmerPostUSA
ផ្សាយពាណិជ្ជកម្ម Advertising
អគ្គនាយកទីផ្សារ និងគ្រប់គ្រង សុបិន្ត ពិន Soben Pin, *Managing Partner*
លេខទូរស័ព្ទ 978 - 656 - 8141 (Mobile) 978 677-7163 (Office) |
អ៊ីម៉ែលsobenpin@khmerpost.us
អ្នកនិពន្ធ Editorials
និពន្ធនាយក ពិន សំខុន Roger Samkhon Pin, *Publisher & Editor-in-Chief*
(978) 942 - 1641 | rogerpin@khmerpost.us

អ្នកនិពន្ធកិត្តិយស **Contributed Writers:**
Kim Phien, Kim Sos, Mao Chan Somnom, Mam Yin,
Richard Howe Esq. Sengly Kong, Ph.D.
ច្នៃសោភ័ណភាពកាសែត **Design Artist**
Heng Chhunleng
ជំនួយការរដ្ឋបាល **Administrative Assistant**
Sokha Lim

KhmerPost USA, LLC is an independent newspaper that aims to facilitate mass communication among the Cambodian communities, their neighboring communities, and families. We aim to address local community, and national news; and give an insight into Cambodian & global news. We also strive to bridge the language and cultural gaps and reduce social isolation by publishing in Khmer & English. It published twice a month in Massachusetts serving Greater Lowell, Lynn, Revere, MA, Providence, RI, CT, NY, NJ, and Philadelphia, PA.

Mail subscription is available within the U.S. & Canada at $60.00 or 70 Euros in Europe per year.

The KhmerPost USA has full authorization from Bernard Krisher, the publisher of the Cambodia Daily to reproduce all the articles that are produced by the Cambodia Daily free of charge effective date: 6/19/2009

តមកពីទំព័រទី ៤

## ខួបលើកទី១៤ នៃអង្គការមិត្តភាពគ្មានព្រំដែន...

ទឹកប្រាក់១០០ដុល្លារ និងមានជាហូរហែ។

កញ្ញា វីរៈសោភាវត្តី អាយុ២២ឆ្នាំ ជានិស្សិតឆ្នាំទី១រៀនជំនាញទំនាក់ទំនងអន្តរជាតិ ក្នុងមហាវិទ្យាល័យ Borough of Manhattan Community College នៅទីក្រុងញូយ៉ករស់នៅក្នុងសង្កាត់ប្រន់ហ្ស៊ី (Bronx) បានស្ម័គ្រចិត្តចូលរួមជួយរៀបចំកម្មវិធីរាត្រីនោះជាលើកទី៣ជាប់គ្នាជាមួយបងប្អូនស្រីរបស់នាងពីររូបទៀតគឺកញ្ញាវីរៈធីតាលាភា និង យុវតី វីរៈសុភ័ក្ត្រ ទេវី រាប់ចាប់ពីឆ្នាំ២០១១មក និងបានមានមតិចាប់អារម្មណ៍ដូច្នេះថា នាងមានទឹកចិត្តសប្បាយរីករាយក្នុងការចូលរួមកម្មវិធីនេះ ហើយនាងយល់ថា កម្មវិធីនេះជាកម្មវិធីល្អ និងមានសារសំខាន់ខ្លាំងណាស់ ព្រោះជាកម្មវិធីសប្បុរសប្រមូលថវិកាសំដៅផ្តល់ប្រាក់ខែដល់ពេទ្យ និងបុគ្គលិកមន្ទីរពេទ្យដែលពេញចិត្តបំពេញការងារប្រកបដោយក្រមសីលធម៌ និងបេះដូងជួយជនរួមជាតិ។ គួរបញ្ជាក់ផងដែរជាមធ្យមនៅការប្រមូលថវិការៀងរាល់ឆ្នាំគឺក្នុងរង្វង់ទឹកប្រាក់២ម៉ឺនដុល្លារសហរដ្ឋអាមេរិកបូកសរុបចំណូលទាំងអស់នេះបើតាមប្រសាសន៍របស់លោក នេរ៉ុហ៍ ឆេង (Nerou Cheng) ជាសហគ្រិនល្បីឈ្មោះម្នាក់នៅទីក្រុងញូយ៉ក និងជាគណកម្មការខ្មែរមួយរូបសម្រាប់មន្ទីរពេទ្យកុមារអង្គរ ។ លោក នេរ៉ុហ៍ ឆេង (Nerou Cheng) បានមានប្រសាសន៍ថា សាច់រឿងរំជួលចិត្តនៃប្រវត្តិកកើតមន្ទីរពេទ្យកុមារអង្គរដែលបង្ហាញដោយស្ថាបនិកមន្ទីរពេទ្យនេះ គឺជាងថតរូបដ៏ល្បីល្បាញម្នាក់ឈ្មោះ Kenro Izu ក្នុងបេសកកម្មរបស់លោកថតទិដ្ឋភាពអង្គរនៅខេត្តសៀមរាបលោកប្រទះក្មេងស្រីស្លាប់នៅនឹងមុខរបស់លោកដោយសារជំងឺ។ ក្នុងហេតុការណ៍នោះលោក Kenro Izu មានសេចក្តីរំជួលចិត្តយ៉ាងខ្លាំង និងបានតាំងចិត្តបង្កើតមន្ទីរពេទ្យនៅចំក្រុងសៀមរាបទុកជាការចូលរួមចំណែកព្យាបាលកុមារ និងដើម្បីតបស្នងសងគុណពីទិដ្ឋភាពដ៏ល្អប្រណិតនៃតំបន់អង្គរដែលផ្តល់ឱ្យលោកបានថតរូបយ៉ាងល្អត្រកាល និងរកប្រាក់ចំណូលបានប្រសើរពីការថតនេះ។ ទន្ទឹមនឹងថវិកាជំនួយពីខ្មែរ និងខ្មែរព្រមទាំងជនបរទេសដែលនៅសហរដ្ឋអាមេរិកមន្ទីរពេទ្យកុមារអង្គរក៏ទទួលជំនួយឧបត្ថម្ភពីបណ្តាប្រទេសផ្សេងៗរួមមាន បារាំង (France) សាំងហ្គាពួរ (Singapore) ជប៉ុន (Japan) **តទៅទំព័រទី ២៩**



ភ្ញៀវកិត្តិយសខ្មែរចូលរួមខួបលើកទី១៤នៃអង្គការមិត្តភាពគ្មានព្រំដែន



Ami Farges and Nellie Moore



Sopheavattey Virak



Thidaleaphea Virak



Sopheaktevy Virak


# Create Success

Over the years, Enterprise Bank has learned the importance of remaining a genuine community bank by hiring people of diverse cultures, making decisions on the local level, providing personalized, responsive service in your native language, and offering a wide range of financial possibilities. Bopha and Sue would be happy to speak to you in Khmer on how Enterprise Bank can assist you with your financial needs.



**Bopha Malone**
*Branch Relationship Manager, AVP*
Lowell Connector Branch
430 Gorham Street
Lowell, MA 01852
(978) 656-5561



**Sue Suon**
*Branch Service Specialist*
Main Office Lowell Branch
222 Merrimack Street
Lowell, MA 01852
(978) 656-5679

Call Bopha Malone or Sue Suon today and let them help you Create Success!

Enterprise Bank
CREATE SUCCESS

EnterpriseBanking.com

Member FDIC

# រីឆឹត ហូវ ទទួលរង្វាន់ កោតសរសើរពី CTI

ដោយៈ ខ្មែរផុស ស.រ.អា

សមាគម **Community Teamwork Inc** បានរៀបចំពិធីដ៏ត្រចះត្រចង់ជាមួយ ភ្ញៀវប្រមាណ២០០នាក់នៅសាល "**Lenzt**" នៃក្រុង" ដ្រាកិត" កាលពីថ្ងៃទី១០/២៣/២០១៣ **CTI** មានទម្លាប់តាមដានសង្កេតការអភិវឌ្ឍន៍នៃសង្គមមនុស្សក្នុងតំបន់





រីឆឹត ហូវ ទទួលរង្វាន់ប័ណ្ណកោតសរសើរពី ឃែរិន ហ្វេតជ្រិក អគ្គនាយក CTI

ហើយផ្តល់រង្វាន់ជាច្រើនកោតសរសើរដល់អ្នកដែលចេះផ្សព្វផ្សាយទំនើបពង្រីកវិជ្ជមាឌនៃព័តិមានសំខាន់ៗចែកជូនសមាគមប្រើជាប្រយោជន៍រៀងៗខ្លួន ។

ផ្លាករង្វាន់កោតសរសើរចំនួន៥បានត្រូវផ្តល់ជូនអ្នកដែលបានបំពេញតួនាទីបំរើសហគមន៍យ៉ាងយកចិត្តទុកដាក់ក្នុងនោះ រីឆាយ ហូវ ដែលចូលរួមសរសេរក្នុងខ្មែរផុស ស.រ.អា បានទទួលផ្លាករង្វាន់សំខាន់ជាងគេ គឺ **President´s Award Honire** ។

## Recognizing Community Action Through Innovative Communications

Through exemplary Community Action and Innovative Communications, these institutions and individuals have strengthened the social and economic fabric of our community.

**President's Award Honoree**
Richard Howe, Jr., Register of Deeds, Middlesex North

**Creating Informed, Engaged Communities Honorees**

Danielle McFadden, Executive Director
Greater Lowell Chamber of Commerce

Robert Mills, Police Reporter
Lowell Sun and Lowellsun.com

Town of Chelmsford
(with Town Manager Paul Cohen
and Assistant to the Town Manager Patricia Dzuris)

Dr. Georges Grinstein & the Institute
for Visualization & Perception Research, UMass Lowell

**Marjorie McDermott Award Honoree**
State Senator Jamie Eldridge

COMMUNITY TEAM WORK


សុខភាពល្អប្រសើរ ក្នុងដៃលោកអ្នក





បើលោកអ្នកមានជំងឺ ឈឺហើមជើងដៃពិបាកធ្វើចលនា -ឈឺនោមច្រើន -ដេកស្រមុកខ្លាំង -មានស្ករច្រើនក្នុងឈាម -ឡើងទម្ងន់ធាត់ -ស្បែកឡើងកន្ទួល លោកអ្នកត្រូវចាំថា មានឱសថសក្តិសិទ្ធមានលក្ខណៈជាប្រភេទចំណី អាចជួយឱ្យសះស្បើយបានយ៉ាងឆាប់រហ័ស ។
ឱសថធម្មជាតិ ជាប្រេងចម្រាញ់ចេញពីពន្លកគ្រាប់ស្រូវមានការត្រួតពិនិត្យដោយវេជ្ជបណ្ឌិតត្រឹមត្រូវ អាចប្រើដោយមិនប្រឆាំងនឹងថ្នាំពេទ្យ ដែលប្រើប្រាស់រាល់ថ្ងៃទេ ។
លោក វិចិត្រ ភូស៊ីវ៉ុឌ ៦២ឆ្នាំ មុនប្រើ"អេមស្កា" គាត់ឈឺទឹក នោមផ្អែម ឈឺបេះដូង លើសឈាម -"អាលើជី"-ឈឺសន្លាក់ ដៃជើង ឈឺក្រពះ... ។ល ។

**បន្ទាប់ពីបានប្រើ"អេមស្កា"**

លេប៩គ្រាប់ក្នុង១ថ្ងៃ-បីថ្ងៃក្រោយមក អន់ឈឺសន្លាក់ដៃជើង -១ខែក្រោយអាចរត់ឡើងជណ្តើរបាន-បីខែក្រោយទៀតសរសៃឈាម២លែងស្ទះ-ឥឡូវនេះអាចរត់បាន១០គីឡូម៉ែត្រ-ធ្វើតេស្តឈាមមានភាពហ្នឹងន់ល្អឡើងវិញ ៕

ចង់ដឹងបន្ថែមលេខទូរស័ព្ទលេខ
-ហ្វីឡាខាងត្បូង ២១៥ ២៣៧ ៥៧០៥ សាមន់ថា -ហ្វីឡាខាងជើង ២១៥ ៦៦៧ ៨៤៣១ រ៉េរ



Grand Opening

សម្ពោធឱសថស្ថាន សិនជួរី

CENTURY PHARMACY & OPTICAL

937 Gorham St    All MAJOR INSURANCES ACCEPTED    Tel: 978-455-6554

- ទទួល និងផ្ញើវេជ្ជបញ្ជាដោយឥតគិតថ្លៃ
- យកចិត្តទុកដាក់ខ្ពស់ដល់អតិថិជនគ្រប់រូប
- ទទួលគ្រប់ប័ណ្ណធានារ៉ាប់រងទាំង មេឌីឃែរ (Medicare) និងមេឌីឃេដ (Medicaid)
- អាចបង់ប្រាក់ដោយលុយសុទ្ធ.ម៉ាន់នីអ័រដឺ (Money order) ឬដោយចម្លង/ បញ្ញើតាមទូរសារ
- អាចជួយចំណាយរួមគ្នា បើត្រូវតាមលក្ខណខណ្ឌ
- យើងមានជំនាញខាងជំងឺឆ្លង និងជំងឺរ៉ាំរ៉ៃ
- មានកញ្ចប់ពិសេសជូន




មានបុគ្គលិកខ្មែរ និង និយាយភាសាខ្មែរ

អាស័យដ្ឋាន : 937 Gorham St Lowell, MA 01852
ទូរស័ព្ទ : 978-455-6554 / ទូរសារ : 978-455-9476

# បោះឆ្នោតនៅឡូវែល ថ្ងៃអង្គារទី៥ ខែវិច្ឆិកា ឆ្នាំ២០១៣

**អត្ថបទដោយៈ លោក រីឆាដ ហូវ**

**ប្រែសម្រួលជាខេមរភាសា ដោយៈ ហេង លីមហ៊ាង**

ម្ចាស់ឆ្នោតនៅឡូវែលនឹងបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុងថ្មី និងគណៈកម្មការសាលាថ្មី នៅថ្ងៃ អង្គារទី៥ ខែវិច្ឆិកា ឆ្នាំ២០១៣។ ការបោះឆ្នោតនឹងប្រព្រឹត្តទៅដោយចាប់ផ្តើមនៅម៉ោង ៧ព្រឹក រហូតដល់ម៉ោង៨យប់។ ប្រសិនបើលោកអ្នកមានសំណួរទាក់ទងនឹងការបោះឆ្នោតសូមទាក់ទងមកកាន់ គណៈកម្មធិការរៀបចំការបោះឆ្នោត តាមលេខទូរស័ព្ទ ៩៧៨ ៦៧៤ ១២០០។

មានបេក្ខជនចំនួន១៨នាក់ដែលឈរឈ្មោះជាទីប្រឹក្សាក្រុង។ អ្នកបោះឆ្នោតម្នាក់អាចធ្វើការបោះឆ្នោតគាំទ្របេក្ខជន៩រូបជាអតិបរមា ។ នៅលើសន្លឹកឆ្នោតនាមរបស់ទីប្រឹក្សាក្រុងក្នុងពេលបច្ចុប្បន្ន ហើយដែលកំពុងឈរឈ្មោះម្តងទៀត ឈ្មោះអ្នកទាំងអស់នោះ លេចឡើងតាមលំដាប់លំដោយនៃលេខរៀងព្យញ្ជនៈនៃបេក្ខជនប្រកួតប្រជែងទាំងអស់ ហើយរាយនាមទៅតាមលំដាប់លំដោយនៃព្យញ្ជនៈទាំងអស់នោះ ។ ទាំងនេះជាឈ្មោះបេក្ខជនក្នុងបញ្ជីបោះឆ្នោត ដែលនឹងលេចឡើងក្នុងសន្លឹកឆ្នោតៈ

រ៉ដនីយ៍ អេលៀត (Rodney Elliott): ជាប់ឆ្នោតជាទីប្រឹក្សាក្រុងលើកទីមួយនៅឆ្នាំ១៩៩៧។ អាយុ៥៣ឆ្នាំ។ រស់នៅក្នុងសង្កាត់ ផឹធឹខេត។ បំពេញការងារជាអ្នកវិភាគថវិកាសម្រាប់ភ្នាក់ងារការពារបរិស្ថាន។

អិដ ខេណេឌី (Ed Kennedy) : ជាប់ឆ្នោតជាទីប្រឹក្សាក្រុង កាលពីពីរឆ្នាំមុនតែធ្លាប់បម្រើការងារក្នុងក្រុមប្រឹក្សាក្នុងទសវត្ស៧០ និង៨០។ ហើយក៏ធ្លាប់បម្រើការងារក្នុងគណៈកម្មការប្រតិភូប្រចាំខណ្ឌមិដដលស៊ិកផងដែរ ក្នុងទសវត្ស៩០។ អាយុ៦២ឆ្នាំ។ រស់នៅសង្កាត់ ប៊ែលវីដេរ៍។ បំពេញការងារជាអ្នកវិភាគអចលនវត្ថុ។

ចន លាហ៊ីយ៍ (John Leahy): បញ្ចប់ភារកិច្ចក្នុងក្រុមប្រឹក្សានៅឆ្នាំ២០១១ តែមានវត្តមានសារជាថ្មីនៅពេលដែលទីប្រឹក្សាលាឈប់ក្នុងឆ្នាំ២០១២។ ពីមុនធ្លាប់បម្រើការងារជា

**តទៅទំព័រទី ១៥**



Richard Howe Jr.

# Lowell election on Tuesday, November 5

**by Richard P Howe Jr**

Translate into Khmer by Limheang Heng

Voters of the city of Lowell will elect a new city council and a new school committee on Tuesday, November 5, 2013. The polls will be open from 7:00 A.M. until 8:00 P.M. If you have questions about where you vote or about anything else related to the election, call the Lowell Election Commission at (978) 674-1200.

There are 18 candidates for city council. A voter may vote for up to nine of them. On the ballot, the names of the present city councilors who are seeking re-election appear first in alphabetical order followed by the challengers listed in alphabetical order. Here is the list of candidates in the order they will appear on the ballot:

Rodney Elliott. First elected to city council in 1997. 53 years old. Lives in Pawtucketville. Works as a budget analyst for the Environmental Protection Agency.

Ed Kennedy. Elected to city council two years ago but also served on the council in the 1970s and 1980s. Also served as Middlesex County Commissioner in 1990s. 62 years old. Lives in Belvidere. Works as real estate appraiser.

John Leahy: Finished 11th in 2011 council election but joined the council when a councilor resigned in 2012. Previously served several terms on the Lowell School Committee. 51 years old. Lives in Belvidere. Works as self-employed painting contractor.

Marty Lorrey. Elected to city council two years ago. 57 years old. Lives in Belvidere. Retired from U.S. Post Office.

Bill Martin. First elected to city council in 1999. Elected mayor in 2005. 51 years old. Lives in Belvidere. Works as a lawyer.

Joe Mendonca. First elected to city council in 2009. Previously served on Lowell School Committee for several terms. U.S. Air Force veteran. 54 years old. Lives in Pawtucketville. Works as independent software engineer.

Rita Mercier. First elected to city council in 1995. 65 years old. Lives in Belvidere. Works as administrative assistant at Lowell Community Counseling Center.

Vesna Nuon. Elected to city council two years ago. 45 years old. Lives in Highlands. **Continued to page 11**


## កម្មវិធីថែសុខភាពតាមគេហដ្ឋានសម្រាប់ចាស់ៗ និងជនពិការភាព

- នាងថែខ្ញុំដូចជាម្តាយបង្កើត ខ្ញុំសប្បាយចិត្តណាស់
- នាងស្រឡាញ់និងថែខ្ញុំដូចជីដូនបង្កើត
- នាងចំអិនម្ហូប បោសសំអាតផ្ទះ បោកខោអាវ ហើយស្តាប់រឿងខ្ញុំពេលខ្ញុំកើតទុក្ខ
- ខ្ញុំមានពេទ្យមកពិនិត្យសុខភាពជាប្រចាំ
- នាងរលឹកពេលដែលខ្ញុំត្រូវញាំថ្នាំ គ្រប់ពេលវេលា
- នាងជូនខ្ញុំដើរលេងលំហែកាយ
- នាងជួយខ្ញុំទិញម្ហូបនិងសំភារៈប្រើប្រាស់
- កូនខ្ញុំមិនព្រួយអំពីភាពអត់ការងារធ្វើ ហើយបាននៅក្បែរខ្ញុំគ្រប់ពេលវេលា
- ព្រឹទ្ធាចារ្យជាដំពេជ្យក្នុងសង្គមយើង ចូរអ្នកទាំងអស់ខំថែទាំគាត់អោយមានអាយុវែងនិងសុខភាពល្អ។

ក្រុមហ៊ុនយើងខ្ញុំកំពុងជ្រើសរើសបុគ្គលិកធ្វើការ

សម្រាប់ពត៌មានបន្ថែមអំពីកម្មវិធីនេះសូមទាក់ទង

ម៉ូនីដា (២៦៧) ២៦២-៣៩២៩ ដេវីដ (២៦៧) ៩១៨-៨៤៩៣

HOME CARE Aurora



# ទីស្នាក់នៅឯសួនពឺកឃីនស៍

ខ្មែរផុសស.រ.អា.

រំឭកទៅថ្ងៃទី២៣ មិនា ឆ្នាំ១៩៨៧ អគ្គិភ័យមួយបានឆាបឆេះបង្កការខូចខាតអគារកាត់ផ្លូវអេខិនតម្រង់ទៅស្ពានអ៊ូលេតសរុបទឹកប្រាក់ ១០លានដុល្លារសហរដ្ឋអាមេរិក ។

រសៀលថ្ងៃអង្គារសប្តាហ៍នេះ សាលាក្រុង និងស្ថាប័នរដ្ឋបានប្រមូលផ្តុំជួបជុំគ្នាកាត់ខ្សែបូរណិសម្ពោធអគារស្នាក់នៅពឺឃីនស៍ ដែលស្ថិតក្នុងលំដាប់ទី៤៧ និងជាប្រភេទបន្ទប់ប្រណិតគ្រែពីរ ។

ក្នុងកម្មវិធីនោះ មានការរំឭកពីស្នាដៃនៃក្រុមហ៊ុនសាងសង់ វ៉ល្ស (Walsh Construction) ដោយមានការរំឭកនឹកដល់ឈ្មោះលោក អិដ វ៉ល្ស (Ed Walsh Jr.) ជាសូចនករណ៍សំខាន់បន្តអភិវឌ្ឍគម្រោងកែកុនលំអសាងសង់ឡើងវិញនូវអគារស្នាក់នៅពឺឃីនស៍នេះ ។ គួរឱ្យសោកស្តាយដែលលោកអិដ វ៉ល្ស ( Ed Walsh Jr.) បានទទួលមរណភាពទាំងតក់ក្រហល់នៅអាយុ ៥២ឆ្នាំ កាលពីខែមករាកន្លងទៅ ។

គួរបញ្ជាក់ផងដែរ កាសម្ពោធអគារស្នាក់នៅពឺឃីនស៍មានការចូលរួមពីអភិបាលក្រុង ផាទ្រីក មីហ្គី ប្រធានក្រុង បឺនី លីនឆ៍ និងភ្ញៀវកិត្តិយសសំខាន់ៗជាច្រើនរូបទៀត ក្នុងខ្លឹមសារទាំងស្រុងដូចខាងក្រោម ។

# The Residences @ Perkins Park

**Posted on October 23, 2013**
**By Jennifer Myers, Mayor's Aid**
**Photo Courtesy by City Hall Official Blog "Room 50"**

On March 23, 1987 a 9-alarm blaze ripped through the Lawrence Mills Complex adjacent to the Ouellette





(Aiken St.) Bridge.

Two-hundred firefighters from 17 communities fought the inferno, fueled by fuel tanks and old textiles. Five firefighters were hospitalized.

When the smoke cleared, 300,000 of the site's 800,000 square feet of mill space was gone, amounting to nearly $10 million in damages.

What had been, in its heyday of the late 1800's and early 1900's a complex that had employed 5,000 people, had become a blight.

State Rep. Tom Golden recalls there being a movement afoot following the fire to "just level it, clear it and knock it all down," a movement halted by historic preservationists, like Peter Aucella, who had a larger vision.

Tuesday afternoon, city and state officials gathered at the site to cut the ribbon on the latest restoration - the Residences @ Perkins Park, 47 market -rate one and Continued to Page14

# ទស្សនាប្រទេសបារាំង ( បន្ត )

**ដោយៈ ពិន សំខុន**

យើងឆ្លៀតឱកាស២ថ្ងៃផល្លៀសខ្លួនចេញពីទីក្រុងប៉ារីស ដើម្បីទៅទស្សនាជនបទទីក្រុងរ៉ែន (Rennes) នៃតំបន់ប្រឺតាញ (Bretagne) ដែល




ស្ថិតនៅទិសខាងលិចជាប់នឹងសមុទ្រអាតាឡង់ទិក (Atlantic) និងចំងាយ៣៥០គមពីទីក្រុងប៉ារីស ។ ទៅដល់ទីនោះ យើងត្រូវកាត់ទីក្រុងធំ២, មួយឈ្មោះថា ស្ហាត្រ (Chartres) និងមួយទៀតឈ្មោះ ឡឺម៉ង់ ( Le Mans) ។

ជាអតីតមហាអំណាចចក្រព័ន្ធគ្រប់គ្រងអាណានិគមខ្មែរ ប្រទេសបារាំង នៅមានដីទំនេរច្រើន វាលប្រាលជ្រៅជាអ្នកចេះធ្វើសង្គ្រាម ហើយមានសម្បត្តិច្រើនទៀតផង ។

គ្រសារខ្មែរ ពីដើមានគ្រួសារដោយសារមានមណ្ឌលទទួលខ្មែរភៀសខ្លួនទៅរ៉ែន ឥឡូវនេះរយៈពេលប្រមាណ៣០ឆ្នាំ ហើយដែលខ្មែរភៀសខ្លួនមកនៅទីនេះតែមួយចំនួនក៏បានចាកចេញទៅរស់នៅទៅផ្សេងទៅហើយដែរ នៅលស់ខ្មែរប្រមាណ ៥០គ្រួសារប៉ុណ្ណោះ ដែលចាក់ឫសនៅទីនោះបង្កើតជាសហគមន៍ព្រះពុទ្ធសាសនាមួយតាំងពីឆ្នាំ ១៩៧៨មកម្លេះ។ ថ្ងៃសៅរ៍ទី១៣ កន្លងទៅនេះព្រះតេជគុណ ចាន់ សុវណ្ណ សុផាត (មេវត្ត) និង



បន្ទាយសង់ច្រើនសតវត្សរ៍មកហើយការពារសាំងម៉ាឡូកុំសត្រូវឈ្លានពាន

លូងលើយធ្វើកសិកម្មបានច្រើន។ ឆ្នាំនេះដោយសារនយោបាយនៃប្រធានាធិបតីថ្មីមកពីចរន្តសង្គមនិយម ប្រជាពលរដ្ឋកិរិតតូចទាបមានភាពរីករាយដោយសារមានការគាំទ្រច្រើនពីរដ្ឋាភិបាលតែពលរដ្ឋកិរិតកណ្តាល និងជាន់ខ្ពស់ត្អូញត្អែរពីជីវភាពស្រុតចុះដោយសារពន្ធដារថ្លៃ រកស៊ីមិនបានជាទូទៅសេដ្ឋកិច្ចបារាំងចុះទន់ខ្សោយដោយសារការតម្លើងពន្ធឥវ៉ាន់ថ្លៃលក់មិនដាច់។ តំបន់ប្រឺតាញពុំមែនជាតំបន់សេដ្ឋកិច្ចទេតែសម្បូរដោយទេសចរណ៍មកទស្សនាច្រើន ដោយសារមានសម្បត្តិវប្បធម៌សេសសល់ពីបូរាណច្រើនកន្លែងបញ្ជាក់ពីការទប់ទល់សង្គ្រាមដោយបន្ទាយធំៗមានវិហារកាតូលិករាយពាលពេញប្រកបដោយក្បាច់ចម្លាក់គួរឱ្យកោតសរសើរ ។

យើងមានឱកាសមួយល្ងាចទៅទស្សនាសាំងម៉ាឡូ (Saint Malo) ដែលមានរូបសញ្ញាថា បារាំងជំនាន់មុនជាតំបន់ប្រឺតាញជាពលរដ្ឋមានជំនឿព្រះតេជគុណ ផុន ភក្តី (និមន្តមកពីបារីស) រួមដំណើរដោយលោកតា សេន អាត (អាចារ្យ) បាននិមន្តទៅធ្វើការប្រោះព្រំឡើងផ្ទះឱ្យពុទ្ធបរិស័ទជើងវត្ត គឺនាង ហរ៉ាត ស្វាមី ជើរ៉ កូនស្រីវត្តី កូនប្រុស រ៉ូម៉េអូស្ថិតនៅម៉ុំម៉ុងស្មែមុង (Mongermont) ថ្ងៃអាទិត្យមានការជួបជុំប្រជាពលរដ្ឋធ្វើបុណ្យនៅវត្តមានរាំកំសាន្ត ជាមួយការប្រគុំតន្ត្រីដឹកនាំដោយមឿស ផា ដែលមានតួនាទីជាអនុប្រធានសមាគមប្រចាំ"អ៊ីលអោវីឡែន" ចូលរួមរីករាយជាមួយពុទ្ធបរិស័ទជើងវត្តប្រមាណ៥០នាក់ ។ មឿស ផា និយាយថា "ឆ្នាំនេះយើងមានការចូលរួមគ្នាបានល្អជាងឆ្នាំមុនៗដែលឃើញតែពីឈ្លោះបែកបាក់គ្នា ឥឡូវយើងអាចស្រាក់លុយគ្នាចូលជួយគណបក្សសង្គ្រោះជាតិ ហើយបាននាំគ្នាទៅធ្វើបាតុកម្មសម្តែងឆន្ទៈនៅប៉ារីសរួមគ្នាទៀតផង ។

តំបន់ប្រឺតាញមានផ្ទៃដីជាឆ្នេរសមុទ្រផ្នែកខាង

តទៅទំព័រទី ១១

# ប្រារព្ធខួបថ្ងៃ ២៣ តុលា ១៩៩១ ប្លែកពីមុន

ដោយ : ខ្មែរជុំសស.រ.អា



▸ មហាបាតុកម្មប្រជាជាតិខ្មែរបានផ្ទុះឡើងតាមគម្រោងគណបក្សសង្គ្រោះជាតិកាលពីថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៣ ខួបទី២២ នៃកិច្ចព្រមព្រៀងទីក្រុងប៉ារីសដែលអង្គការសហប្រជាតិ និងប្រទេសហត្ថលេខីទាំងអស់បានសន្យាផ្តល់សុខសន្តិភាព សេរីភាព និងលទ្ធិប្រជាធិបតេយ្យជូនកម្ពុជាវិញ បន្ទាប់ពីសង្គ្រាមក្នុង និង ក្រៅស្រុកបានបំផ្លាញពលរដ្ឋខ្មែរឱ្យទៅជាប្រជាជាតិដែលកំពង់រលត់អស់រយៈពេលជិត៣០ឆ្នាំ ។

២៣ឆ្នាំក្រោយមកពាក្យសន្យារបស់អង្គការរបស់អ.ស.ប និងហត្ថលេខីនៃសន្ធិសញ្ញាក្រុងប៉ារីសនៅតែជាពាក្យភុតកុហក់ពលរដ្ឋខ្មែរ ដដែលដោយពលរដ្ឋនៅតែរស់នៅក្នុងការគម្រាមកំហែងដោយការគ្រប់គ្រងក្នុងផលប្រយោជន៍បក្ខពួក និងផលប្រយោជន៍បរទេសខ្វះស្បៀង ខ្វះការថែទាំសុខភាព ខ្វះការងារសម្រាប់រស់នៅជាមនុស្សតែដដែល ។ ថ្ងៃ២៣ តុលា នេះពលរដ្ឋខ្មែរ និងគណបក្សសង្គ្រោះជាតិបាននាំយកហត្ថលេខានៃអ្នកតវ៉ាឱ្យមានការផ្លាស់ប្តូរសង្គមខ្មែរចំនួន២លាននាក់ដង្ហែដោយបាតុករប្រមាណ៤ម៉ឺននាក់ទៅជូនតំណាងអង្គការសហប្រជាជាតិទាមទារឱ្យមានការត្រឡប់មកគោរពអត្ថន័យនៃកិច្ចព្រមព្រៀងអន្តរជាតិក្រុងប៉ារីសឱ្យបានត្រឹមត្រូវមកវិញ ។

លោក សម រង្ស៊ី និងលោក កឹម សុខា ដែលជាតារាឯកក្នុងការដឹកនាំបាតុកម្មមហាជនដ៏មានប្រជាប្រិយភាពនេះ បានសម្តែងចំអក"ខ្ញុំកោតតែលោក ហ៊ុន សែន នៅមុខក្រាសទៀត ប្រជាជនស្អប់មួយពិភពលោកទៅហើយ! ចុះចេញទៅ ប្រជាជនលែងត្រូវការលោក ហ៊ុន សែន ទៀតហើយ!..." លោក កឹម សុខា ថា "យើងចង់បង្ហាញថា សន្ធិសញ្ញាក្រុងប៉ារីសនៅមានសុពលភាព ហើយនៅតែត្រូវការឱ្យមានការដោះស្រាយនៅឡើយ ហើយម្យ៉ាងទៀត ឱ្យដោះស្រាយភាពមិនប្រក្រតីនៃការបោះឆ្នោត..." ។

បាតុកម្មនេះប្រព្រឹត្តទៅក្នុងរយៈពេលបីថ្ងៃក្នុងគោលការណ៍ទាមទារឱ្យមានការផ្លាស់ប្តូរនៅកម្ពុជា និងឱ្យរកយុត្តិធម៌ជូនម្ចាស់ឆ្នោត ។ បន្ថែមពីនេះទៀតបាតុករ នឹងទៅបង្ហាញឆន្ទៈដដែលនេះនៅមុខស្ថានទូតនៃប្រទេសមួយចំនួនមានស្ថានទូតបារាំង, ចក្រភពអង់គ្លេស, ស.រ.អា, រុស្ស៊ី, ឥណ្ឌូណេស៊ី, ចិន, ដែលគេជឿថា ប្រទេសទាំងនោះមានលទ្ធភាពកោះហៅសមាជិកហត្ថលេខីនៃសន្ធិសញ្ញាក្រុងប៉ារីសឱ្យមករួមប្រជុំដំណើរការវិញបាន ។

បាតុកម្មអហឹង្សានៅតែបន្តដំណើរយ៉ាងមាំទាំ និងពេញកម្លាំង បើទោះបីជាមានការចោទប្រកាន់ដោយចរន្តគំនិតថា "មធ្យោបាយប្រើឱ្យឃឹតយ៉ាវក្នុងការដណ្តើមអំណាច... ឬក៏ចង់ពន្យាពេលសំរាប់ចរចាចែកអំណាចជាមួយបក្សប្រជាជន... ឬក៏មានការភ័យខ្លាចមានអាសន្ននាំគ្នារត់ទៅបរទេសពិបាកចូលស្រុកវិញ ។ល។" ក៏ដោយ ។ លោក សម រង្ស៊ី ទើបនឹងត្រឡប់មកពីបារាំងបានបំពេញការងារប្រាស្រ័យទាក់ទងជាមួយប្រទេសសំខាន់ៗនៅអឺរ៉ុបរហូតដល់ថ្ងៃ២១នេះ រួចហើយមកចូលរួមមហាបាតុកម្ម៣ថ្ងៃនៅកម្ពុជាយ៉ាងគ្មានហត់នឿយ ។ នៅឯនាយសមុទ្រឯណោះខ្មែរនៅបរទេសនាំគ្នាសម្តែងឆន្ទៈដោយបាតុកម្មនៅបារាំងនាវិមានត្រូកាដេរ៉ូ កាលពីថ្ងៃទី២០បាតុកម្មនៅមុខវិមាន អ.ស.ប នៅសហរដ្ឋអាមេរិកនៅមុខវិមាន អ.ស.ប នៅហ្សឺណែវនៃប្រទេសស្វីសទាំងអស់គ្នាបាននាំនូវការគាំទ្រដល់មហាបាតុកម្មរបស់ប្រជាជាតិខ្មែរដឹកនាំដោយគណបក្សសង្គ្រោះជាតិនៅកម្ពុជាយ៉ាងពេញទំហឹងដដែល ។

ប្រឈមមុខនឹងចលនាអហិង្សានៅកម្ពុជា គណបក្សប្រជាជន និងលោក ហ៊ុន សែន នៅតែបន្តការកាន់អំណាចរៀបចំគណរដ្ឋមន្ត្រីរបស់ខ្លួនយ៉ាងស្ងាត់ស្ងៀម បើទោះបីជាមិនបានគោរពច្បាប់ និងនីតិវិធីគ្រប់គ្រងស្ថាប័នសភាជាតិគ្រប់គ្រង់ក៏ដោយ ។ ស្ថានភាពហឹង្សាមិនបានកើតឡើងនាពេលនេះ តែពុំមាននរណាដឹងថា "តើសមាជិកគណបក្សប្រជាជនមានការព្រួយបារម្ភប៉ុណ្ណានោះទេ.."

ដោយដឹកនាំមិនបានតាមអំណាចរដ្ឋ ហើយនឹងស្របគ្នានឹងចលនាបាតុកម្មនេះតែពូនធំឡើងមិនអាចរង់ចាំដីរធំជើង៤គង់មានភ្លាត់នោះឡើយ" ។

ខួបថ្ងៃ២៣ តុលា ១៩៩១ លើកនេះមានលក្ខណៈធំទូលាយជាងខួបមុនៗដែលសហគមន៍ខ្មែរទាំងក្នុង និងក្រៅស្រុកប្រារព្ធច្រើនឆ្នាំបន្តបន្ទាប់គ្នាយ៉ាងច្រើន ។ លើកនេះប្រជាពលរដ្ឋខ្មែរជាច្រើនមិនដែល **តទៅទំព័រទី ១១**






# ឡូវែលត្រូវការ ជីម មីលីណាសហ្សូ (Jim Milinazzo)



ជីម មីលីណាសហ្ស (Jim Milinazzo) តែងតែតស៊ូមតិនាំសម្លេងលោកអ្នកទៅកាន់សាលាក្រុង ។ គាត់តែងតែមានឆន្ទៈក្នុងការក្រោកឈរឡើងក្នុងគោលជំហការពារប្រជាពលរដ្ឋក្នុងឡូវែល ទោះក្នុងកាលៈទេសៈមួយចំនួនគាត់ត្រូវធ្វើតែម្នាក់ឯងក៏ដោយ ។

ក្នុងនាមជាអភិបាលក្រុង លោកជីម តែងតែផ្តល់ការគោរពទៅកាន់ភាពជាអ្នកដឹកនាំប្រកបដោយគរុកោសល្យរបស់ទីប្រឹក្សាក្រុង ក៏ដូចជាគណៈកម្មការសាលាផងដែរក្នុងពេលដែលសហគមន៍កំពុងប្រឈមនឹងឧបសគ្គទាំងឡាយ ។

ជីម មីលីណាសហ្សូ តែងតែកម្រិតការបំពេញការងារស្ថិតក្នុងស្តង់ដារទទួលខ្ពស់ ។

### ទិសដៅអភិវឌ្ឍសេដ្ឋកិច្ច

គាំទ្រ វត្តមានរបស់មន្ទីរពេទ្យ Lowell Community Health Center ព្រមទាំងការិយាល័យបំពេញការងារ និងស្នាក់នៅក្នុងអគារ a MAppleton Mill Complex ស្ថិតនៅ Hamilton Canal District ។

ការពង្រីកថ្មីនូវទំហំមន្ទីរពេទ្យ Lowell General Hospital ។

### ការអប់រំជាសាធារណៈ

បោះឆ្នោតគាំទ្រឱ្យមានថវិកាដល់សាលាសាធារណៈនៅឡូវែល ។ ពង្រឹងភាពជាដៃគូរវាងសាកលវិទ្យាល័យ UMASS Lowell និងមហាវិទ្យាល័យ Middlesex ។

### សុវត្ថិភាពសាធារណៈ

បោះឆ្នោតឱ្យមានទឹកប្រាក់បន្ថែមដល់ជំនួយផ្នែកសុវត្ថិភាពសម្រួលឧបទ្ទវហេតុហឹង្សាក្នុងទីប្រជុំជន ។ លើកទឹកចិត្តឱ្យមានការបញ្ចេញមតិដោយចំហជុំវិញអ្នករស់នៅជិតខាងទាំងអស់ក្នុងសហគមន៍ ។

លោកជីម មីលីណាសហ្សូ ជាកូនប្រុសយកសម្តីជាធំ និងធ្វើឱ្យសម្តីទាំងអស់នោះក្លាយជាសកម្មភាព ។

លោកជីម មីលីណាសហ្សូ (Jim Milinazzo) តែងតែបង្ហាញពីភាពជាអ្នកដឹកនាំដ៏រឹងមាំក្នុងការស្វែងរកដំណោះស្រាយប្រកប ដោយប្រសិទ្ធភាពសម្រាប់ក្រុងឡូវែលរបស់យើង ។

### មនសិការ បទពិសោធន៍ និងភាពជាអ្នកដឹកនាំ បច្ចុប្បន្ន និង ខ្លាំងជាងមុន !

ឧបត្ថម្ភដោយគណៈកម្មការបោះឆ្នោតគាំទ្រ ជីម មីលីណាហ្សូ-ជាទីប្រឹក្សាក្រុង ។







Continued from Page 07

# Lowell election on Tuesday,...

Works at State Sex Offender Registry Board.

Cory Belanger. Ran unsuccessfully for city council in 2011. 44 years old. Lives in Belvidere. Owner of Major's Pub.

Fred Doyle. Has run for city council many times but has never served. 74 years old. Lives in Highlands. Retired painter.

Genevieve Doyle. First-time candidate. 36 years old. Lives in Centralville. Works as documentation specialist at Genzyme.

Erik Gitschier. First campaign for city council. Was elected and still serves on Greater Lowell Vocational High School school committee. 42 years old. Lives in Highlands. Works as superintendent of town of Lexington water and sewer department.

Stacie Hargis. First-time candidate. 36 years old. Lives in downtown. Works as director of Community Teamwork's Small Business Center.

Jim Milinazzo. Failed to win election to city council in 2011 after serving several terms including one as mayor. 59 years old. Lives in Belvidere. Works as Vice President of Business Services at Jeanne d'Arc Credit Union.

Derek Mitchell. First-time candidate. 33 years old. Lives in Belvidere. Works as Executive Director of International Institute of Lowell.

Van Pech. Second time running for city council. 29 years old. Lives in South Lowell. Works as a counselor at Advocates, a human service organization.

Dan Rourke. First-time candidate. 37 years old. Lives in Pawtucketville. Works as a probation officer in the Massachusetts courts.

William Samaras. First-time candidate. 71 years old. Lives in Belvidere. Retired headmaster of Lowell High School.

In addition to these candidates running for city council, there are seven candidates running for Lowell School Committee. Voters may choose up to six of them. All six incumbents are running for re-election. They are David Conway, Robert Gignac, James Leary, Connie Martin, Kristin Ross-Sticawich and Kim Scott. The one challenger is Steve Gendron who is running for school committee for the first time but who served two terms on the city council in the 1990s.

តមកពីទំព័រទី ៩

## ប្រារព្ធខួបថ្ងៃ២៣ តុលា ១៩៩១....

ធ្លាប់ចេញមកគាំទ្រព្រឹត្តិការណ៍នយោបាយដោយចំហរ គ្មានភ័យខ្លាចដល់ការគ្រោះថ្នាក់ដល់រូបរាងកាយ និងដល់ជីវិតពិសេសទៅទៀតគ្មានធ្វើដោយជំពាក់គុណនរណា...បានចេញមកសម្តែងឆន្ទៈស្របគ្នាទាមទារឱ្យ"២៣តុលាមិនមែនជាការចំអកដល់ប្រជាពលរដ្ឋខ្មែរទេ" ហើយនៅថ្ងៃដដែលនេះដែរ បើមិនមែនជាការចំអកទេ សូមឱ្យរកយុត្តិធម៌ជូនម្ចាស់ឆ្នោតដែលទើបបានបោះឆ្នោតសភារួច" ។ គឺជាការទាមទារនៅថ្ងៃដ៏មានន័យសំខាន់សំរាប់ជីវិតប្រជាពលរដ្ឋខ្មែរម្នាក់ៗឱ្យអាចក្រោកឈរទៅរួច ។

ទល់នឹងការគ្រោះថ្នាក់ដល់ផលប្រយោជន៍ផ្ទាល់ខ្លួននៃរបបគណបក្សប្រជាជនការកែទម្រង់ណាមួយដែលស្របនឹងទ្រឹស្តី"ប្រជាធិបតេយ្យ សេរីពហុបក្ស" ដែលចែងក្នុងសន្ធិសញ្ញាក្រុងប៉ារីស បើទោះបីជាគ្មានការប្តូរផ្លាស់ដៃកាន់អំណាចទៅគណបក្សថ្មីក៏ដោយគណបក្សប្រជាជនកម្ពុជាដែលកំពុងបង្ហាញប្រវត្តិទុច្ចរិត.អយុត្តិធម៌ និងកាចសាហាវពុំអាចបន្តអំណាចរបស់ខ្លួនយូរអង្វែងបានឡើយ ពីព្រោះ "លោក ហ៊ុន សែន គ្មានអ្វីទៀតទេ ក្រៅ ពីកាំភ្លើងនោះ"នៅពេលនេះ ។ នៅយូរបន្តិចទៀតមិនត្រឹមតែកាំភ្លើងទេ នឹងត្រូវដកចេញពីដៃបក្សពួកទាំងអស់ និងរងគ្រោះដោយសារទង្វើអគតិរបស់លោក ហ៊ុន សែន ថែមទៀត ៕

ការិយាល័យ មេធាវី
ថំមាស ស្តាលីយ៉ាណូស
Law Office of Thomas Stylianos Jr.
287 Appleton St. Lowell MA 01852
Immigration • Divorce • Auto Crash
▸ អន្តោប្រវេសន៍ ▸ គ្រោះថ្នាក់រថយន្ត ▸ លែងលះប្តីប្រពន្ធ
សូមទូរស័ព្ទមក: សោភា ឬធំ
978-459-5000 or 800-308-3766
Only Licensed in Massachusets

តមកពីទំព័រទី ៨

## ទស្សនាប្រទេសបារាំង...



លិចទាំងមូលនៅខាងជើងនៃក្រុងប្រេសក៍ (Brei) ជាផ្នែកដែលសម្បូរណ៍ផ្ការលាន់ជាងតំបន់ណាទាំងអស់ ។ មានការកត់ត្រាប្រវត្តិក្រុងប្រឹតាញ ថា ជាតំបន់ចោរសមុទ្រឈ្មោះ "វីគីង" (Les Viking) រស់នៅដោយសារ ការប្លន់នៅសមុទ្រ អាមេរីតា ជិតបូស្តុន (Boston) ជាដើម ។ វិចិត្រករបារាំង បានសរសេរ និងគូររូបជីវចលឡើង"អាស្តេរីក"(Asterix)ធ្វើឱ្យគូររូបថ្លុក អាស្តេរីក អ៊ីដេហ៊ីក ឬអូបេលីត បានក្លាយជាតួ







អមតៈក្នុងការចងចាំរបស់បារាំងគ្រប់រូប ។

ធាតុអាកាសមិនត្រជាក់ណាស់ពេកទេ តែរដូវក្តៅកន្លងទៅបាត់ហើយ បាននៅសល់មេឃស្រឡះ និងថ្ងៃកំដៅខ្លះៗតែប៉ុណ្ណោះ ។ សុបិនដែលបានស្គាល់ប្រទេសបារាំងលើកដំបូងមើលឃើញប្រទេសនេះមានលក្ខណៈច្រើនយ៉ាងដូចគ្នា និងផ្ទះសម្បែងដំណាំ ដាំដុះ ការតុបតែង ប្រៀបធៀប ទៅនឹងកម្ពុជាក្រោមបានច្រើន អន្លើ "ផ្លូវតូចៗ ផ្ទះតូចៗ តុបតែងលម្អដាំផ្កានៅមាត់បង្អួចមានផ្ទះលក់ទំនិញកំបិកកំប៉ុកជាប់គ្នាៗ" ធ្វើឱ្យនាងនឹកដល់ស្រុកដែលធ្លាប់រស់នៅកាលពីតូចៗយ៉ាងខ្លាំង -ផ្លូវសាធារណៈក្នុងក្រុងជាច្រើនមិនចាក់កៅស៊ូខ្មៅដូចផ្លូវក្រៅក្រុងទេ តែរៀបជាដុំថ្មតម្រៀបគ្នាជាក្បាច់មូល ឬត្រង់ ធ្វើឱ្យផ្លូវនៃប្រទេសបារាំងមានលក្ខណៈពិសេសរបស់ខ្លួនគួរឱ្យកត់សម្គាល់ ។

ជនជាតិបារាំងចាស់ៗច្រើនឈរជជែកគ្នាលេងពីនេះពីនោះពេលរសៀលលេងកំសាន្ត"ប៊ូលប៉េតង់"កំដរពេលវេលាខ្លះក៏ស្ពាយនំប៉័ងស្រួលវែងខ្ចប់យកទៅផ្ទះ -ក្រាកង់ និងនំបង្អែម ជាមុខជំនាញនៃហាងលក់នំប៉័ងដ៏ច្រើនរៀបចំយ៉ាងប្រណីតសម្រាប់ទាក់ទាញអ្នកទិញចំណីចាំបាច់យកទៅគ្រប់ផ្ទះ ។ ពលរដ្ឋបារាំង ហូបកាហ្វេក្រាស់ៗណាស់ នៅហាង -គេក៏ចូលចិត្តភេសជ្ជៈដូចជាស្រាបៀរ ស្រាក្រហម ខ្លាំងៗ បិតនៅបារាំងឬអាល្លឺម៉ង់មានរស់ជាតិពិសេសមិនដូចស្រាអាមេរិកទេ ។

**លេខក្រោយយើងនឹងត្រឡប់មកប៉ារីសម្តងទៀត ៕**

ឌឹ ខេមបូឌា ដេលី The Cambodia Daily

ជំនាន់ថ្មីប្រែសម្រួលពីកាសែតអង់គ្លេស អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌឹ ខេមបូឌា ដេលី ច្បាប់ចេញផ្សាយថ្ងៃ ព្រហស្បតិ៍ ទី២៨ ខែតុលា ឆ្នាំ២០១៣

# មនុស្សរាប់ពាន់នាក់ចូលរួមក្នុងមហាបាតុកម្ម របស់គណបក្សសង្គ្រោះជាតិ

ដោយ Colin Meyn and Simon Marks - October 23, 2013

ក្រុមអ្នកគាំទ្រគណបក្សសង្គ្រោះជាតិរាប់ពាន់នាក់បានធ្វើដំណើរមកកាន់ទីលានប្រជាធិបតេយ្យកាលពីព្រឹកថ្ងៃពុធនេះ ដើម្បីចូលរួមធ្វើមហាបាតុកម្មរយៈពេលបីថ្ងៃដែលបានចាប់ផ្តើមនៅព្រឹកនេះក្នុងបំណងអំពាវនាវឱ្យអង្គការសហបរិវេណអ្នកតវ៉ា ហើយផ្លូវសំខាន់ៗក្នុងក្រុងបើកឱ្យចរាចរណ៍ជាធម្មតា។

នៅវេលាម៉ោងពារសៀលនេះ គណបក្សសង្គ្រោះជាតិគ្រោងនឹងដឹកនាំអ្នកគាំទ្រចំនួន៥០០០នាក់ ដើម្បីដង្ហែក្បួនទៅកាន់ការិយាល័យរបស់អង្គការសហប្រជាជាតិនៃឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស ដើម្បីដាក់ញត្តិដោយអំពាវ





ប្រជាជាតិ និងប្រទេសដែលជាហត្ថលេខីនៃកិច្ចព្រមព្រៀងទីក្រុងប៉ារីស ឱ្យជួយអន្តរាគមន៍បញ្ហាផ្ទៃកនយោបាយដែលកំពុងជាប់គាំង ក្រោយពីការបោះឆ្នោតដ៏ចម្រូងចម្រាសកាលពីថ្ងៃទី២៨ ខែកក្កដា។

អ្នកគាំទ្រគណបក្សសង្គ្រោះជាតិនាំគ្នាជ្រកក្រោមឆ័ត្រដើម្បីចូលរួមមហាបាតុកម្មនៅឯទីលានប្រជាធិបតេយ្យកាលពីព្រឹកមិញ ។(ភោគ ដន, The Cambodia Daily)

វាមិនដូចជាការតវ៉ាមុនៗទេដែលបានធ្វើឡើងដោយគណបក្សសង្គ្រោះជាតិនោះ គឺមានវត្តមានរបស់កងកម្លាំងសន្តិសុខជាច្រើននាក់បានដាក់ពង្រាយក្នុងទីក្រុងភ្នំពេញ ប៉ុន្តែបាតុកម្មលើកនេះមានកងកម្លាំងសន្តិសុខតិចតួចបំផុតនៅជុំវិញនាវឱ្យមានការអន្តរាគមន៍ ដើម្បីទម្លាយភាពជាប់គាំងផ្នែកនយោបាយ និងទាមទាឱ្យបង្កើតគណៈកម្មាធិការដើម្បីស៊ើបអង្កេតភាពមិនប្រក្រតីនៃការបោះឆ្នោត។

សាលាក្រុង និងក្រសួងមហាផ្ទៃបានប្រកាសកាលពីម្សិលមិញនៅក្នុងកិច្ចប្រជុំនៅនាទីចុងក្រោយមួយថា?ខ្លួនអនុញ្ញាតឱ្យគណបក្សសង្គ្រោះជាតិដឹកនាំអ្នកគាំទ្រត្រឹមតែ១.០០០នាក់ ដើម្បីហែក្បួនតាមផ្លូវនានាក្នុងរាជធានីភ្នំពេញ ដើម្បីដាក់ញត្តិទៅការិយាល័យអង្គការសហប្រជាជាតិ និងស្ថានទូតបរទេសនានា អំឡុងមហាបាតុកម្មរយៈពេលបីថ្ងៃរបស់ខ្លួន។

**សូមរង់ចាំអានព័ត៌មានលម្អិតនៅថ្ងៃស្អែក**

# Thousands Join Opposition Rally in Phnom Penh

**By Colin Meyn and Simon Marks - October 23, 2013**

At least 20,000 opposition supporters made their way to Freedom Park in Phnom Penh on Wednesday morning to begin the first of a three-day demonstration designed to urge signatories of the Paris Peace Agreement to intervene in the country's current political deadlock.

Unlike at the previous protests conducted by the CNRP, the security presence around the capital was minimal and all major roads in the city center were open to traffic.

At about 3:30 p.m., tens of thousands of CNRP supporters left Freedom Park and marched to the U.N. Office of the High Commissioner for Human Rights to hand in a petition asking officials there to push the government to conduct an independent investigation into election irregularities.

After City Hall originally said it would not allow the CNRP to march, the Ministry of Interior on Tuesday said it would let 1,000 opposition supporters march through the city.

On Thursday and Friday, more marches will take place in order to hand the same petition to a host of embassies belonging to countries that signed the 1991 Peace Agreement, which was signed 22 years ago today.

At a press conference this morning, CNRP leaders Sam Rainsy and Kem Sokha outlined the purpose of the demonstration—an investigation into July's election, binding electoral reform and government adherence to the promises within the Paris Peace Agreements, including guarantees of a liberal and multi-party democracy.

Since July's contested election, the CPP has pushed ahead with convening a one-party National Assembly and forming a new government headed by Prime Minister Hun Sen, despite an ongoing boycott of parliament by the 55 elected CNRP lawmakers.

Addressing concerns by the government that opposition marches and demonstrations could get out of hand should crowds become too large, Mr. Rainsy said that the CNRP could guarantee that its supporters would not be the cause of violence.

"We ensure that our organization has taken every measure to ensure that there is no violence," Mr. Rainsy said.

"If there is violence, it does not come from us. It comes from elements who want to provoke," he said, adding that the CNRP would cooperate with government authorities to ensure that outside elements do not disturb the opposition demonstrations.

ផ្ទះល្វែងសម្រាប់ជួល
Lynn- ៣បន្ទប់គេង, កម្រាលឈើម៉ាំ, បន្ទប់ធំ
ងាយស្រួលនៅក្នុងសហគមន៍ខ្មែរ សាលារៀន
និងទីកន្លែងចតឡាន
ថ្លៃជួល $1100 ហៅ 617-840-8611
(ភាសាអង់គ្លេស)
781-632-4916 (ភាសាខ្មែរ)



BOULEY TRUCKING & PAVING
Tom Bouley
52 Bolton ST
Lowell, Ma 01852
978-804-1214
Tom Machado
147 Billerica St
Lowell, Ma 01852
805-726-1141
Paving - Trucking - Bobcat Service - Snow Removal
Fully Insured
Free Estimates

ឌឹ ខេមបូឌា ដេលី The Cambodia Daily

ដំណឹងខ្មែរសំរួលពីភាសាអង់គ្លេស អត្ថបទដកស្រង់ និងចុះផ្សាយដោយការអនុញ្ញាតពីកាសែត ឌឹ ខេមបូឌា ដេលី ច្បាប់ចេញផ្សាយថ្ងៃ ព្រហស្បតិ៍ ទី២៤ ខែតុលា ឆ្នាំ២០១៣

# ធនាគារចិនចុះហត្ថលេខាលើកិច្ចព្រមព្រៀងស្តីពីប្រាក់កម្ចីសម្បទាន១២១លានដុល្លារ

ដោយ Khuon Narim - October 17, 2013

កាលពីម្សិលមិញ ធនាគារចិន នីហរ័ណ-អាហរ័ណ (Export-Import Bank of China) បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងពីរ ដើម្បីផ្តល់ប្រាក់កម្ចីសរុបចំនួន១២១លានដុល្លារដល់សមភាគីកម្ពុជា នៅក្នុងពិធីចុះហត្ថលេខារៀបចំនៅឯក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រោមអធិបតីភាពរបស់លោក គាត ឈន់ អតីតរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

លោក គាត ឈន់ ដែលត្រូវបានជំនួសដោយលោក អូន ព័ន្ធមុនីរ័ត្ន ក្នុងតំណែងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច?និងហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា កាលពីថ្ងៃទី២៦ខែកញ្ញាត្រូវបានអញ្ជើញឱ្យចូលរួមជាភ្ញៀវកិត្តិយសក្នុងពិធីចុះហត្ថលេខានេះ។ លោកបានលើកឡើងថា កិច្ចព្រមព្រៀងទាំងនេះនឹងជួយឱ្យគម្រោងនានាមានសកម្មភាពជាក់ស្តែង។ គួររំឭកផងដែរថា គម្រោងទាំងនេះត្រូវបានអតីតរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុរូបនេះ និងលោក ពូ ជីនហ្គួ (Bu Jinguo) ឯកអគ្គរដ្ឋទូតប្រទេសចិន បានព្រមព្រៀងគ្នាកាលពីខែសីហា។

លោក គាត ឈន់ បានមានប្រសាសន៍ថា "កិច្ចព្រមព្រៀងស្តីពីប្រាក់កម្ចីសម្បទានទាំងពីរមានទឹកប្រាក់សរុប១២១លានដុល្លារ ដែលឯកឧត្តម លី រួហ្គូ (Li Ruogu) ប្រធានធនាគារចិន នីហរ័ណ-អាហរ័ណ និងឯកឧត្តម អូន ព័ន្ធមុនីរ័ត្ន ទើបតែបានចុះហត្ថលេខាថ្មីៗនេះ?គឺជាជំហានបោះទៅមុខមួយក្នុងដំណើរ ការអនុវត្តគម្រោងអភិវឌ្ឍន៍ប្រព័ន្ធធារាសាស្ត្រ អា ចាង (A Chang ) នៅក្នុងខេត្តកំពង់ឆ្នាំង និងគម្រោងសាងសង់បណ្តាញបញ្ជូនចរន្តអគ្គិសនីកម្លាំង១១៥គីឡូវ៉ុល តភ្ជាប់ពីរាជធានីភ្នំពេញទៅក្រុងបាវិត"។ លោកបានមានប្រសាសន៍បន្តទៀតថា "គិតរហូតមកទល់ពេលនេះ សាធារណរដ្ឋប្រជាមានិតចិន បានផ្តល់ហិរញ្ញប្បទានកិច្ចសហប្រតិបត្តិការចំនួន២.៨៥៦-សម្រាប់គម្រោងអភិវឌ្ឍន៍ និងហេដ្ឋារចនាសម្ព័ន្ធក្នុងប្រទេសកម្ពុជា **តទៅទំព័រទី ២២**

# ថៃនិងជប៉ុន ផ្តល់ជំនួយមនុស្សធម៌ដល់ជនរងគ្រោះដោយសារទឹកជំនន់នៅកម្ពុជា

ដោយ Denise Hruby and Aun Pheap - October 23, 2013

ក្រុមមន្ត្រីបានលើកឡើងកាលពីម្សិលមិញថា រដ្ឋាភិបាលជប៉ុន និងរដ្ឋាភិបាលថៃក៏ដូចជាសហគមន៍ថៃនៅក្នុងប្រទេសកម្ពុជាបានសម្រេចផ្តល់ជំនួយជាសម្ភារ និងលុយសុទ្ធដែលគិតជាទឹកប្រាក់សរុបប្រហែល៥២០.០០០ដុល្លារ ទៅឱ្យជនរងគ្រោះដោយសារទឹកជំនន់នៅក្នុងប្រទេសកម្ពុជា។

លោក ញឹម វណ្ណដា អនុប្រធានទី១នៃគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ បានលើកឡើងថា រដ្ឋាភិបាលជប៉ុននឹងផ្តល់ជំនួយប្រហែល៤០០.០០០ដុល្លារ ក្នុងពិធីផ្លូវការមួយដែលនឹងប្រារព្ធឡើងនៅព្រឹកនេះនៅឯអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ។ ស្ថានទូតជប៉ុនបានលើកឡើងថា ជំនួយជាសម្ភាររួមមានម៉ាស៊ីនភ្លើង និងឧបករណ៍បន្សុទ្ធទឹកដែលមានតម្លៃប្រហែល៣២០.០០០ដុល្លារ នឹងត្រូវផ្តល់ឱ្យរដ្ឋាភិបាលកម្ពុជា ដើម្បីជួយជនរងគ្រោះដែលកំពុងរងផលប៉ះពាល់ដោយទឹកជំនន់។

ស្ថានទូតជប៉ុនបានលើកឡើងក្នុងសេចក្តីថ្លែងការណ៍មួយកាលពីថ្ងៃច័ន្ទថា "ដោយឃើញថា មានការខូចខាតខ្លាំងដោយសារទឹកជំនន់ និងដោយសារតែមានទំនាក់ទំនងមិត្តភាពល្អរវាងជប៉ុន និងកម្ពុជារដ្ឋាភិបាលជប៉ុនបានសម្រេចផ្តល់ជំនួយមនុស្សធម៌បន្ទាន់សម្រាប់ប្រជាពលរដ្ឋដែលរងផលប៉ះពាល់ដោយសារទឹកជំនន់"។

កាសែត ឌឹ ណេសិន (The Nation) ដែលមានមូលដ្ឋាននៅទីក្រុងបាងកកបានរាយការណ៍ថា រដ្ឋាភិបាលថៃមានបំណងផ្តល់ជំនួយជាទូកសង្គ្រោះ ប៉ុន្តែត្រូវបានស្នើឱ្យផ្តល់ជំនួយជាប្រាក់សុទ្ធចំនួន២០០.០០០ដុល្លារជំនួសវិញទៅឱ្យកាកបាទក្រហមកម្ពុជា។

លោកស្រី កានីយ៉ា ហ្គោឡុកលី (Kanya Gollogly) អនុប្រធានក្រុមប្រឹក្សាពាណិជ្ជកម្មកម្ពុជា-ថៃ **តទៅទំព័រទី ២២**

# ក្រុងសៀមរាបនាំមុខទីក្រុងផ្សេងៗទៀតក្នុងបញ្ជីចំណាត់ថ្នាក់របស់ទស្សនាវដ្តីដ៏មានកិត្យានុភាព

ដោយ Michelle Vachon - October 23, 2013

ក្រុងសៀមរាបបាននាំមុខគេនៅក្នុងបញ្ជី "ទីក្រុងកំពូលទាំង១០នៅអាស៊ី" គឺនាំមុខទីក្រុងបាងកក និងទីក្រុងតូក្យូក្នុងបញ្ជីពានរង្វាន់ Readers' Choice Awards របស់ទស្សនាវដ្តី Conde Nast Traveler ដ៏មានកិត្យានុភាព។

បញ្ជីពានរង្វាន់របស់ទស្សនាវដ្តីនេះក៏បានផ្តល់ចំណាត់ថ្នាក់លេខ២ដល់សណ្ឋាគារសូហ្វីតែលភ្នំពេញ ភូគីត្រា Sofitel Phnom Penh Phokeethra ក្នុងចំណោមសណ្ឋាគារល្អបំផុតទាំង២៥នៅអាស៊ីអាគ្នេយ៍ផងដែរ។ យោងតាមលទ្ធផលដែលចុះផ្សាយក្នុងទស្សនាវដ្តីទេសចរណ៍នេះកាលពីសប្តាហ៍មុននេះ ក្រុងសៀមរាបទទួលបានពិន្ទុ៨៣.៦ភាគរយផ្នែកស្វាគមន៍រាក់ទាក់៨១ភាគរយផ្នែកបរិយាកាស៨០.៣ភាគរយផ្នែកកន្លែងស្នាក់នៅ និង៦៣.៨ភាគរយផ្នែកភោជនីយដ្ឋាន។

លោក ហូវ៉ាន់ឌី សហប្រធានក្រុមការងារទេសចរណ៍មានប្រសាសន៍ដោយក្តីរីករាយថា "ជយោ! នេះដោយសារតែការប្តេជ្ញាចិត្តយ៉ាងខ្លាំងក្លារបស់វិស័យឯកជនក្នុងការផ្តល់សេវាល្អផ្តល់ភ្ញៀវទេសចរណ៍។ យើងត្រូវតែផ្តល់សេវាល្អក្នុងតម្លៃសមរម្យ" ដែលមិនមែនរឿងសាមញ្ញឡើយ។

លោក ឆាល ហ៊ែនរី ឆេវេត (Charles-Henri Chevet) នាយកគ្រប់គ្រងទូទៅនៅសណ្ឋាគារសូហ្វីតែលមានប្រសាសន៍ថា នេះជាដំណឹងភ្ញាក់ផ្អើលគួរឱ្យស្វាគមន៍ដែលសណ្ឋាគារភ្នំពេញ ភូគីត្រា ដែលបានបើកទ្វារកាលពីពីរឆ្នាំមុន ដណ្តើមបានចំណាត់ថ្នាក់លេខ២ ក្នុងបញ្ជីសណ្ឋាគារល្អបំផុតនៅអាស៊ីអាគ្នេយ៍បន្ទាប់ពីសណ្ឋាគាររមណីយដ្ឋានអាម៉ាន់គីឡា (A មានកិលា) នៅលើកោះបាលី ក្នុងប្រទេសឥណ្ឌូណេស៊ី។

គួរបញ្ជាក់ថា មានទស្សនាវដ្តីទេសចរណ៍ជាភាសាអង់គ្លេសចំនួនពីរ ដែលការស្ទង់មតិអ្នកអានរបស់ខ្លួនផ្តល់លទ្ធផលពាក់ព័ន្ធនឹងភាពឥតខ្ចោះក្នុងវិស័យសណ្ឋាគារ នោះគឺទស្សនាវដ្តី Travel +Leisure និងទស្សនាវដ្តី Conde Nast Traveler។

លោក ឆាល ហ៊ែនរី ឆេវេត បានមានប្រសាសន៍ថា "ឥឡូវនេះយើងត្រូវតែរក្សាគុណភាពក្នុងកម្រិតនេះឱ្យបាន។ នេះគ្រាន់តែជាការចាប់ផ្តើមប៉ុណ្ណោះ" ដោយបានពន្យល់ថា ការទទួលបានចំណាត់ថ្នាក់លេខ២របស់សណ្ឋាគារសូហ្វីតែលនេះ នឹងតម្រូវឱ្យបុគ្គលិករបស់សណ្ឋាគារនេះ បន្តការប្តេជ្ញាចិត្តក្នុងការរក្សាបទដ្ឋានឱ្យស្ថិតក្នុងកម្រិតខ្ពស់។

សណ្ឋាគារផ្សេងៗទៀតនៅក្នុងប្រទេសកម្ពុជាក៏បានទទួលចំណាត់ថ្នាក់ល្អគួរឱ្យកត់សម្គាល់ក្នុងការស្ទង់មតិនេះផងដែរ។ បញ្ជីចំណាត់ថ្នាក់សណ្ឋាគារកំពូលទាំង២៥" នៅកម្ពុជា ឥណ្ឌូណេស៊ី សិង្ហបុរី ហ្វីលីពីន និងវៀតណាមនេះ រួមមានសណ្ឋាគារចំនួន៥ក្នុងប្រទេសកម្ពុជា។ សណ្ឋាគារឡារ៉េស៊ីដង់អង្គរ (La Residence d'Angkor) និងសណ្ឋាគារហ្រ្គង់ អូតែល អង្គរ(Raffles Grand Hotel d'Angkor) ដែលសុទ្ធតែស្ថិតនៅក្នុងក្រុងសៀមរាបទទួលបានចំណាត់ថ្នាក់លេខ៣ និងលេខ៤តាមរៀងគ្នា។

សណ្ឋាគារអាម៉ាន់សារ៉ា (A មានសារា) ដែលស្ថិតក្នុងក្រុងសៀមរាបដែរនោះ ជាប់ចំណាត់ថ្នាក់លេខ១៥ នាំមុខសណ្ឋាគារអាំងទែរកុងទីណង់តាល់ក្នុងប្រទេសសិង្ហបុរី (Inter Continental Singapore) ហើយសណ្ឋាគារឡឺរ៉ូយ៉ាល់ (Raffles Hotel Le Royal) ក្នុងរាជធានីភ្នំពេញជាប់ចំណាត់ថ្នាក់លេខ១៩ បន្ទាប់ពីសណ្ឋាគារសូហ្វីតែលផ្លាហ្សា (Sofitel Plaza) ក្នុងទីក្រុងហាណូយ។

យោងតាមគេហទំព័ររបស់ទស្សនាវដ្តីទេសចរណ៍ Conde Nast Traveler នេះ អ្នកអានទស្សនាវដ្តីនេះក្នុងចំនួនច្រើនបំផុតធ្លាប់មានបានចូលរួមក្នុងការស្ទង់មតិនេះ ដោយពួកគេត្រូវបានស្នើឱ្យដល់ចំណាត់ថ្នាក់សណ្ឋាគារ និងរមណីយដ្ឋានដែលខ្លួនពេញចិត្តផ្អែកលើចំណុចមួយចំនួនដែលមានចាប់ពីគុណភាពអាហាររហូតដល់ការតុបតែងសណ្ឋាគារ។

អ្នកអានសរុបចំនួន៧៩.២៦៨នាក់បានផ្តល់ចំណាត់ថ្នាក់ដល់សណ្ឋាគារ និងរមណីយដ្ឋានជាង១៦.០០០កន្លែង ហើយក៏បានចូលរួមក្នុងការស្ទង់មតិពីក្រុមហ៊ុនអាកាសចរណ៍ល្អបំផុត ទីក្រុងល្អបំផុត ។ល។និង ។ល។ផងដែរ។

**ប្រែសម្រួលដោយ ស៊ា ស៊ុយឈាង**

*Continued from page 08*

## The Residences @ Perkins Park...

two bedroom luxury apartments.

The project, developed by Mira Development and Charter Environ-mental, joins their initial development the 183-unit Lofts at Perkins Park in the former Hub Hoisery and Mc Quade buildings (opened in 2009), as well as a 370-space parking garage, in bringing life back to that section of the neighborhood.

In addition to the Residences @ Perkins Park, the mill complex's iconic administration building is currently being renovated and will be leased to UMass Lowell's Office of Advan cement.




"We thank you for never giving up on this project," Golden said to Bob Delhome, of Mira, and his team, adding that not even he, the most optimistic guy in town could have imagined what the site would become.

Mayor Patrick Murphy, who recently returned from the Mayors Institute on City design conference in Charleston, South Carolina said "Any mayor who attended would find themselves lucky to find a project like this in their downtown and close to the waterfront."

While it was a day of celebration, there was an aura of sadness as well, because one of the keys to the redevelopment, Ed Walsh Jr. of Walsh Construction was not there to see the project through. Walsh, 52, died unexpectedly in January.

"Ed loved the city and would have loved this today," said Delhome. "He was passionate about the city on many levels."

Walsh's wife Mary and father Ed Walsh Sr. were in attendance and participated in the ribbon cutting ceremony.

Delhome praised the city's government including City Manager Bernie Lynch. Assistant City Manager and Director of the Department of Planning and Development Adam Baacke, the Historic Board, the Development Services Department, and the Department of Public Works, as well as the Lowell National Historical Park in making the project a reality and making the process as easy and enjoyable as possible.

Lynch returned the compliment, saying Delhome, Walsh Jr., their team were a pleasure to work with.

"Lowell is really a city on the move, you can see that here today," Lynch said, adding his only regret about the project is that the administration building is being leased to UMass Lowell.

"I was hoping it would be made available as a City Manager residence," quipped Lynch, who is planning to move into the city's downtown.






តមកពីទំព័រទី ៧ ## បោះឆ្នោតនៅឡូវែលថ្ងៃអង្គារទី ០៥...

គណៈកម្មការសាលា៣ទៅ៤ដង។ អាយុ៥១ឆ្នាំ។ រស់នៅបែលវីដៀ។ បំពេញការងារក្នុងជំនួញផ្ទាល់ខ្លួនជាជាងគំនូរ។

ម៉ារទី ឡូរី (Marty Lorrey): ជាប់ឆ្នោតជាទីប្រឹក្សាក្រុងពីរឆ្នាំមុន។ អាយុ៥៧ឆ្នាំ ។ រស់នៅបែលវីដៀ។ ជាមន្ត្រីចូលនិវត្តន៍ពីស្ថានីយ៍ប្រៃសនីយ៍សហរដ្ឋអាមេរិក។

បៀល ម៉ារទីន (Bill Martin) : ជាប់ឆ្នោតលើកទីមួយក្នុងក្រុមប្រឹក្សាឆ្នាំ១៩៩៩។ ជាប់ឆ្នោតជាអភិបាលក្រុងឆ្នាំ២០០៥ ។ អាយុ៥១ឆ្នាំ។ រស់នៅបែលវីដៀ ។ បំពេញការងារជាមេធាវី។

ចូអ៊ី មិនដុនកា (Joe Mendonca) : ជាប់ឆ្នោតលើកទីមួយក្នុងក្រុមប្រឹក្សាឆ្នាំ២០០៩ ។ មុននេះធ្លាប់បម្រើការងារក្នុងគណៈកម្មការសាលាឡូវែល ៣ទៅ៤ដង។ ជាទាហានមាតុភូមិនិវត្តន៍អាមេរិក។ អាយុ៥៤ឆ្នាំ។ រស់នៅឯធីធីខេត។ បំពេញការងារជាវិស្វករសុហ្វវែរឯករាជ្យ។

រីដា មឺស៊ី (Rita Mercier) : ជាប់ឆ្នោតលើកទីមួយក្នុងក្រុមប្រឹក្សាឆ្នាំ១៩៩៥។ អាយុ៦៥ឆ្នាំ។ រស់នៅបែលវីដៀ ។ បំពេញការងារជាជំនួយការរដ្ឋបាលក្នុងមជ្ឈមណ្ឌលប្រឹក្សាសម្រាប់សហគមន៍ឡូវែល។

វ៉ាសនា នួន (Vesna Nuon) : ជាប់ឆ្នោតជាទីប្រឹក្សាក្រុងកាលពី២ឆ្នាំមុន ។ អាយុ៤៥ឆ្នាំ។ រស់នៅសង្កាត់ហៃឡែន។ បំពេញការងារនៅក្នុងគណៈកម្មការរដ្ឋការពារការបំពានផ្លូវភេទ។

ខរី ប៊ីលែនហ្គឺ (Cory Belanger) : ធ្លាប់ប្រកួតប្រជែងមិនបានជោគជ័យក្នុងតំណែងក្រុមប្រឹក្សាឆ្នាំ២០១១ អាយុ៤៤ឆ្នាំ។ រស់នៅបែលវីដៀ។ ជាម្ចាស់ហាងមេដឹ។

ហ្វ្រិដ ដូយអល (Fred Doyle) : ធ្លាប់ប្រកួតប្រជែងជាទីប្រឹក្សាក្រុងច្រើនដងតែមិនធ្លាប់ទទួលបានឱកាសបម្រើការងារនៅឡើយ។ អាយុ៧៤ឆ្នាំ។ រស់នៅសង្កាត់ហៃឡែន ។ ជាជាងគំនូរចូលនិវត្តន៍។

ហ្សេនេវីវ ដូយអល (Genevieve Doyle) : ជាបេក្ខជនប្រកួតប្រជែងលើកទីមួយ ។ អាយុ៣៦ឆ្នាំ។ រស់នៅសង្កាត់សិនថ្រលវីល។ បំពេញការងារជាមន្ត្រីជំនាញរក្សាឯកសារនៅជែនហ្សីម។

អេរីក ហ្គីតសឆី (Erik Gitschier): ប្រកួតប្រជែងជាលើកទីមួយ។ ត្រូវបានជាប់ឆ្នោត និងកំពុងបំពេញការងារជាគណៈកម្មការអប់រំបំពេញបន្ថែមក្នុងវិទ្យាល័យតំបន់ឡូវែល ។ អាយុ៤២ឆ្នាំ។ រស់នៅសង្កាត់ហៃឡែន។ បំពេញការងារជាអ្នកចាត់ចែងក្នុងមន្ទីរធនធានទឹក និងដេរប៉ាក់ប្រចាំឡិកស៊ីងតុន។

ស្ទេស៊ីយ៍ ហាហ្គីស (Stacie Hargis): ជាបេក្ខជនដំបូង។ អាយុ៣៦ឆ្នាំ។ រស់នៅក្នុងទីប្រជុំជនឡូវែលដោនថោន។ បំពេញការងារជានាយកមជ្ឈមណ្ឌលក្រុមការងារសហគមន៍សម្រាប់ជំនួញតូចៗ។

ជីម មីលីណាសហ្សូ (Jim Milinazzo): មិនទទួលជោគជ័យក្នុងការប្រកួតប្រជែងឆ្នាំ២០១១ បន្ទាប់ពីបម្រើការងារជាច្រើនអាណត្តិក្នុងសាលាក្រុងរាប់ទាំងតំណែងអភិបាលក្រុងចំនួន១ដង។អាយុ៥៩ឆ្នាំ។ រស់នៅបែលវីដៀ។ បំពេញការងារជាអនុប្រធានគ្រឹះស្ថានហិរញ្ញវត្ថុសម្រាប់ជំនួញហៅថា ជីន ដាក។

ដេរែក មីតឆែល (Derek Mitchell) : ជាបេក្ខជនលើកទីមួយ។ អាយុ៣៣ឆ្នាំ។ រស់នៅបែលវីដៀ។ បំពេញការងារជានាយកប្រតិបត្តិសម្រាប់វិទ្យាស្ថានអន្តរជាតិក្នុងតំបន់ឡូវែល។

វ៉េន ពេជ្រ (Van Pech) : ដាក់ប្រកួតប្រជែងជាលើកទី២។ អាយុ២៩ឆ្នាំ។ រស់នៅក្នុងប៉ែកខាងត្បូងនៃឡូវែល។ បំពេញការងារជាទីប្រឹក្សា និងជាអ្នកតស៊ូមតិសម្រាប់អង្គការបម្រើការងារមនុស្សធម៌។

ដេន រូគី (Dan Rourke): ជាបេក្ខជនលើកទីមួយ។ អាយុ៣៧ឆ្នាំ។ រស់នៅក្នុងសង្កាត់ធីធីខេត។ បំពេញការងារជាមន្ត្រីព្រហ្មទណ្ឌប្រចាំតុលាការរដ្ឋម៉ាសាឈូសេត។

វីល្លៀម សាម៉ារ៉ាស់ (William Samaras): ជាបេក្ខជនប្រកួតលើកដំបូង។ អាយុ៧១ឆ្នាំ។ រស់នៅក្នុងតំបន់បែលវីដៀ។ ជាប្រធានសាលាចូលនិវត្តន៍ពីវិទ្យាល័យឡូវែល។

ជាមួយគ្នានោះដែរ មានបេក្ខជនចំនួន៧នាក់ ដែលកំពុងឈរឈ្មោះជាគណៈកម្មការសាលាស្របពេលដែលមានបេក្ខជនឈរឈ្មោះជាទីប្រឹក្សាក្រុង។ អ្នកបោះឆ្នោតអាចជ្រើសរើស៦នាក់ក្នុងចំណោម៧នាក់នៃអ្នកឈរឈ្មោះជាគណៈកម្មការសាលា។ មានបេក្ខជន៦រូបដែលកំពុងស្ថិតក្នុងតំណែងរួមមាននាម ដេវិដ ខុនវេយ៉្ស រ៉ូប៊ីត ហ្គីកណាក្ស ចេមស៍ លារ៉ៃ ខូនី ម៉ារទីន្ស គ្រីសស្ទីនរ៉ស ស្ទីសាវីជ្ជ និង ឃីម ស្កត់។ បេក្ខជនដែលឈរឈ្មោះប្រកួតប្រជែងគឺ ស្ទីវ ហ្គិនដ្រុន កំពុងឈរឈ្មោះជាលើកទីមួយសម្រាប់តួនាទីជាគណៈកម្មការសាលាតែធ្លាប់បានបម្រើការងារ២ អាណត្តិក្នុងតំណែងជាទីប្រឹក្សាក្រុងក្នុងទសវត្ស៩០៕


# បុណ្យខួបឆ្នាំទី២៩

សមាគមខ្មែរ

១៩៨៤ 1984 ២០១៣ 2013

CAMBODIAN MUTUAL ASSISTANCE ASSOCIATION LOWELL Massachusetts

# 29th Anniversary Celebration

**សមាគមខ្មែរក្រុងឡូវែល**
*មានកិត្តិយសគោរពអញ្ជើញ*
*លោក លោកស្រី និងប្រិយមិត្ត*
*ទាំងអស់ចូលរួមក្នុងពិធីជប់លៀង*
*បុណ្យខួបឆ្នាំទី២៩ នៃសមាគមខ្មែរ*
*ដែលនឹងប្រារព្ធធ្វើឡើងនៅ៖*
**ថ្ងៃសៅរ៍ ទី២ ខែវិច្ឆិកា ឆ្នាំ២០១៣**
*ម៉ោង ៦:៣០ ល្ងាច-ម៉ោង ១២ អាធ្រាត*
**ភោជនីយដ្ឋានក្រុងប៉ៃលិន**
**តម្លៃវិភាគទាន ៣៥ ដុល្លារទិញទុកមុន**
***៤០ ដុល្លារទិញនៅមាត់ទ្វារ***
**សំលៀកបំពាក់សមរម្យ**
សម្រាប់ពត៌មានបន្ថែមសូមទាក់ទង៖
៩៧៨-៤៥៤-៦២០០

**The Cambodian Mutual Assistance Association of Greater Lowell, Inc.**
*Cordially invites you to its*
*29th Anniversary Celebration*
*on*
*Saturday, November 2, 2013*
*6:30 pm to 12:00 midnight*
*at*
*Pailin City Restaurant*
*6 Branch Street*
*Lowell, MA 01851*
*Donation: $35 in advance*
*$40 at the door*
*$5 optional donation towards*
*Young Professionals Program*
*Formal Attire*
*Dinner, Live Music, Traditional Dancing & Cash Bar*
**Questions/Information:**
**978-454-6200**

# ខែដែលរដ្ឋម៉ាសាឈូសេតប្រារព្ធ"ក្រុងអន្តោប្រវេសន៍ និងសហគ្រិន"

ឡូវែលជាក្រុងមួយក្នុងចំណោមអ្នកដែលចូលរួមយ៉ាងសកម្មក្នុងពិធីប្រារព្ធ"ក្រុងអន្តោប្រវេសន៍ និងសហគ្រិន"។ រៀបចំដោយការិយាល័យ"អភិវឌ្ឍន៍សេដ្ឋកិច្ច" ដែលបានផ្តើមឡើងកាលពីថ្ងៃទី១៥ តុលា កន្លងទៅ ។

ផេមស៍ បានផ្តល់សេចក្តីរាយការណ៍ជាភាសាអង់គ្លេសបានបញ្ជាក់ថា ក្រុមអន្តោប្រវេសន៍ដែលមានប្រជាជន១៤.៩ភាគរយតែបានក្លាយជាម្ចាស់សហគ្រាសដល់ទៅ១៨ភាគរយនៃពាណិជ្ជកម្មក្នុងរដ្ឋ៩ សូមអានអត្ថបទ ផេមស៍ អស៊ីស ដូចខាងក្រោមនេះ :


Gnanesh Dholakia Bollywood Fashions


Gnanesh Dholakia - Bollywood Fashions


Rosemary Agbede - Unique You Salon


TheresaPark

## Massachusetts Immigrant Entrepreneurship Month

**by James Ostis**

The month-long celebration is being organized by the Massachusetts Immigrant and Refugee Advocacy Coalition and the Immigrant Learning Center and is taking place in several communities throughout the Commonwealth.

In Lowell, the economic development office is using social media to highlight local immigrant entrepreneurs. The office's facebook page features a single entrepreneur and local business each day during the celebration month, which began on October 15th.



Roger and Soben

Theresa Park, who also spoke of the importance of immigrant-run businesses at Lowell Heritage Partnership's recent Lowell: The Entrepreneurial City event, echoed those sentiments in discussing this initiative "The City of Lowell has a great history of immigrant entrepreneurs who have helped to shape the city to what it is now. Our city's character is very much defined by the different cultures that have shaped our business communities."

KhmerPostUSA was one of the local businesses highlighted. On October 21st, the City of Lowell Economic Development Office facebook page posted an image of the paper's July ribbon cutting in Downtown Lowell and provided a description of the organization.

Other local entrepreneurs and businesses highlighted so far include Ely Hsu (Tepthida Khmer), Gnanesh Dholakia (Bollywood Fashions), Rosemary Agbede (Unique You Salon), and Marcia Strauss (Lowell Naturalization and Citizenship Services). Check back at www.facebook.com/CityOfLowellEconomicDevelopmentOffice each day until November 15th to see more immigrant entrepreneurs honored.

In addition to promoting specific local business and their contributions locally, organizers of Immigrant Entrepreneurship **Continued to page 17**



# ហាងខ្មែរជួសជុលរថយន្ត

បើចង់ឱ្យរថយន្តលោកអ្នករត់បានល្អ សូមអញ្ជើញ

# Rathe´s Auto Service

State and Emission Inspaction General Repairs and Maintenance

MON-SAT, 8:30AM-5:30PM
SUN. EMERGENCY ONLY




- ជាងមានបទពិសោធន៍ជាយូរឆ្នាំ -ជួសជុលរថយន្តគ្រប់ប្រភេទ
- មានដូរប្រេង ដូរហ្វ្រាំង ដូរកង់ និងករណីជាច្រើនទៀត ។
- មានត្រួតពិនិត្យគ្រឿងម៉ាស៊ីន DIAGNOSTICS ដោយឥតគិតថ្លៃ
- មានចុះថ្លៃពិសេស ចាប់ពីខែកុម្ភៈ ២០០៨ ទៅ : - ដូរប្រេងកីរិត ៥ ក្វាត $22
- INSPECTIONS រថយន្តឆ្នាំ 96 up $49.99+ តាក់ -មានជូនប័ណ្ណពិសេសសំរាប់ដូរប្រេងចុះថ្លៃពាក់កណ្តាល នៅពេលយកមកជួសជុលអស់តម្លៃ $150.
- តម្លៃជួសជុលទូទៅ សមរម្យ ដោយទាបជាងហាងជួសជុលផ្សេងៗទៀត ។
- ប្តេជាចិត្តធ្វើជូនដោយហ្មត់ចត់ គុណភាពខ្ពស់ មិនឱ្យខុសបំណងលោកអ្នកឡើយ។ ពិសេស ជួយទៅពិនិត្យដល់កន្លែងនូវរថយន្តណាដែលខូច STARTER ឬ ធុងអាគុយអស់ភ្លើងដោយឥតគិតថ្លៃ ។ *សូមអរគុណ !*

5105 N.2ND ST., PHILADELPHIA, PA 19120. TEL : (215) 329-2418
Fax : (215) 329-2419. Rath CELL : (215) 431-6376

# ANGKOR AUTO SERVICE,INC.

## ហាងជួសជុលរថយន្ត "អង្គរ"

**Free Estimate**

**Auto Body and Maintenance**

**BODY WORKS**
**Auto glass and windshields**
**Auto Frame Straightening and Painting**



មានបទពិសោធន៍២០ឆ្នាំ ជាជាងរថយន្តមានសញ្ញាប័ត្រវាយតម្លៃការងារដោយឥតយកថ្លៃ ហើយយើងជួយសន្សំប្រាក់តម្លៃបន្ថយរបស់អិនស៊ូរិនបានផង យើងផ្តល់សេវាគ្រប់យ៉ាង :

ENGINE AND TRANSIMISSION SERVICES
State Inspection
Check Engine Light Diagnostic
Timing Belt Services
Complete Tune Up:
-Brake -Muffler -Struts
-Water Pump -A/C
-Bearing Services



From the moment you get into car accident, we will take care of you from towing to calling your insurance, and to get a rental car for you. With Angkor Auto, you can be worried free.

4835 N. 16th Street. Philadelphia, PA 19141
Tel : (215) 455-7810 / Ricky : (215) 485-1425

Continued from Page 16

## Massachusetts...

Month also want to provide information on the economic impact of immigrant entrepreneurs in the big picture. Immigrants



Marcia Strauss - Lowell Naturalization andCitizenship Services

make up 14.9 percent of the state's population, but in 2012 owned 18 percent of businesses. Immigrants start businesses at twice the rate of native-born residents. In 2012, immigrant entrepreneurs formed 61 percent of new businesses--generating $2.8 billion in annual income. For more information please visit: http://immigrantentrepreneurshipmonth2013.com

# ជល់កែវកាហ្វេរសជាតិបារីស

**ដោយៈ ខ្មែរផុសសរអា**

ព្រឹកថ្ងៃព្រហស្បតិ៍ទី២៤ខែតុលាឆ្នាំ២០១៤ នៅទីស្នាក់ការសារព័ត៌មានខ្មែរផុសសហរដ្ឋអាមេរិកអគ្គនាយកសារព័ត៌មានខ្មែរផុសស.រ.អា.ព្រមទាំងអគ្គនាយកគ្រប់គ្រង និងទីផ្សារបានទទួលស្វាគមន៍មានមតិសំណេះសំណាលជាមួយទីប្រឹក្សាក្រុង ឡូវែលអ្នកស្រីរីតា មឺស្សឺ ក្រេបរសជាតិកាហ្វេបារីស បន្ទាប់ពីវិស្សមកាលនៅអឺរ៉ុប ។

**សុបិន្ត ពិន - សំខុន ពិន - រីតា ម. មឺស្សឺ**




# អាហារនិងផ្លែឈើសម្រាប់ បំប៉នដល់សុខភាពភ្នែក



កែវភ្នែកជាវត្ថុមានតម្លៃ សំខាន់បំផុត ប្រៀបដូចនឹងជីវិតអីចឹង ។ ភ្នែកខ្សោយបណ្តាលមកពីកត្តាផ្សេងៗជាច្រើន ដូចជា ដំណេកមិនគ្រប់គ្រាន់របបអាហារខ្វះជីវជាតិបំប៉ន ការអង្គុយមុខកុំព្យូទ័រយូរពេក ។ ប្រិយមិត្តប្រាដកជាគិតថា ញ៉ាំការ៉ុតឱ្យបានច្រើន (ឆៅ ឬទឹកការ៉ុត) ជាការប្រសើរព្រោះវាដែលជួយប៉ូវដល់សុខភាពភ្នែក ។ តាមការពិតការញ៉ាំតែការ៉ុតមួយមុខនោះ វាក៏មិនអាចជួយជួយថែរក្សាភ្នែកបានដែរ ពោលគឺត្រូវមានមានអាហារផ្សេងៗទៀតមកចូលរួមផ្សំគ្នា ។ ដើម្បីឱ្យសុខភាពភ្នែករបស់ប្រិយមិត្តទាំងអស់មានសុខភាពល្អនោះ ពេលនេះផបហ្សូនអាស៊ីសូមបង្ហាញពីម្ហូបអាហារដ៏ដូចជាផ្លែឈើសម្រាប់ជួយការពារដល់សុខភាពភ្នែករបស់ប្រិយមិត្តទាំងអស់ឱ្យបានយល់ដឹង ។

ភ្នែកត្រូវការសារធាតុបំប៉នជាប្រចាំ ដូចជា វីតាមីន A, C និង E, និងសារធាតុ Zeaxanthin & Lutein ដែលមាននៅក្នុងបន្លែស្លឹកបៃតងដែលទាំងនេះជួយទប់ស្កាត់សារធាតុពុលក្នុងឈាមប៉ះពាល់ដល់ភ្នែក និងជាអង់ទីករថែរក្សាការពារភ្នែកទៀតផង ។

វីតាមីន A: មានច្រើននៅក្នុងការ៉ុត ប៉េងប៉ោះ ល្ពៅទុំ និងថ្លើមជ្រូក ។ វីតាមីន C: មានច្រើននៅក្នុងផ្លែក្រូច ស្ត្របឺរី ម្ទេសផ្លោក ឬម្ទេសហាវ៉ៃ និងផ្កាខាត់ណាបៃតង ។ វីតាមីន E: មានច្រើននៅក្នុងប្រេងបន្លែ និងគ្រាប់ធញ្ញជាតិ ។

សារធាតុ Zeaxanthin & Lutein: មានច្រើននៅក្នុងពពួកបន្លែស្លឹកបៃតង ផ្លែស្វាយ ផ្លែគីវី ត្រសក់ស្រូវ សណ្តែកបារាំង ផ្កាខាត់ណាបៃតង ពោត ទំពាំងបាយជូរក្រហម និងក្រូច ៕




Rita M. Mercier

**សូមជម្រាបសួរ!**

នាងខ្ញុំឈ្មោះ រីដា ម. មឺស្សឺ Rita M. Mercier ។ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះលោកអ្នកដែលបានគាំទ្រនាងខ្ញុំ នាថ្ងៃបោះឆ្នោតបឋម ។ នាងខ្ញុំសូមអំពាវនាវលោកអ្នកគាំទ្ររូបនាងខ្ញុំសារជាថ្មីម្តងទៀត ដើម្បីរួមចំណែកអភិវឌ្ឍក្រុងឡូវែលឱ្យកាន់តែប្រសើរឡើង ។

នៅថ្ងៃអង្គារទី ៥ ខែវិច្ឆិកា លោកអ្នកអាចគាំទ្រនាងខ្ញុំតាមរយៈការទៅបោះឆ្នោត និងបោះឆ្នោតគាំទ្រនាងខ្ញុំ ។

នាងខ្ញុំមានកិត្តិយសក្នុងការបំពេញការងារបម្រើប្រយោជន៍លោកអ្នកដូចដែលនាងខ្ញុំបានធ្វើការងារនេះអស់រយៈពេល ១៨ឆ្នាំមកហើយ ។

នាងខ្ញុំនឹងជាអ្នកនាំសារពាំនាំនូវគំនិត និងសេចក្តីព្រួយបារម្ភរបស់លោកអ្នកឱ្យសាលាក្រុងបានដឹងឮ ។ សូមផ្តល់ឱកាសដល់នាងខ្ញុំដើម្បីបានបន្តប្រឹងប្រែងបំពេញការងារជាទីប្រឹក្សាក្រុងបម្រើប្រយោជន៍ជូនលោកអ្នកដូចដែលនាងខ្ញុំបានធ្វើកន្លងមក ។

**សូមអរគុណចំពោះការជួយជ្រោមជ្រែងរបស់លោកអ្នក ។**

Rita

រីតា ម. មឺស្សឺ

## តមកពីទំព័រទី ១ មហាបាតុកម្មអហឹង្សានៅទីលាន...



សង្គ្រោះជាតិបានដឹកនាំក្រុមបាតុករជាច្រើនពាន់នាក់ដង្ហែញត្តិស្នាមមេដៃចេញពីទីលានប្រជាធិបតេយ្យឆ្ពោះទៅស្ថានទូតបារាំងដែលមានលោក សម រង្ស៊ី រង់ចាំនៅទីនោះ។

បន្ទាប់ពីដាក់ញត្តិនៅស្ថានទូតបារាំងរួចក្បួនដង្ហែបន្តទៅស្ថានទូតអង់គ្លេស និងស្ថានទូតអាមេរិក។ បន្ទាប់ដាក់ញត្តិរួចក្បួននេះវិលត្រឡប់មកជួបជុំគ្នានៅទីលានប្រជាធិបតេយ្យវិញ។

រីឯបញ្ហាសន្តិសុខសណ្តាប់ធ្នាប់មានភាពល្អប្រសើរដោយមានក្រុមសមត្ថកិច្ចជួយសម្រួលចរាចរណ៍នៅតាមផ្លូវ។

សម្រាប់ថ្ងៃបាតុកម្មចុងក្រោយ ថ្ងៃ២៥ តុលា នឹងមានការហែយកញត្តិទៅដាក់នៅស្ថានទូតអូស្ត្រាលី ស្ថានទូតរុស្ស៊ី ស្ថានទូតជប៉ុន ស្ថានទូតឥណ្ឌូនេស៊ី និងស្ថានទូតចិន។

### ២៤ តុលា ២០១៣ នៅតាមស្ថានទូត

អម្បាញ់មិញនេះ មន្ត្រីស្ថានទូតបារាំងមន្ត្រីស្ថានទូតអង់គ្លេស និងមន្ត្រីស្ថានទូតសហរដ្ឋអាមេរិកប្រចាំនៅទីក្រុងភ្នំពេញបានទទួលញត្តិ (ញត្តិស្នើសុំឱ្យប្រទេសជាហត្ថលេខីកិច្ចព្រមព្រៀងទីក្រុងប៉ារីស ជួយដោះស្រាយវិបត្តិនយោបាយនៅកម្ពុជា និងឱ្យមានការគោរពពេញលេញនូវកិច្ចព្រមព្រៀងទីក្រុងប៉ារីស ថ្ងៃទី២៣ តុលា ១៩៩១) របស់យើង។

នៅពេលយប់នៅទីលានប្រជាធិបតេយ្យមានបញ្ចាំងខ្សែភាពយន្តឯកសារ ទោះបីបក្សីក៏ត្រូវការសំបុក

### ២៤ តុលា ២០១៣ ទីលានប្រជាធិបតេយ្យ

នៅពេលនេះ ខ្ញុំ និងលោក កឹម សុខា កំពុងចូលរួមមហាបាតុកម្មអហិង្សា ថ្ងៃទី២ នៅទីលានប្រជាធិបតេយ្យ រាជធានីភ្នំពេញ។

### ២៤ តុលា ២០១៣

អម្បាញមិញនេះ នៅក្នុងមហាបាតុកម្មអហិង្សារបស់យើង បងប្អូនប្រជាពលរដ្ឋ និងព្រះសង្ឃបានឡើងសម្តែងមតិទាមទារឱ្យមានការផ្លាស់ប្តូរ។

### ចេញពីស្ថានទូតបារាំងចូលស្ថានទូតចក្រភពអង់គ្លេស

### ២៤ តុលា ២០១៣

ព្រឹកមិញនេះ យើងបានដាក់ញត្តិ (ញត្តិស្នើសុំឱ្យប្រទេសជាហត្ថលេខីកិច្ច ព្រមព្រៀងទីក្រុងប៉ារីសជួយដោះស្រាយវិបត្តិនយោបាយនៅកម្ពុជា និងឱ្យមានការគោរពពេញលេញនូវកិច្ចព្រមព្រៀងទីក្រុងប៉ារីស ថ្ងៃទី២៣ តុលា ១៩៩១) ជូនមន្ត្រីស្ថាទូតបារាំង មន្ត្រីស្ថានទូតអង់គ្លេស និងមន្ត្រីស្ថានទូតសហរដ្ឋអាមេរិកប្រចាំនៅទីក្រុងភ្នំពេញ។

### ២៤ តុលា ២០១៣

ទិដ្ឋភាពសំខាន់ៗនៃក្បួនដង្ហែញត្តិដាក់ជូនស្ថានទូតបារាំង អង់គ្លេស និងអាមេរិក ប្រចាំរាជធានីភ្នំពេញ កាលពីព្រឹកមិញនេះ។

### សង្ខេបព័ត៌មានពីមហាបាតុកម្មអហិង្សាថ្ងៃ



### ទី២៣ តុលា ២០១៣

មានបាតុករមកពីរាជធានីភ្នំពេញ និងខេត្តនានាមកចូលរួមរាប់ម៉ឺននាក់។

លោក កឹម សុខា បានថ្លែងថា បានប្រមូលស្នាមមេដៃបានជាង២លាន៣ម៉ឺន។

មន្ត្រីគណបក្សសង្គ្រោះជាតិប្រកាសថា បានប្រមូលស្នាមមេដៃអ្នកគាំទ្រនៅទូទាំងប្រទេសបានជាង២លាន៣ម៉ឺន ដើម្បីដង្ហែដាក់ញត្តិតាមស្ថានទូតនានា និងការិយាល័យអង្គការសហប្រជាជាតិប្រចាំរាជធានីភ្នំពេញ ដើម្បីទាមទារសុំឱ្យពិនិត្យសើរើឡើងវិញ អំពីភាពមិនប្រក្រតីនៃលទ្ធផលបោះឆ្នោតដែលបក្សសង្គ្រោះជាតិបានចោទថា បក្សប្រជាជន រួមគំនិតជាមួយគណៈ

កម្មាធិការជាតិរៀបចំការបោះឆ្នោតលួចបន្លំ។

ខេត្ត និងរាជធានីដែលទទួលបានស្នាមមេដៃច្រើនជាងគេមកទល់ថ្ងៃទី២៣ តុលា នេះ មាន៥ ដូចជាភ្នំពេញ កំពង់ចាម កណ្តាល កំពង់ស្ពឺ ជាដើម។





លោក កឹម សុខា អនុប្រធានបក្សសង្គ្រោះជាតិប្រកាសនៅទីលានប្រជាធិបតេយ្យនៅថ្ងៃទី២៣ តុលា ថា រាជធានីភ្នំពេញ បានជាង៤សែន ក្នុងចំណោមសន្លឹកឆ្នោតសង្គ្រោះជាតិ៣សែន៨ម៉ឺន២ពាន់សំឡេង។ ខេត្តព្រៃវែង ស្នាមមេដៃ ២សែន ក្នុងចំណោមសន្លឹកឆ្នោតជាង២សែន៨ម៉ឺន។

ខេត្តកំពង់ចាម ស្នាមមេដៃជិត៤សែន ក្នុងចំណោមសន្លឹកឆ្នោតសង្គ្រោះជាតិប្រហែល៤សែន៥ម៉ឺន៧ពាន់។ ខេត្តកំពង់ស្ពឺ ស្នាមមេដៃ១សែន១ម៉ឺន ក្នុងចំណោមសន្លឹកឆ្នោតសង្គ្រោះជាតិ ជាង១សែន ៨ម៉ឺន ៦ពាន់។ ខេត្តកណ្តាល ស្នាមមេដៃ២សែន៣ម៉ឺន ក្នុងចំណោមសន្លឹកឆ្នោតប្រហែល៣សែន៦ម៉ឺន៦ពាន់។

បន្ទាប់មកមានខេត្តជាច្រើនបានស្នាមមេដៃកម្រិតមធ្យម ដូចជា ខេត្តកំពត បន្ទាយមានជ័យ បាត់ដំបង កំពង់ឆ្នាំង កំពង់ធំ ជាដើម។

តំណាងបក្សសង្គ្រោះជាតិប្រចាំខេត្តទាំងនោះឱ្យដឹងនៅថ្ងៃទី២៣ តុលាថា មូលហេតុដែលប្រមូលស្នាមមេដៃបានតិច គឺដោយសារមូលហេតុចម្បងសំខាន់បី គឺអាជ្ញាធរមូលដ្ឋានរារាំង គំរាមកំហែងគ្រោះទឹកជំនន់ និងអ្នកគាំទ្រចំណាកស្រុកច្រើនក្រោយថ្ងៃបោះឆ្នោត។

លោក ជា ប៉ូច ប្រធានក្រុមការងារបក្សសង្គ្រោះជាតិ ខេត្តកំពត បញ្ជាក់ថា បក្សសង្គ្រោះជាតិ ខេត្តកំពត ប្រមូលស្នាមមេដៃបានជាង៨ម៉ឺន ក្នុងចំណោមសន្លឹកឆ្នោតចំនួនជាង ១សែន ២ម៉ឺន៥ពាន់នាក់។

ចំណែកខេត្តនៅភាគពាយព្យក៏មិនខុសគ្នាប៉ុន្មានដែរ។ លោក ឡុង រី ប្រធានក្រុមការងារបក្សសង្គ្រោះជាតិ ខេត្តបន្ទាយមានជ័យ ឱ្យដឹងថា ខេត្តបន្ទាយមានជ័យ មានស្នាមមេដៃជាង៤ម៉ឺន៦ពាន់ ក្នុងចំណោមសន្លឹកឆ្នោតជាង ៦ម៉ឺន ៤ពាន់ ដែលចំនួននេះនៅស្មើរ ព្រោះអាជ្ញាធរមូលដ្ឋានរារាំងគ្រោះទឹកជំនន់ និងអ្នកគាំទ្រចំណាកស្រុក។

ចំណែកខេត្តបាត់ដំបងបានស្នាមមេដៃប្រហែល៨ម៉ឺនស្នាមមេដៃ ក្នុងចំណោមសំឡេងឆ្នោតសង្គ្រោះជាតិជាង១សែន៦ម៉ឺន២ពាន់។ ខេត្តពោធិ៍សាត់ ស្នាមមេដៃ៣ម៉ឺន១ពាន់ ក្នុងចំណោមសំឡេងឆ្នោត៤ម៉ឺន៨ពាន់។ ខេត្តកំពង់ឆ្នាំង៥ម៉ឺន៤ពាន់ ក្នុងចំណោមសំឡេងឆ្នោត៩ម៉ឺន៦ពាន់។ សៀមរាប ស្នាមមេដៃជិត៩ម៉ឺន ក្នុងចំណោមសន្លឹកឆ្នោត១៤ម៉ឺន។

រីឯខេត្តកំពង់ធំ បាន៥ម៉ឺន៤ពាន់ ក្នុងចំណោមសំឡេងឆ្នោតជាង១សែន១ម៉ឺន។ ខេត្តក្រចេះបានស្នាមមេដៃជាង៤ម៉ឺន ក្នុងចំណោមសំឡេងឆ្នោតជិត៦ម៉ឺន។

ខេត្តស្វាយរៀង ស្នាមមេដៃជាង៤ម៉ឺន៣ពាន់ ក្នុងចំណោមសន្លឹកឆ្នោតជិត១សែនសំឡេង។ ខេត្តតាកែវ ស្នាមមេដៃ១៥ម៉ឺន ក្នុងចំណោមសំឡេងប្រហែល៤៥ម៉ឺន។

ក្រៅពីនេះខេត្ត៩នៅសល់បានសំឡេងតិចជាងគេ គឺខេត្តព្រះសីហនុ កោះកុង២.៥០០ រតនគិរី មណ្ឌលគិរី ព្រះវិហារ ប៉ៃលិន ឧត្តរមានជ័យ ស្ទឹងត្រែង និងខេត្តកែប មានស្នាមមេដៃត្រឹមកម្រិតខ្ទង់ពាន់ប៉ុណ្ណោះ។

មន្ត្រីបក្សសង្គ្រោះជាតិបញ្ជាក់ថា មូលហេតុដែលចំនួនស្នាមមេដៃតាមខេត្តទាំងប៉ុន្មាននេះតិចជាងគេ គឺដោយសារបក្សសង្គ្រោះជាតិមិនមានគោលការណ៍ប្រមូលស្នាមមេដៃតាមខេត្តទាំងនោះ ដែលខេត្តនីមួយៗនោះ មានកៅអីអ្នកតំណាងរាស្ត្រតែមួយ។

មានបុព្វហេតុ៣ដែលពុំអាចឱយទទួលបានស្នាមមេដៃ៣លាន៣សែនគឺ: តទៅទំព័រទី ២៨

# ដេកមិនលក់ប៉ះពាល់សុខភាព និងសម្រស់

ដេកមិនលក់ធ្វើឱ្យមានផលវិបាកច្រើនចំពោះសុខភាព និងសម្រស់។ លោកអ្នកគ្រប់រូបពិតជាចៀសមិនផុតឡើយចំពោះបញ្ហាដេកមិនលក់។ ដេកមិនលក់នេះទៀតសោតអាចបណ្តាលឱ្យមានរង្វង់ភ្នែកខ្មៅ ខូងភ្នែក ជម្ងឺឈឺក្បាល ឬវិលមុខជាដើម។ ប៉ុន្តែដេកមិនលក់មិនមែនជាជម្ងឺទេ គ្រាន់តែជាអាការរោគមួយប្រភេទដែលបណ្តាលមកពីការគិតច្រើននិងមកពីជម្ងឺផ្សេងៗ។



លោកស្រីវេជ្ជបណ្ឌិត ចក ធីតា ឯកទេសវិកលវិទ្យាបានចូលរួមបកស្រាយពីមូលហេតុដេកមិនលក់ជូនមិត្តអ្នកអាន ។

**មូលហេតុដេកមិនលក់**

អាការដេកមិនលក់កើតមកពីបញ្ហា ២យ៉ាង។



**១-បញ្ហាផ្លូវកាយ :** ជម្ងឺពាក់ព័ន្ធរាងកាយមានដូចជាឈឺសរសៃរោយឆ្អឹងខ្នងបញ្ហារោគស្ត្រីជាដើម។ ម្យ៉ាងទៀតវាអាចបណ្តាលមកពីការធ្វើការច្រើនហួសកំណត់ពុំសូវមានពេលសម្រាកដែលភាគច្រើនកើតមានលើកម្មករសំណង់និងអ្នកធ្វើការនៅរោងចក្រ។ ជួនកាលមកពីការទទួលទានអាហារច្រើនជ្រុលក៏ធ្វើឱ្យរសាប់រសល់ពិបាកដេក។

**២-បញ្ហាផ្លូវចិត្ត :** អាចកើតចេញជាច្រើនរូបភាពតាមរយៈពិបាកចិត្ត ឬស្មុគស្មាញនៅកន្លែងធ្វើការដែលជាកត្តាចម្បងសម្រាប់ការគិតច្រើនធ្វើឱ្យដេកមិនលក់។ អ្នកខ្លះទៀតកង្វល់អំពីបន្ទុកក្រុមគ្រួសារមានការមិនយល់ចិត្តគ្នា ឬដោះស្រាយមិនចេះចប់មិនចេះហើយជាដើម។ ម្យ៉ាងទៀតមូលហេតុដេកមិនលក់ក៏អាចដោយសាររឿងស្នេហាមានជម្លោះមិនសូវត្រូវរ៉ូវគ្នាជាដើមផងដែរ។

**វិធីដោះស្រាយដេកមិនលក់**

មានដំណោះស្រាយមួយចំនួនសម្រាប់លោកអ្នកជួយខ្លួនឯងឱ្យគេងលក់ស្រួល។

លោកអ្នកត្រូវរកមូលហេតុពិតប្រាកដដែលបណ្តាលឱ្យដេកមិនលក់ ដើម្បីដំណោះស្រាយទាន់ពេលវេលានិងទៅតាមរឿងនីមួយៗ។ លោកអ្នកគួរតែដោះស្រាយដោយសន្តិវិធីរម្ងាប់អារម្មណ៍ដោយខ្លួនឯង ហើយព្យាយាមសម្ងំដេកមិនត្រូវគិតពីរឿងអ្វីទាំងអស់ ដើម្បីជួយឱ្យមានអារម្មណ៍ឱ្យជ្រះថ្លាពេលក្រោកពីដំណោក។

លោកអ្នកអាចទៅពិភាក្សាជាមួយដៃគូដែលអ្នកទុកចិត្ត ដូចជាមិត្តភក្តិបងប្អូន គូសង្សារជាដើម។ តែបើបញ្ហាសំខាន់មិនអាចដោះស្រាយបាន គួរទៅជួបអ្នកជំនាញដើម្បីផ្តល់ជាយោបល់និងអាចជួយសម្រួលឱ្យដេកលក់។

**ផលវិបាកនៅពេលដេកមិនលក់**

ដេកមិនលក់មានផលវិបាកច្រើនចំពោះរាងកាយ ដូចជាស្រកទម្ងន់លឿនស្លេកស្លាំងទាំងមុខមាត់ ឬរូបរាងកាយមិនស្រស់ថ្លាជាដើម។ មិនត្រឹមតែប៉ុណ្ណោះទេ ធ្វើឱ្យរង្វង់ភ្នែកជាំខ្មៅមួយរយៈពេល **តទៅទំព័រទី ២៥**


## មជ្ឈមណ្ឌលថែទាំមនុស្សចាស់ក្រុងឡូវែល

LOWELL ELDER CARE 978-596-1111

**345 Chelmsford St. Lowell, MA 01851/ — www.lowelleldercare.com**

### អ្វីទៅជាមណ្ឌលថែទាំមនុស្សចាស់ក្រុងឡូវែល?

គឺជាលំនៅដឹកកក់ក្តៅមួយ ដែលផ្តល់សេវាមានកម្មវិធីជាក់លាក់ដល់សហគមន៍បំណង គឺគាំទ្រឲ្យមនុស្សចាស់ជរាអាចរស់នៅដោយឯករាជ្យខ្លួនឯង និងជួយឲ្យមានសុខុមាលភាពផ្នែកផ្លូវកាយ ផ្លូវចិត្ត និងផ្នែកសង្គម ។ កម្មវិធីរបស់យើងធានានូវបរិស្ថានរស់នៅមួយប្រកបដោយសុវត្ថិភាព និងមានបរិយាកាសដូចជាផ្ទះរបស់ពួកគាត់ ។

### ទីតាំងនៃមណ្ឌល

ទីតាំងអាចរកឃើញដោយងាយក្នុងអគារថ្មី ជាមួយនូវការតុបតែងរចនាបែបសិល្បៈខ្មែរយ៉ាងល្អប្រណិត ។ មានបន្ទប់ទទួលទានអាហារស្អាត និងមានពន្លឺគ្រប់គ្រាន់ បន្ទប់អានសៀវភៅ បន្ទប់កុំព្យូទ័រ បន្ទប់សម្រាក បន្ទប់មើលភាពយន្ត និងកន្លែងផ្សេងៗទៀតជាទីពេញចិត្តរបស់លោកអ្នក ។



### មណ្ឌលផ្តល់សេវាដល់មនុស្សចាស់

- មានរថយន្តជូនដំណើរទៅវិញទៅមកពីផ្ទះលោកអ្នក
- ការពិនិត្យ និងថែទាំសុខភាព
- ការព្យាបាលតាមរយៈការហាត់ប្រាណ
- កិច្ចការសង្គម (ផ្តល់ការពិគ្រោះផ្ទាល់ខ្លួន និងក្រុមគ្រួសារ)
- ម្ហូបខ្មែរក្តៅៗ និងចំណីផ្សេងៗ
- ការហាត់ប្រាណសំរាប់សុខភាពរាងកាយ
- កម្មវិធីសិល្បៈ និងតន្ត្រី
- ការអប់រំពីសុខភាព
- ការពិភាក្សាលើព្រឹត្តិការបច្ចុប្បន្ន (និងការសំណេះសំណាលគ្នា)
- សកម្មភាព និងដំណើរកំសាន្តក្រៅមណ្ឌល

### Our Services

- Door-to-Door Transportation
- Medical Care and Support
- Physical Therapy
- Social Worker
- Khmer Meals and Snacks
- Adaptive Physical Exercise
- Music Programs
- Health Educational Seminars
- Discussions on current events, (and times of reminiscing)
- Outdoor Field Trips

**សូមហៅលេខទូរស័ព្ទ (978) 596-1111**

# ព្រេងនិទាន ធ្មប់

**ដោយ : រីឆាដ ហូវ**

**ប្រែសម្រួលជាភាសាខ្មែរដោយ : សុខា**

ភាគច្រើននៃអ្នកទស្សនាដែលបានធ្វើទស្សនកិច្ចមកកាន់ផ្នូរកប់ខ្មោចឡូវែល ឬឡូវែលសេមិត ធើរី ( Lowell Cemetery) តែងតែធ្វើគារវកិច្ច ចំពោះអ្នកផ្នូរអ្នកទាំងឡាយដែលទទួលមរណភាពដោយសារជម្ងឺ ។ ឯអ្នកខ្លះទៀតមកទីនេះ ដើម្បីកំសាន្តនូវទិដ្ឋភាព និងធម្មជាតិស្រស់ត្រកាល ឬជួនកាលក៏គេបំណងនឹងមកមើលចម្លាក់អស្ចារ្យនានាដែលឆ្លាក់លើផ្នូរ ។ ជាមួយគ្នានោះមួយចំនួនតូចនៃអ្នកដែលមកទស្សនាផ្នូរកប់ខ្មោច គឺដើម្បីស្រាវជ្រាវពីរឿងរ៉ាវទាក់ទងនឹងធ្មប់ ។

ប្រជាជនដែលជឿលើអបិយជំនឿទាំងអស់នោះ បានតំណាលតៗគ្នាថា រូបចម្លាក់ធ្វើពីស្ពាន់ឆ្លាក់ឧទ្ទិសដល់វិញ្ញាណក្ខន្ធអ្នកស្រីខ្លារ៉ា បូននីយ៍ (Clara Bonney) មានអំណាចអភិនិហា ដែលគេជឿថា ថ្ងៃណាមួយរូបចម្លាក់នោះនឹងទម្លាក់ស្បៃរបស់នាងនៅត្រឹមកដៃ ហើយនាងក៏នឹងរស់រានមានជីវិតឡើងវិញ រួចក៏លងអ្នកភូមិ ។ ដូច្នេះអ្នកដែលជឿដំណាលរឿងនេះ តែងបរិច្ចាគទុករបស់មានតម្លៃគ្រឿងអលង្ការ ឬកាក់ទ្រព្យរបស់ខ្លួនជួនកាលមានទាំងបាល់អោបទៀតផង នៅរូបសំណាកនោះ ព្រោះដើម្បីសុំការប្រណីពីរូបចម្លាក់នោះ ។ យ៉ាងណាមិញកន្លងមកពុំទាន់មាននរណាម្នាក់អាចអះអាងថាបានឃើញរូបចម្លាក់នោះមានចលនានៅឡើយទេ ។

រូបចម្លាក់នេះបង្ហាញអត្តសញ្ញាណផ្នូររបស់អ្នកស្រី ខ្លារ៉ា បូននីយ៍ (Clara Bonney) ដែលបានស្លាប់នៅឡូវែលឆ្នាំ១៨៩៤ ដោយសារជម្ងឺរបេងនៅអាយុ៣៩ឆ្នាំ ។ នាងបានរៀបការជាមួយចៅក្រមឆាលស៍ លីលលី (Charles S. Lilley) ហើយនាងជាកូនស្រីរបស់ចៅ តទៅទំព័រទី ២២



Richard Howe Jr.

# The Legend of the Witch

**by Richard Howe**

Many who visit Lowell Cemetery come to pay their respects to deceased relatives. Others come to enjoy the beautiful, natural setting or the wonderful sculptures that mark some of the graves. A few come in search of a witch.

People who believe in those things say that the bronze figure that marks the grave of Clara Bonney has supernatural powers and that one day, the figure's dress will drop down to her waist and she will come to life and haunt the community. Those who believe the legend leave tokens like coins or jewelry or even baseballs to gain the favor of the figure but no one has ever seen her move.

This statue marks the burial place of Clara Bonney who died in Lowell in 1894 of tuberculosis at the age of 39. She was married to Judge Charles S. Lilley and was the only child of Judge Arthur Bonney and his wife Emma. After she died her family hired the famous artist Frank Elwell to create this monument for Clara. Elwell called the sculpture "New Life."

No one knows how this statue became connected with the legend of the witch. It seems unfair to Clara Bonney who lived a good life that was cut short by a deadly disease. But throughout the year and especially on Halloween, many people visit this monument and wonder about its special powers.

Lowell Cemetery is located at 77 Knapp Avenue in Lowell, right next to Shedd Park. It was founded in 1841 and is still an active cemetery that is open to anyone regardless of religion, race or national origin. For more information, go to www.lowellcemetery.com.



Bonney

AccuCare

កម្មវិធីជំនួយផ្នែកថែទាំសុខភាពតាមផ្ទះរដ្ឋ

Homecare Agency
Group Adult Foster Care Program (GAFC)
MassHealth

ជាសេវាមានគុណភាពខ្ពស់ និងទុកចិត្តបាន
បុគ្គលិកមានសណ្ដានចិត្តល្អ និងធ្វើការតាមវិជ្ជាជីវៈ
អ្នកគ្រប់គ្រង និងបុគ្គលិកនិយាយភាសាខ្មែរ



Compassionate Care & Reliable
Professional & Cultural Sensitive
Management & Staffs speak Khmer

កម្មវិធី Group Adult Foster Care (GAFC) គឺជាដំណោះស្រាយល្អបំផុតសំរាប់ចាស់ៗ ខ្មែរយើង ដែលមានប ញ្ហារាំរ៉ៃផ្នែកសុខភាព ឬជរាហើយមិនចង់ ចាកចេញពីលំនៅដ្ឋានខ្លួនឯង ឬមិនចង់បែកពីក្រុមគ្រួសារដែលបានរស់នៅជាមួយគ្នាជាយូរមកហើយ ។ យើងអាចជួយអោយជីវិតលោកអ្នកកាន់តែប្រសើរឡើង តាមរយៈការផ្ដល់នូវសេវាថែទាំសុខភាពមួយទល់មួយដល់ផ្ទះលោកអ្នកតែម្ដង ។

Accucare Homecare Agency is the perfect solution for seniors and others who are not ready to leave their home for an institutional setting or live with reltives because of illness or chronic conditions. We improve your life by providing one-on-one compassionate senior care in the comfort of your own home.

ដើម្បីអាចចូលរួមក្នុងកម្មវិធីនេះបានលោកអ្នកត្រូវមានលក្ខណៈដូចខាងក្រោម :
To be eligibled for GAFC you must:
-រស់នៅផ្ទះរដ្ឋ (live in subsidized or public housing)
-អាយុ ២២ ឆ្នាំឡើងទៅ (age 22 years and older)
-មាស់ហែលស្ទេនដា (eligible for Masshealth Standard)
-ត្រូវការជំនួយក្នុងការរស់នៅប្រចាំថ្ងៃយ៉ាងហោចណាស់មួយដូចជា មុជទឹក ស្លៀកពាក់ ពេលប្រើបន្ទប់ទឹក ចំអិនអាហារ ឬ ពេលដើរ (need daily assistance with one or more personal care tasks such as bathing, dressing, toileting, meal preparation and/or moving)
-មានការអនុញ្ញាតពីគ្រូពេទ្យផ្ទាល់ខ្លួនអ្នក (have physician statement of your condition)
-ត្រូវបានវាយតំលៃផ្នែកសុខភាព និងការអនុម័តយល់ព្រមពីកម្មវិធី (be screened and approved for the program )

ផលប្រយោជន៍ទទួលបាន :
Benefits you will get:
-ការថែទាំផ្ទាល់ខ្លួនមួយទល់មួយក្នុងផ្ទះរបស់អ្នករាល់ថ្ងៃមួយថ្ងៃមួយម៉ោងលើការរស់នៅប្រចាំថ្ងៃ (personal care service in your home, up to one hour of service each day)
-ជំនួយលើការគ្រប់គ្រងថ្នាំសង្កូវអ្នក (Medication Managemant)
-ផែនការថែរទាំសុខភាពផ្ទាល់ខ្លួនមួយ ដែលធ្វើឡើងដោយគ្រូពេទ្យ និងខេសមានីយើ (an individual care plan developed by a registered nurse and case manager)
-វាយតំលៃលើសេចក្ដីត្រូវការជាប្រចាំជាបន្តបន្ទាប់ (ongoing monitoring of needs)
-សមាជិកអាចទាក់ទងមក ២៤ម៉ោង (24-hour access to services)

ត្រូវការជ្រើសរើសបុគ្គលិកធ្វើការ PCA/ HHA needed for Lowell, Lynn, Revere, and Boston

ដើម្បីចុះឈ្មោះសូមទាក់ទងមក
To register, please contact:



អ៊ុក តុលាយុទ្ធ ឡូវែល
Tolayuth Ok: Lowell
Tel: (978)735-4955, Fax: (978) 735-4956
Office: 144 Merrimack St., Suite 404, Lowell, MA 01852



ពិន ឆាវ៉ាន លីន រីវៀរ បូស្តុន
Chhavan Pin: Lynn, Revere, Boston
Tel:(617)783-7177, Fax: (617) 783-7188
Office: 214 Lincoln St., Suite 200, Allston, MA 02134

តមកពីទំព័រទី ២៦
## វត្តសុរិយារង្សីនៅហ៊ីឡាដែលហៀរ...

មិនបើកអង្គប្រជុំអាណាទៅបើកអង្គប្រជុំនោះធ្វើអីកើត, ហើយលោកនៅតែបន្តធ្វើទៅលើការព្រមានរបស់អាជ្ញាធរដែនដីតទៅទៀតយ៉ាងគឃ្លើម (នេះបើតាមការដែលសមាជិកក្នុងគណកម្មការចាស់រអ៊ូជាហូរហែមក)។ អស់លោកដែលគេរអ៊ូរទំដាក់នោះគឺលោកគ្រូជិននឹងក្មួយអាង, សុទ្ធតែជាមនុស្សដែលខ្ញុំមានការរាប់អានខ្ពស់តែខ្ញុំសុខចិត្តចុះហត្ថលេខាទំលាក់ដោយពុំចង់ឱ្យគាត់នៅក្នុងដំណែងដើម្បីប្រព្រឹត្តិខុសតទៅទៀតតែប៉ុណ្ណោះ, មិនមែនដោយសារស្អប់អស់លោកទេ។ ឱ្យអ្នកថ្មីគេឡើងកាន់កាប់ដឹកនាំជំនួសម្តងទៅចុះ,ដូចលោកក្មួយ ង៉ោ ថាច់ ង៉ុក ជាដើម។ មិនស្មានថា លោកគ្រូ ជិន និងក្មួយអាងបានទៅនៅក្នុងគណកម្មការជាប់ឆ្នោតទៅវិញសោះ អាស្រ័យហេតុនេះខ្ញុំសុំប្រកាសថ្ងៃនេះ (ថ្ងៃទី១ ខែតុលាឆ្នាំ២០១៣) ខ្ញុំមិនគាំទ្រលទ្ធផលការបោះឆ្នោតនៃគណកម្មការដែលមានសិទ្ធកាន់កាប់, ចាត់ចែងការងារនៃវត្តសុរិយរង្សីនេះតទៅទៀតទេ.ខ្ញុំបានទទួលស្គាល់ពីមុននោះដោយការភ័ន្តច្រឡំ។ ម្យ៉ាងទៀតខ្ញុំសុំអង្វរចិត្តអស់លោកប្រព្រឹត្តខុសធ្វើឱ្យសហគមន៍យើងខាតបង់ដោយសារការចរចេសរឹងរុះរបស់ខ្លួននោះត្រូវមានភាពក្លាហានដោយសំណងជាប្រាក់កាស ឬសារភាពទោសកំហុសដែលខ្លួនបានចរចេសនោះតាមការយល់ឃើញរបស់សមោហភាព។ សុំមេត្តាកុំគេចវេះ, រត់ទៅលាក់បាំងកំហុសរបស់ខ្លួនដោយវិធីនេះ ឬវិធីនោះ។ ការមិនចេះឃើញនឹងស្គាល់កំហុសរបស់ខ្លួននេះធ្វើឱ្យប្រទេសខ្មែរយើងអន្តរាយច្រើនហួសនឹងរាប់បានទៅហើយ។ សុំមេត្តារៀនសំឡឹងកំហុសរបស់ខ្លួនវិញ ដើម្បីកសាងគ្រួសារល្អ, សហគមន៍ស្អាតស្អំ,សង្គមប្រសើរនឹងជាតិមួយដ៏ឧត្តមរង់រឿង។ យើងមកដល់ប្រទេសគេមានច្បាប់ត្រូវធ្វើអ្វីៗទៅតាមច្បាប់ ដូចលក្ខន្តិកសមាគមជាដើមក៏អស់លោកត្រូវគិតគូរឱ្យគ្រប់ជ្រុងជ្រោយកុំឱ្យមានធ្លោះធ្លោយដូចមុនទៀត។ ក្រុមឈ្នះឆ្នោតបានធ្វើមក ហើយនោះមិនខុសទេ ខុសពីលក្ខន្តិក ទេតើ! នោះមិនទាន់សូវសំខាន់ទេ បើយើងគិតទៅលើរឿងបោះឆ្នោតសាកលរបស់ប្រទេសកម្ពុជាឆ្នាំ១៩៩៣វិញ: លោកព្រឹទ្ធាចារ្យ សឺន សាន រៀបចំធ្វើពហិការមិនចូលរួមការបោះឆ្នោតដោយសារខ្មែរកម្ពុជាក្រោមនៅព្រះរាជាណាចក្រកម្ពុជាពុំមានសិទ្ធបោះឆ្នោតកុំតែតំណាងអង្គការសហប្រជាជាតិទៅអង្វរសុំឱ្យលោកបោះបង់គំនិតនោះចោល ទើបលោកព្រមចេញទទួលស្គាល់ការបោះឆ្នោតនោះហើយក៏ការបោះឆ្នោតឆ្នាំ១៩៩៣បានប្រព្រឹត្តិទៅយ៉ាងរលូនទៅ ។ សួរថា តើព្រឹទ្ធាចារ្យ សឺន សាន ធ្វើពហិការបានប្រយោជន៍អី? លោកគ្រាន់តែបានប្រជាពលរដ្ឋខ្មែរកម្ពុជាក្រោមដឹងគុណលោកថា លោកតស៊ូដើម្បីពលរដ្ឋខ្មែរក្រោមសុខចិត្តបាត់តំណែងរបស់លោកជាតំណាងរាស្ត្រនឹងតំណែងជាមេបក្សផង។ ត្រូវជ្រាបថា លោកជាប្រធានគណបក្សមួយ បើបាត់តំណែងនោះលោកគ្មានបានធ្វើអីតទៅទៀតសម្រាប់ខ្មែរកម្ពុជាក្រោម ឬសម្រាប់ខ្មែរទូទៅបានទៀតទេ តែស្តាយត្រង់ពេលលោកបានចូលសភាហើយម្តេចក៏លោកមិនតវ៉ាឱ្យខ្មែរកម្ពុជាក្រោមដែលជាពលរដ្ឋខ្មែរដែរនោះ ទទួលបានសិទ្ធបោះឆ្នោតដូចពលរដ្ឋខ្មែរដទៃទៀតវិញផង? លោកនៅស្ងៀម ឬក៏ភ្លេចទុកឱ្យគ្នាមានការលំបាករហូតដល់សព្វថ្ងៃ។ ម្យ៉ាងវិញទៀតកាលកំពុងប្រជុំនៅឯសន្និសិទ្ធទីក្រុងប៉ារីសព្រឹទ្ធាចារ្យ សឺន សាន នឹងឯកឧត្តម ថាច់ រ៉េង រវល់ធ្វើអីមិនជួយការពារផលប្រយោជន៍ពលរដ្ឋខ្មែរកម្ពុជាក្រោមនៅប្រទេសកម្ពុជាផង ទុកឱ្យគេ "ធីប៉" ប្រជាពលរដ្ឋនេះនៅក្រៅប្រព័ន្ធបោះឆ្នោតទៅកើតរហូតដល់សព្វថ្ងៃ ដោយគេយល់ថា ពួកខ្មែរកម្ពុជាក្រោមដឹងពុតត្បុតយួនច្បាស់.ប្រាកដជាមានចំណេញច្រើនទៅលើគណបក្សលោកតា សឺន សាន និងលទ្ធិប្រជាធិបតេយ្យនៅកម្ពុជា : គេមើលឃើញឆ្ងាយទើបគេបានបិទច្រកជាស្រេចមិនឱ្យពលរដ្ឋខ្មែរកម្ពុជាក្រោមនៅប្រទេសកម្ពុជាមានសិទ្ធបោះឆ្នោតតាំងពីពេលសន្និសិទ្ធស្វែងរកសន្តិភាពនៅទីក្រុងប៉ារីសកំពុងប្រព្រឹត្តទៅនៅថ្ងៃ២៣តុលា ឆ្នាំ១៩៩១ ម្លេះនៅក្រោមក្បៀកបុគ្គលខ្មែរកម្ពុជាក្រោមដ៏សំខាន់ពីររូបដែលបានចូលរួមនឹងគេដែរនោះ,ពុំបានស្វែងយល់ពីបញ្ហាគេបិទច្រកនៃប្រព័ន្ធបោះឆ្នោតរបស់ពលរដ្ឋអភ័ព្វខ្មែរកម្ពុជាក្រោមនោះឡើយនោះ គឺលោកតា សឺន សាន និងឯកឧត្តម ថាច់ រ៉េង នេះឯង,រួចក៏គ្មាននរណាដឹងរឿងនេះទាល់តែសោះនឹងក៏គ្មានខ្មែរក្រោមណាម្នាក់ដេញដោលសួរលោកទាំងពីរថា តើលោកទាំងពីររវល់ធ្វើអីពេលគេប្រជុំជជែកពីរបៀបវារៈនៅសន្និសីទនេះថា ខ្មែរចំពូកណាខ្លះដែលអាចបោះឆ្នោតបាននៅកម្ពុជាក្នុងអនាគត។ រួចបានចូលសភា ហើយក្នុងនាមនៃមេបក្សរណសិរ្សសេរីព្រះពុទ្ធសាសនាទៀត ហើយបានដឹងថា ពលរដ្ឋខ្មែរកម្ពុជាក្រោមគ្មានសិទ្ធបោះឆ្នោតនឹងគេទេ ម៉េចក៏ លោកតា សឺន សាន នៅសម្ងំស្ងៀមមិនតវ៉ា ឬស្នើរឱ្យព្រៀងច្បាប់ស្តីពីរឿងនេះរហូតដល់លោកទាំងពីរចែកឋានទាំងអស់គ្នាទៅ!!។ រំលឹករឿងនេះមិនមែនចង់ឱ្យលោកទាំងពីររស់ឡើងវិញ ដើម្បីតវ៉ាអីទៀតនោះទេ តែចង់ឱ្យគ្នាយើងអ្នកជំនាន់ក្រោយនេះចេះសង្កេតកំហុស ឬប្រហោងរបស់ស្ទៀតប្រដាល់របស់យើង ដូចជាការដែលក្រុមគណកម្មការទាំងពីរនៃវត្តសុរិយរង្សីមិនចុះសម្រុង

**តទៅលេខក្រោយ**



## តមកពីទំព័រទី ១៣ ថៃ និងជប៉ុន ផ្តល់ជំនួយមនុស្សធម៌ដល់ជន...

បានលើកឡើងកាលពីម្សិលមិញថា ក្រុមប្រឹក្សាពាណិជ្ជកម្មកម្ពុជា-ថៃ ស្ថានទូតថៃ និងសមាជិកនៃសហគមន៍ថៃក្នុងប្រទេសកម្ពុជាក៏បានផ្តល់ជំនួយជាសម្ភារបើគិតជាទឹកប្រាក់មានចំនួន២០.០០០ដុល្លារ ទៅឱ្យកាកបាទក្រហមកម្ពុជាផងដែរ។

លោកស្រីមានប្រសាសន៍ថា "យើងបានរៀបចំការប្រជុំមួយ ហើយយើងបាននិយាយពីបញ្ហាទឹកជំនន់ ហើយសម្រេចថា នឹងសហការគ្នារៃអង្គាសប្រាក់ដើម្បីទិញសម្ភារ និងជំនួយ"។ លោកស្រីបន្ថែមថា ជំនួយភាគច្រើនបានមកពីសមាជិកចំនួន៦៣រូបមកពីក្រុមប្រឹក្សាពាណិជ្ជកម្មកម្ពុជា-ថៃ។ ពួកគេភាគច្រើនបានផ្តល់ជំនួយជាផលិតផលដែលខ្លួនបានផលិតមានដូចជា អង្ករ និងអាហារកំប៉ុងជាដើម។

លោកស្រីថ្លែងថា "យើងបានរៀបចំកញ្ចប់ជំនួយចំនួន៧៥០កញ្ចប់ ដែលរួមមានទឹកសុទ្ធអង្ករ និងស្បៀងអាហារ។ យើងនឹងប្រគល់ជំនួយទាំងនេះទៅឱ្យកាកបាទក្រហមកម្ពុជានៅព្រឹកនេះ"។ លោកស្រីបន្ថែមថា ស្បៀងអាហារទាំងនេះនឹងត្រូវចែកចាយដោយកាកបាទក្រហមនៅខេត្តកំពង់ចាម ក្នុងថ្ងៃអាទិត្យ។

លោក ញឹម វណ្ណដា បានមានប្រសាសន៍ថា ទឹកជំនន់បានចាប់ផ្តើមស្រកទៅវិញហើយ នៅក្នុងខេត្តជាច្រើន ហើយគ្មានរបាយការណ៍ថ្មីពីអ្នកស្លាប់ដោយសារទឹកជំនន់ទេ ក្នុងប៉ុន្មានថ្ងៃកន្លងមកនេះ ដោយធ្វើឱ្យតួលេខនៃអ្នកស្លាប់នៅត្រឹម ១៦៨នាក់។

***ប្រែសម្រួលដោយ ស៊ា ស៊ុយឈាង***

## តមកពីទំព័រទី ១៣ ធនាគារចិនចុះហត្ថលេខាលើកិច្ចព្រម...

ដូចជាផ្លូវថ្នល់ ស្ពាន ប្រព័ន្ធ ស្រោចស្រព កំពង់ផែ និងវិស័យថាមពលអគ្គិសនី"។

នៅក្នុងពិធីនោះ លោក គាត ឈន់ ក៏បានថ្លែងអំណរគុណសម្រាប់ការចុះកិច្ចព្រមព្រៀងជាមួយសហគ្រាសចិននានា ក្នុងគោលបំណងជួយផ្តល់មូលនិធិសម្រាប់បង្កើតរោងចក្រចម្រាញ់ប្រេងក្នុងខេត្តកំពត និងសម្រាប់ជួយប្រទេសកម្ពុជាឱ្យសម្រេចបាននូវគោលដៅនាំអង្ករចេញរបស់ខ្លួនផងដែរ។ លោក គាត ឈន់ បានមានប្រសាសន៍បន្ថែមទៀតថា "ខ្ញុំសូមអបអរសាទរ ចំពោះការចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា រវាងធនាគារអភិវឌ្ឍន៍ជនបទនៃព្រះរាជាណាចក្រកម្ពុជា និងធនាគារចិន និហ័រណ-អាហ័រណដែលបានផ្តល់ហិរញ្ញប្បទានជាសាច់ប្រាក់ដោយមិនចាំបាច់មានលក្ខខណ្ឌធានាមូលធនពីរដ្ឋដល់ធនាគារអភិវឌ្ឍន៍ជនបទ ក្នុងគោលបំណងសម្រេចឱ្យបាននូវផែនការនាំអង្ករចេញមួយលានតោន ចាប់តាំងពីឆ្នាំ២០១៥"។

ប្រាក់កម្ចីសម្បទានទទួលបានពីសមភាគីចិន បានរងសំឡេងរិះគន់ពីសំណាក់សហគមន៍ផ្តល់ជំនួយនានា ក្នុងរយៈពេលមួយទសវត្សរ៍កន្លងមកនេះ ដោយលើកឡើងថា ប្រាក់កម្ចី ទាំងនេះធ្វើឱ្យមានការបំប៉ោងគម្រោងអភិវឌ្ឍន៍ដែលមានការធានាឱ្យមានតម្លាភាពតិចតួច ឬក៏មិនមានតែម្តង។ លើសពីនេះទៀត ខណៈដែលប្រាក់កម្ចីសម្បទានត្រូវបានផ្តល់ឱ្យក្នុងលក្ខខណ្ឌអំណោយផលជាងអត្រាការប្រាក់ទីផ្សារអ្នករិះគន់លើកឡើងផងដែរថា ប្រាក់កម្ចីសម្បទានទទួលបានពីប្រទេសចិន នៅតែមានអត្រាការប្រាក់ខ្ពស់ជាងប្រាក់កម្ចីទទួលបានពីស្ថាប័នអភិវឌ្ឍន៍អន្តរជាតិ។

លោក សុន គន្ធរ ប្រធានធនាគារអភិវឌ្ឍន៍ជនបទបានលើកឡើងថា ប្រាក់កម្ចីថ្មីទទួលបានពីធនាគារនិហ័រណ-អាហ័រណនេះ "មានអត្រាការប្រាក់ខ្ពស់ជាងអត្រាការប្រាក់ ប្រាក់ កម្ចីសម្បទានមួយ ប៉ុន្តែទាបជាងអត្រាការប្រាក់ ប្រាក់កម្ចីពាណិជ្ជកម្ម។ វាមានអត្រាប្រហែល៤ទៅ៦ភាគរយ"។

លោក គាត ឈន់ បានលើកឡើងបន្ថែមទៀតថា រដ្ឋាភិបាលនឹងធ្វើឱ្យប្រាកដថា ប្រាក់កម្ចីថ្មីបំផុតដែលទទួលពីសមភាគីចិនត្រូវបានគ្រប់គ្រងឱ្យស្របតាមគោលការណ៍អភិបាលកិច្ចល្អ។ លោកមានប្រសាសន៍ថា "ខ្ញុំនឹងធានាថា រាជរដ្ឋាភិបាលកម្ពុជានឹងប្រើប្រាស់ហិរញ្ញប្បទានកិច្ចសហប្រតិបត្តិការនេះ ប្រកបដោយតម្លាភាព និងគណនេយ្យភាព ដើម្បីអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមនៃប្រទេសកម្ពុជា"៕

## តមកពីទំព័រទី ២០ ព្រេងនិទាន ឆ្មប់

ក្រុមអាច្ស៊ីបូននីយ៍ ដែលមានភរិយាឈ្មោះ អេម ម៉ា។ បន្ទាប់ពីខ្លារ៉ា បូននីយ៍ (Clara Bonney) បានទទួលអនិច្ចកម្មទៅក្រុមគ្រួសាររបស់នាងបានស្ថាបត្យករល្បីល្បាញមួយរូបឈ្មោះ ហ្វ្រេងឃ្លីន អែលវែល ដើម្បីបង្កើតរូបសំណាកនេះឡើងឧទ្ទិសដល់ខ្លារ៉ា បូននីយ៍ (Clara Bonney)។ ស្ថាបត្យករអែលវែលបានដាក់ឈ្មោះចម្លាក់នោះថា ជីវិតថ្មី។

គ្មាននរណាម្នាក់បានដឹងថា រូបសំណាកនេះក្លាយទៅមានទំនាក់ទំនងនឹងដំណាលកថាពាក់ពន្ធនឹងឆ្មប់ដោយរបៀបណានៅឡើយទេ ។ ទំនងដូចជាអយុត្តិធម៌ចំពោះអ្នកស្រីខ្លារ៉ា បូននីយ៍ (Clara Bonney) ដែលមិនមានឱកាសរស់នៅក្នុងជីវិតរីករាយឱ្យបានយូរអង្វែង។ ប៉ុន្តែច្រើនឆ្នាំកន្លងទៅជាពិសេសនៅពេលប្រារព្ធហាឡូវីន (Halloween) ប្រជាជនជាច្រើនតែងតែធ្វើទស្សនកិច្ចរូបសំណាកនោះ ហើយតែងតែឆ្ងល់ពីអំណាចពិសេសរបស់រូបសំណាកនេះ។

ផ្នូរកប់ខ្មោចឡូវែល ឬឡូវែលសេមិតធីរី ៕ Lowell Cemetery) ស្ថិតនៅវិថី៧៧ Knapp Avenue ក្រុង Lowell នៅជាប់នឹងសួនស្សិដដ៏ (Shedd Park)។ ផ្នូរកប់ខ្មោចឡូវែល ឬឡូវែលសេមិតធីរី (Lowell Cemetery) ត្រូវបានបង្កើតឡើងនៅឆ្នាំ១៨៤១ ហើយនៅតែជាផ្នូរកាប់ខ្មោចមានការប្រព្រឹត្តទៅជាសកម្មនឹងបើកស្វាគមន៍សាធារណជនមិនប្រកាន់ជាតិសាសន៍ពណ៌សម្បុរ ឬដើមកំណើតឡើយ។ សម្រាប់ពតិមានបន្ថែម សូមចូលកាន់គេហទំព័រ www.lowellcemetery.com./

Golden Video Shop Providence
មានលក់ថាសចម្រៀង និងខ្សែវីដេអូ-ខ្មែរ-ចិន-ថៃ (401)-808-9336
VM LAPTOPS CENTER
- VANNAK MOEUN (Manager)
មានជួសជុល-ទិញ និងលក់"ឡាប់តុប"គ្រប់យ៉ាង
301 Reservoie Ave. Providence RI 02907

ហ្វ្រីជិនខ្មែរវីដេអូ
មានជួលនិងលក់កុនចិន-ថៃ-ខ្មែរ-តុក្កតាគ្រប់ប្រភេទមានចម្រៀង
សម័យវីដេអូ ខារ៉ាអូខេថ្មីៗ
742 Potters Avenue
Providence, RI 02907 ទូរស័ព្ទ : (401) 787 6663

ការិយាល័យច្បាប់នៃមេធាវីម៉ារីណា ស្សេបផល្គី ភី ស៊ី
LAW OFFICES OF MARINA SHEPLSKY,P.C.
Attorneys at Law
Member of NY and NJ Bar
មេធាវីច្បាប់
សមាជិកគណមេធាវីរដ្ឋញូយ៉ក និង ជឺស៊ី
2306 Coney Island Avenue, 2nd Floor
Brooklyn, NY 11223
E-Mail: marina@shepelskylaw.com
Tel : (718) 769-6352
Fax: (718) 769-2391

REPRESENTING IMMIGRATION CLIENTS IN ALL 50 STATES

ការិយាល័យច្បាប់នៃមេធាវីម៉ារីណា សៀបផលស្គី អាចជួយលោកអ្នកក្នុងផ្នែកអន្តោប្រវេសន៍ដូចខាងក្រោម :

- គ្រីនខាត តាមរយៈការរៀបអាពាហ៍ពិពាហ៍ និងសមាជិកគ្រួសារ
- សេចក្តីអនុញ្ញាតក្នុងនាមគូដណ្តឹង
- សេចក្តីអនុញ្ញាតក្នុងនាមគ្រួសារ
- អ្នកដែលមិនទាន់ចូលសញ្ជាតិ ហើយប្រឈមនឹងការបញ្ជូនត្រលប់ទៅស្រុកវិញ
- សេចក្តីកោះហៅពីតុលាការអន្តោប្រវេសន៍

- ការចាប់ខ្លួន និងដកហូតអន្តោប្រវេសន៍ (អន្តោប្រវេសន៍ពន្ធនាគារ)
- ជនភៀសខ្លួន និងការសុំអនុញ្ញាតជ្រកកោន
- ភាពជាពលរដ្ឋនៃសហរដ្ឋអាមេរិក និងការសុំចូលសញ្ជាតិ
- ការសម្ភាសជាមួយ យូ អេស ស៊ី អាយ អេស
- ទិដ្ឋាការធ្វើការ និងជំនួញ

- ទិដ្ឋាការសម្រាប់វិនិយោគិន
- ទិដ្ឋាការស្នាក់នៅរយៈពេលខ្លី ឬបណ្តោះអាសន្ន
- ការសុំសិទ្ធិញ្ញើមជាអន្តរជាតិ
- ការប្តឹងឧទ្ធរណ៍
- ការតវ៉ា ដើម្បីបើកសវនាការក្តីដែលបានបិទរួចហើយ


Marina Shepelsky, Esq.

បំពេញសុបិន្តអាមេរិកលោកអ្នក
ឱ្យក្លាយជាការពិតតំណាងកូនក្តីទូទាំង៥០រដ្ឋ
រាល់សេចក្តីត្រូវការផ្នែកច្បាប់អន្តោប្រវេសន៍ សូមចូលកាន់គេហទំព័រ WWW.E-US-VISA.COM
សម្រាប់ព័ត៌មានទូទៅនៃការិយាល័យច្បាប់ សូមចូលគេហទំព័រ WWW.SHEPELSKYLAW.COM
សម្រាប់ភាសាខ្មែរ សូមទូរស័ព្ទទៅកាន់សាខានៅមែនហាថិន លេខទូរស័ព្ទ 212-219-2299

# វិធីព្យាបាលជម្ងឺរលាកអាងត្រគាកស្ត្រី

ដើម្បីព្យាបាលជម្ងឺនេះអ្នកជម្ងឺត្រូវសម្រាកនៅមន្ទីរពេទ្យ ដើម្បីឱ្យគ្រូពេទ្យតាមដានដោយដាក់ថ្នាំសម្លាប់មេរោគខ្លាំង ហើយប្រើរយៈពេលយូរ។

នៅក្នុងករណីធ្ងន់ធ្ងរក្រោយពេលព្យាបាលដោយថ្នាំមិនទទួលបាននូវជោគជ័យគ្រូពេទ្យអាចព្យាបាល ដោយវិធីវះកាត់ដៃស្បូន ឬវះកាត់ស្បូនទាំងមូលតែម្តង។

បើក្នុងករណីអ្នកជម្ងឺមិនធ្វើការព្យាបាលទេ នោះចំនួន៤៥ទៅ៨៥ភាគរយនៃស្ត្រីដែលកើតជម្ងឺរលាកអាងត្រគាកអាចក្លាយទៅជាអ្នកខ្វះសមត្ថភាពក្នុងការបន្តពូជ ។ មិនតែប៉ុណ្ណោះអាចបង្កើនឱ្យមានគ្រោះថ្នាក់មានគភ៌នៅក្រៅស្បូន រហូតដល់ពី៧ទៅ១០ដងខ្ពស់ជាងស្ត្រីធម្មតា។

វិធីការពារជម្ងឺរលាកអាងត្រគាកស្ត្រី ដើម្បីការពារកុំឱ្យមានជម្ងឺនេះស្ត្រីគ្រប់រូបត្រូវធ្វើអនាម័យទ្វារមាសឱ្យបានទៀងទាត់។ ត្រូវជ្រើសរើសវិធីរួមភេទដែលមានសុវត្ថិភាព។ ប្រសិនបើស្ត្រីមានដៃគូរួមភេទច្រើនត្រូវមានការប្រុងប្រយ័ត្នការពារឱ្យបានល្អក្រោយពេលរួមភេទ។ ព្រោះការពារចំពោះការរួមភេទមិនមែនការពារតែជម្ងឺអេដស៍មួយនោះទេ។

ផលប៉ះពាល់ចំពោះជម្ងឺរលាកអាងត្រគាកស្ត្រី ផលប៉ះពាល់នៃជម្ងឺរលាកអាងត្រគាកស្ត្រីគឺអាចបណ្តាលឱ្យស្ត្រីគ្រប់រូបពុំមានសមត្ថភាពមានកូន។ ប្រសិនបើមានកូនអាចស្ថិតនៅក្រៅស្បូនអាចប្រឈមមុខនឹងជម្ងឺមហារីកមាត់ស្បូន ទារកអាចស្លាប់នៅក្នុងផ្ទៃរលូតកូន ទារកកើតមកស្លាប់អាចបង្កឱ្យ រលាកភ្នែកទារកដែលទើបនឹងកើតជាដើម។

មិនតែប៉ុណ្ណោះអាចធ្វើឱ្យស្ត្រីមានជម្ងឺស្ថិតពោះវៀន ឈឺចាប់ក្នុងពោះផ្នែកខាងក្រោមរ៉ាំរ៉ៃ និងប៉ះពាល់ដល់ការកង្វះសមត្ថភាពក្នុងការរួមភេទទៀតផង។ ប្រសិនបើជម្ងឺនេះកើតឡើងរ៉ាំរ៉ៃដែលឈានដល់ការរលាកផ្លូវទឹកនោមនឹងអាចរាលដាលដល់ប្រព័ន្ធផ្លូវលាមកទៀតនោះ ធ្វើឱ្យអ្នកជម្ងឺមានសភាពធ្ងន់ធ្ងរ។



ចំពោះស្ត្រីដែលរលាកអាងត្រគាកធ្ងន់ធ្ងររហូតមានការខូចខាតដៃស្បូនទៅហើយនោះមិនអាចព្យាបាលឱ្យជាដូចដើមបានឡើយ ព្រោះ



សន្ទាក់ក្នុងអាងត្រគាកបានរុញច្រានឱ្យដៃស្បូនរួមតៀ្បតប

បង្កើនគ្រោះថ្នាក់នៃការមានគភ៌ក្រៅស្បូន។ ហើយបើទារកស្ថិតនៅក្នុងដៃស្បូនទៀតនោះដៃស្បូនអាចបែកបណ្តាលឱ្យហូរឈាមយ៉ាងច្រើន ៕




# ទឹកឈូ បង្កើនការទាក់ទាញជាងពីមុនសួនសត្វទឹកឈូ បង្កើនការទាក់ទាញជាងពីមុន





ខ្លាដំបង មើលទៅហាក់ដូចជាមានសុខភាពល្អ និងរឹងមាំខណៈវាដើរក្បែររបងទ្រុងរបស់វាជាមួយនឹងជំហានប្រកបដោយជំនឿចិត្ត និងបញ្ចេញសម្រែកយ៉ាងខ្លាំងដែលជាសញ្ញាបង្ហាញពីភាពសាហាវឃោរឃៅរបស់វា ។

នេះជាទស្សនីយភាពស្វាគមន៍នៅសួនសត្វទឹកឈូ ដែលធ្លាប់រងនូវការរិះគន់យ៉ាងខ្លាំងនៅក្នុងខេត្តកំពត ដែលកាលពីពេលមិនដល់កន្លះឆ្នាំមុនមានការខ្វះខាតក្នុងការផ្តល់ចំណីដល់សត្វទាំងនេះធ្វើឱ្យវាមានភាពស្គាំងស្គមយ៉ាងខ្លាំងនៅក្នុងទ្រុងតូចចង្អៀតដែលមានម្លប់តិចតួច ឬគ្មានម្លប់ទាល់តែសោះ ។

លោក Nick Marx ប្រធានផ្នែកថែទាំ និងសង្គ្រោះសត្វព្រៃនៃអង្គការសម្ព័ន្ធសត្វព្រៃជាបុរសម្នាក់ក្នុងចំណោមបុរសមួយចំនួនដែលទទួលបន្ទុកផ្តល់ការគាំពារដល់សួនសត្វនេះបានថ្លែងថា: វាមានស្ថានភាពប្រសើរជាងមុនសត្វទាំងអស់នៅទីនេះឡើងតឹឡូ ។ អ្នកបម្រើការផ្នែកសត្វព្រៃដ៏មានបទពិសោធរូបនេះបន្តថា: វាមានសត្វថ្មីមួយចំនួនហើយមួយចំនួនបានងាប់ ប៉ុន្តែវាមានចំនួនប្រហាក់ប្រហែលដូចមុនដែរ ។

លោក Marx បាននាំផ្លូវយើងដើរកម្សាន្តក្នុងសួនសត្វនេះ ដើម្បីបង្ហាញយើងពីដំណាក់កាលដំបូងនៃអ្វីដែលអ្នកផ្តល់ថវិកា Rory and Melita Hunter សង្ឃឹមថា នឹងជាការកែប្រែថ្មីយ៉ាងធំធេងនៅលើទីតាំងនេះ ដែលស្ថិតនៅតំបន់សម្បូណ៌ទេសចរនៅជើងភ្នំបូកគោមិនឆ្ងាយប៉ុន្មានពីក្រុងកំពត ។

ទៅកម្សាន្តសួនសត្វនោះ កាលពីខែមីនាឆ្នាំទៅវាមានស្ថានភាពគួរឱ្យអាសូរខ្លាំងណាស់ ដែលបានឃើញសត្វដំរីស្បែកជាប់នឹងឆ្អឹងស្គមកំព្រឹងកំពុងរស់នៅក្នុងទ្រុងមានអាចម៍ពាសវាលពាសកាលកំពុងបោះប្រមោយវាតាមរន្ធរបងដ៏រឹងមាំក្នុងបំណងចង់ស៊ីចំណី ។ ទ្រុងផ្សេងទៀត ដែលធ្លាប់មានសត្វខ្លាឃ្មុំ និងភេរស់នៅ គឺមានសភាពទទេស្អាតគួរឱ្យអាសូ ។

លោក Marx បានពន្យល់ ខណៈលោកនាំយើងឱ្យទៅកាន់តែកៀកនឹងហ្វូងសត្វដំរីថា: សត្វទាំងអស់នៅទីនេះ មានអាហារប្រសើរជាងមុន





ហើយឥឡូវនេះ ។ របងរបស់វាមានការប្រែប្រួលប្រសើរឡើង គឺដោយសារជំនួយ២ម៉ឺនដុល្លារ ។

អ្វីដែលគួរឱ្យចាប់អារម្មណ៍បំផុត គឺការប្រែប្រួលរូបរាងនៃសត្វដំរី២ក្បាល ដែលមើលទៅហាក់មានសុខភាពរឹងមាំ ។

លោក Marx ថ្លែងបន្តថា: កាលពីមុនពួកវាស្គមនិងសល់តែឆ្អឹងប៉ុណ្ណោះ ។ ប៉ុន្តែឥឡូវនេះ មើលពោះរបស់ពួកវាទៅមើល! ពួកវាមិនមានបញ្ហាទេឥឡូវនេះ ។

សញ្ញាណដំបូងក៏ជាក្តីសង្ឃឹមសម្រាប់សត្វដទៃទៀតផងដែរ ដូចជាខ្លា តោ ខ្លាឃ្មុំ ស្វា និងសត្វស្លាបជាច្រើនប្រភេទទៀត ដែលរួមទាំងសត្វត្មាតកម្រផងដែរ ។ ដំបូលបាំងកម្តៅថ្ងៃត្រូវបានដំឡើងនៅក្នុងទ្រុងជាច្រើន សម្រាប់សត្វដែលត្រូវថវិកាមួយចំនួន និងបានចរចាកិច្ចព្រមព្រៀងរយៈពេល១៥ឆ្នាំ ជាមួយលោក ញឹម វណ្ណដា ដើម្បីប្រែក្លាយសួនសត្វទឹកឈូនេះ ឱ្យក្លាយទៅជាកន្លែងដែលមិនមែនគ្រាន់តែជាសួនសត្វប៉ុណ្ណោះទេ ។ នេះបើយោងតាមលោក Wayne McCallum អ្នកសម្របសម្រួលគម្រោងដែលបានពន្យល់ប្រាប់យើង ខណៈយើងដើរកាត់សត្វអូទ្រីស និងក្រពើ ។ លោកបន្តថា: ពួកគេថា ពួកគេចង់ធ្វើអ្វីមួយចំនួនក្នុងនាមជាបុគ្គលឯកជន ។ លោកបន្តថា: វាចំណាយច្រើនខ្លាំងណាស់ ។ ដូច្នេះវាមិនមាននិរន្តរភាពក្នុងរយៈពេលយូរទេ ។

ដូច្នេះ តើនឹងមានអ្វីកើតឡើងនៅពេលប្រាក់ទាំងនោះអស់នោះ?

លោក McCallum ដែលបានបម្រើការងារផ្នែកអភិរក្សនៅកម្ពុជា តាំងពីឆ្នាំ២០០៣ មកបានថ្លែងថា: ឱ្យគ្រួសារ Hunters នឹងបង្កើតមូលនិធិមួយ... អ្នកដែលចង់គាំទ្រអាចរួមចំណែកជាថវិកា ហើយដឹងថា មូលនិធិទាំងនោះនឹងត្រូវប្រើសម្រាប់កាតព្វកិច្ចច្បាស់លាស់នៅទឹកឈូ ។ លោកបន្តថា: យើងមិនមែនជាអង្គការក្រៅរដ្ឋាភិបាលទេ ដូច្នេះយើងមិនអាចរកប្រាក់តាមមធ្យោបាយចាស់បានទេ... ប៉ុន្តែយើងកំពុងសម្លឹងមើលសហគមន៍រកស៊ីហើយសង្ឃឹមថា នឹងទាក់ទាញទឹកចិត្តមនុស្សធមិរបស់ពួកគេ ។ លោកបន្ថែមថា: យើងចង់ប្រែក្លាយទីនេះ ឱ្យទៅជាមជ្ឈមណ្ឌលអប់រំអំពីសត្វព្រៃ និងបរិស្ថាន ។ យើងចង់ប្រែក្លាយទីនេះឱ្យក្លាយទៅជាអ្វីមួយដែលពិសេសរហូត **ឥទៅទំព័រទី ២៥**



ការសម្រាក ហើយសំរាមដែលធ្លាប់នៅពាសវាលពាសកាលក្នុងសួននេះត្រូវបានប្រមូលចេញអស់ហើយ ។

លោក Marx បន្តថា: សត្វមានចំណីអាហារ និងត្រូវបានថែទាំប្រសើរជាងមុន ។ យើងមានទំនាក់ទំនងល្អជាមួយឯកឧត្តម ញឹម វណ្ណដា ឱ្យដែលជាម្ចាស់សួនសត្វនេះ ។ អ្វីៗគ្រប់យ៉ាងកំពុងវិវត្តទៅរកភាពកាន់តែល្អនាពេលបច្ចុប្បន្ននេះ ។

គ្រួសារលោក Hunters ដែលឈ្មោះរបស់ពួកគេត្រូវបានចារនៅលើខ្លោងទ្វារសួនសត្វនេះ បានសន្យាជួយ

## តមកពីទំព័រទី ២៤ ទីកល្បូ បង្កើនការទាក់ទាញជាងពីមុន....

ពុំមានកន្លែងណាដូចវានៅក្នុងតំបន់ទន្លេមេគង្គផ្នែកខាងក្រោម ។

លោក McCallum បន្តថា ក្រុមរបស់លោកសង្ឃឹមថា នឹងរៃអង្គាសបានប្រាក់៥០ម៉ឺនដុល្លារក្នុងរយៈពេល១២ខែក្រោយ ដើម្បីផ្គត់ផ្គង់គម្រោងរចនាសម្ព័ន្ធធំៗមួយចំនួនទៀត ។ លោកបន្ថែមថា: យើងកំពុងពិនិត្យមើលបង្កើតវាឡើងជាមួយនឹងកម្មវិធីរៃអង្គាសប្រាក់នៅរាជធានីភ្នំពេញ និងកន្លែងផ្សេងទៀត ។

ក្រៅពីអាកាសធាតុល្អសួនសត្វទឹកល្បូមានលក្ខណៈស្ងាត់ជ្រងំ ។ ទេសចរបរទេសយូរៗម្តងដើរឬជិះកង់កាត់យើង ហើយជនជាតិខ្មែរពេញចិត្តនឹងភាពចម្រុះនៃសត្វក្នុងស្រុក និងនាំចូល ។

លោក សេក សុវណ្ណារ៉ា អ្នកបម្រើការងារក្នុងក្រុមហ៊ុនលក់ស្រាបៀរវ័យ៤០ឆ្នាំម្នាក់ មកពីរាជធានីភ្នំពេញបានថ្លែងថា លោក និងគ្រួសារលោករីករាយដែលឃើញសត្វជិតផុតពូជទាំងនេះនៅក្នុងសួនសត្វទឹកល្បូ ។ យ៉ាងណាក្តីអ្វីដែលលោកព្រួយបារម្ភគឺទំហំទ្រុងដែលពួកវារស់នៅទ្រុងខ្លះមិនមានទំហំធំល្មមទេ ។ សូមពង្រីកទ្រុងហើយឱ្យមានដំបូលសមរម្យផងដែរ ។

ភិក្ខុសង្ឃព្រះនាម ម៉ៅ សាមិត្ត ព្រះជន្ម១៧វស្សាបានមានសង្ឃដីកាថា សត្វដែលរស់នៅក្នុងទ្រុងនៅសួនសត្វនេះ ត្រូវការឱ្យមានការថែទាំផ្តល់ចំណីគ្រប់គ្រាន់ ។ ព្រះអង្គបន្តថា: តាមវិន័យព្រះពុទ្ធសាសនាសត្វនឹងដាក់បណ្តាសាម្ចាស់សួនសត្វ បើម្ចាស់សួនសត្វមិនឱ្យពួកវាស៊ីចំណីគ្រប់គ្រាន់ទេនោះ ។ ប៉ុន្តែនៅពេលម្ចាស់ចិញ្ចឹមពួកវាបានល្អសត្វទាំងនោះនឹងឱ្យពរគាត់ ។

តើសួនសត្វទឹកល្បូដែលយកកម្រៃសេវាចូលទស្សនា៤ដុល្លារ សម្រាប់ភ្ញៀវបរទេស និង១ដុល្លារសម្រាប់ភ្ញៀវខ្មែរមានភ្ញៀវកាន់តែច្រើនដែរ ឬទេចាប់តាំងពីមានការធ្វើឱ្យប្រសើរមកនោះ?

លោក Marx មានភាពស្ទាក់ស្ទើរនឹងតួលេខភ្ញៀវ ។ លោកអះអាងថា:ខ្ញុំមិនដែលរាប់ឡើយ ។ ពិតណាស់អ្នកទស្សនាដែលមកលេងឆ្ងល់ថា មានអ្វីត្រូវបារម្ភនោះ ។ ទ្រុងត្រូវការធ្វើឱ្យថ្មីយើងត្រូវការប្រាក់ ដើម្បីធ្វើអ្វីដែលយើងចង់ធ្វើ ប៉ុន្តែសត្វមានសុខភាពល្អ និងរីករាយណាស់ នាពេលឥឡូវនេះ ។

កាលពីឆ្នាំកន្លងទៅសួនសត្វនេះ បានជួលបុគ្គលិកបន្ថែម តាមសំណើលោក McCallum លោក Marx ដែលធ្លាប់ធ្វើការជាមួយសត្វព្រៃនៅចក្រភពអង់គ្លេស អាហ្វ្រិកខាងត្បូង ឥណ្ឌា និងនៅកម្ពុជាជាច្រើនឆ្នាំ បានចូលរួមកាន់តែខ្លាំង នៅពេលគ្រួសារ Hunters ចាប់ផ្តើមផ្តល់ជំនួយរបស់ពួកគេ ។ លោក Marx បានឱ្យដឹងថា: ជារៀងរាល់ខែយើងត្រូវការយ៉ាងតិចបំផុត៨ពាន់ដុល្លារ ក្នុងមួយខែ ។ នោះជាប្រាក់ខែថ្លៃចំណីសត្វ ហើយវាមានន័យថា យើងត្រូវការកន្លែងពេទ្យសត្វនៅនឹងកន្លែងផ្ទាល់ ។ ប៉ុន្តែវាមិនត្រឹមតែប្រាក់ទេ ។ វានៅខ្វះរចនាសម្ព័ន្ធការងារដែលត្រូវការសម្រេចឱ្យបាន ។

នៅពេលយើងជួបជាមួយគាត់នៅខាងក្រៅលំនៅដ្ឋានរបស់គាត់លោក ញឹម វណ្ណដា អនុប្រធានទី១ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយបានប្រាប់យើងថា លោកតែងតែស្រឡាញ់សត្វរបស់លោក ប៉ុន្តែលោកបានធ្លាក់ចូលក្នុងស្ថានការណ៍ដែលលោកមិនអាចចិញ្ចឹមវាឱ្យបានសមរម្យ ។ លោកគូសបញ្ជាក់ថា: នៅពេលខ្ញុំជួបការលំបាកសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានឱ្យដំបូន្មានខ្ញុំ ឱ្យផ្ទេរសត្វទាំងនោះ ទៅសួនសត្វភ្នំតាម៉ៅ ព្រោះវាមានសត្វជាច្រើននៅទីនោះស្រាប់ទៅហើយ ។ សមាជិករដ្ឋសភាម្នាក់នេះ បានអះអាងថា ខ្លួនបានលក់សត្វគោប្រមាណ២៥ពាន់ក្បាល ដើម្បីទិញចំណីឱ្យសត្វរបស់គាត់ទាំងនេះ ។

លោកបន្តថា ការថែរក្សាអនាគតសួនសត្វនេះជាការសំខាន់ ដែលនេះ ជាមូលហេតុដែលលោកចុះកិច្ចសន្យារយៈពេល១៥ឆ្នាំជាមួយគ្រួសារ Hunters ។

លោកបន្តថា: ក្រោយយើងសហការគ្នាសត្វទាំងនោះបានចាប់កំណើតជាថ្មី... ពួកវាមានសុខភាពល្អជាងមុន ។

ដំណើរទស្សនកិច្ចរបស់យើងជិតដល់ទីបញ្ចប់ហើយ ខណៈយើងដើរកាត់កន្លែងក្មេងលេងខុសប្លែកធម្មតាមួយ ហើយលោក Marx បានបង្ហាញយើងពីការផ្លាស់ប្តូរដែលលោកបានធ្វើទៅលើទ្រុងសត្វស្លាប ។ ការខុសប្លែកទាំងនោះ រួមមានមានដំបូលជ្រកម្លប់ធំជាងមុន និងធុងចំណីដែលមិនឱ្យសត្វស្រមោចឡើងរួច ប៉ុន្តែវានៅតែមានសត្វស្លាបជាច្រើនស្ថិតនៅក្នុងទ្រុងដដែល ។

សួនសត្វនេះ កំពុងវិវត្តឆ្ពោះទៅរកភាពគង់វង្ស ។ ជាមួយនឹងរូបភាពសត្វស្គមស្គាំងសល់តែស្បែកដណ្តប់ឆ្អឹងហាក់នៅថ្មីៗគំនិតផ្លាស់ប្តូរប្រហែលត្រូវការពេលវេលា ។ ការធ្វើឱ្យមនុស្សស្គាល់ទីតាំងសួនសត្វនេះ អាចជាឧបសគ្គមួយទៀត ។ វាច្បាស់ណាស់ថា បញ្ហាធំគឺនៅតែជាប្រាក់ ។

លោក Marx បានបន្តថា: យើងធ្វើការផ្លាស់ប្តូរតាមតែយើងអាចធ្វើបាន ឥឡូវនេះ យើងនឹងធ្វើទៅតាមកម្រិតហិរញ្ញវត្ថុតិចតួចរបស់យើងពីចំណុចក្រោម ៕


# សាលា( Lowell Day Nursery )
## ពីថ្នាក់ដំបូងរហូតដល់ថ្នាក់មត្តេយ្យ

▸ សាលាជាទីកន្លែងលោកអ្នកឮសំលេងកូនក្មេងសើចសប្បាយរីករាយ និងឃើញកូនក្មេងក្រេបជញ្ជក់នូវចំណេះដឹងបានល្អ ។




▸ សាលា(Lowell Day Nursery) បានជួយកូនក្មេង និងក្រុមគ្រួសារតំបន់ឡូវែលបានជាង១០០ឆ្នាំងមកហើយ។

ដូច្នេះពួកគេចង់ជួយលោកអ្នក និងក្រុមគ្រួសាររបស់អ្នកផងដែរ។

▸ ទទួលចុះឈ្មោះចាប់ពីកូនក្មេងអាយុ១៥ខែ រហូតដល់មត្តេយ្យ ចំពោះក្រុមគ្រួសារដែលមានប្រាក់ចំណូលទាបសាលា ក៏ប្រហែលមានមួយចំនួនសំរាប់ដល់ពួកគេដែរ ហើយចំពោះក្រុមគ្រួសារដែលមានប័ណ្ណគណនេយ្យ (Vouchers) ក៏សាលាចុះឈ្មោះដែរ ។

តម្លៃការសិក្សានៅសាលា(Lowell Day Nursery) មានកំរិតទាបជាងគេបំផុតក្នុងសាលាផ្សេងៗនៅក្នុងទីក្រុង Lowell។

▸ ដើម្បីធ្វើការណាត់ជួបក្នុងការទស្សនកិច្ចបរិវេណសាលាព្រមទាំងជួបជាមួយបុគ្គលិក សូមទាក់ទង តាមទូរស័ព្ទលេខ : (978)454 5981 ឬតាមអាស័យដ្ឋានលេខ ១១៩ ផ្លូវ Hall, Lowell MA ០១៨៥៤



# វត្តសូរិយារង្សីនៅហ្វីឡាដែលហ្វ្យនៅតែបន្តមានជំលោះ

**តពីលេខមុន**




ខំរកលុយកាក់បង់ទឹកភ្លើងហ្គាស នឹងចំណាយផ្សេងៗទៀត មើលទៅមិនងាយរកបានលុយកាក់អនុវត្តន៍តាមបញ្ជាសាលាក្រុងបានទេ ។ បើអញ្ចឹងវត្តសុរិយារង្សីកំពុងប្រឈម នឹងការបិទទ្វារតាមបញ្ជាសាលាក្រុងទៅហើយឬអី? ស្រួលមិនស្រួលជំលោះ របស់ក្រុមទាំងពីរនេះ អាចបញ្ចប់ទៅដោយការបិទវត្តជាសារវន្តទេដឹង? ពិសេសក្រុមឈ្នះឆ្នោត គួរគិតឱ្យមែនទែន.អស់លោកចង់កសាងវត្តយើងទៅរកសេចក្តីល្អ ឬចង់ឱ្យអាជ្ញាធរបិទទ្វារវត្តរបស់យើង?

បើក្រលោកយកលុយទៅឱបទុកសម្រាប់មើលលេងវាគ្រោះថ្នាក់ពេកណាស់សម្រាប់វត្តដ៏កំសត់មួយនេះ ឯលុយកាក់ទាំងនោះគ្មានក្រុមណាអាចយកចាយលេងក្រៅពីសម្រាប់ប្រយោជន៍អារាមនេះឡើយ...វត្តយើងកំពុងត្រូវការលុយដើម្បីដោះខ្លួនពីការអាជ្ញាធរដែនដីបិទទ្វារជាសារវន្តអស់លោកបែរជាឱបលុយទុកដោយព្រងើយបញ្ហានេះអាចបញ្ជាក់ថា ក្រុមលោកធ្វើការបោះឆ្នោតនោះ ដើម្បីលុយទេមិនមែនដើម្បីសេចក្តីល្អប្រសើរសម្រាប់សុរិយរង្សីដ៏កំសត់នេះទៅហើយ? បើតាមខ្ញុំស្តាប់តាម ការប្រកាសកម្មវិធីព្រៀងរបស់លោក ងៅ ថាច់ង៉ុក ទុកអនុវត្តន៍សម្រាប់កែលំអរនៃវត្តយើង(ប្រសិនបើលោកបានឡើងកាន់កាប់នោះ) វាល្អប្រសើរណាស់.គួរគណកម្មការចាស់វៀនសូត្រតាម។ យ៉ាងណឹងហើយវាគួរតែគណកម្មការថ្មី(ជាប់ឆ្នោត)នោះប្រគល់លុយដែលក្រុមលោកបានដកហូតយករក្សាទុកនោះឱ្យគណកម្មការចាស់ចាត់ចែងអនុវត្តតាមបញ្ជារបស់សាលាក្រុងគេបង្គាប់ភ្លាមទៅកុំឱ្យគេបិទទ្វារវត្តរបស់យើងទាំងអស់គ្នា ឬក៏កុំអស់លោកចេញមុខមកចាត់ចែងជួសជុលជំនួសក្រុមគណកម្មការចាស់ដែលអត់មានសមត្ថភាព (ដោយមិនបានកាន់លុយនោះ)វិញទៅវាល្អប្រសើរជាជាងឱបលុយទុកឱ្យវត្តសុរិយរង្សីរង់ចាំអាជ្ញាធរដែនដីគេមកចាក់សោររបងវត្តធ្វើឱ្យពុទ្ធបរិស័ទ្ធគាត់អត់ដឹងអីសោះនោះគ្មានវត្តធ្វើបុណ្យ ។ ប្រសិនបើលោកធ្វើបានរឿងនេះមួយវាបង្ហាញថា ក្រុមលោកជាក្រុមក្លាហានមួយហើយៗ ប្រសិនបើក្រុមទាំងពីរឈានទៅដល់ការស្រុះស្រួលគ្នាលុបចោលជំលោះមកចរចារគ្នារកផ្លូវដោះស្រាយការពារអារ៉ាមយើងពីការអន្តរាយនោះអស់លោកទាំងពីរក្រុមជាអ្នកក្លាហានគួរឱ្យលើកសរសើរ។ ការបែកបាក់គ្នាទាំងប៉ុន្មានចាត់ទុកជាការយល់សប្តិអាក្រក់របស់យើងទាំងអស់គ្នាទៅចុះ។ យើងជាបងប្អូន, ជាសាច់ឈាមៈ អារទឹកមិនដាច់អារសាច់មិនបានទេ,រួបរួមគ្នាឡើងវិញទៅបងប្អូន,កុំបន្តធ្វើនូវអំពើដែលនាំទុក្ខមកឱ្យយើងទាំងអស់គ្នាខំធ្វើអំពើណាដែលនាំមកនូវប្រយោជន៍ឱ្យយើងទាំងអស់គ្នា,ឱ្យសហគមន៍យើង,ជាតិយើងនឹងសាសនាយើងបានថ្កុំថ្កើងពីបុណ្យភ្ជុំនេះតរៀងទៅ ។ ប្រសិនបើអស់លោកយល់ថា ល្អចង់រួបរួមគ្នាឡើងវិញតែមិនអាចទាក់ទងគ្នាបាន,ខ្ញុំ គីម ភៀន សុំធ្វើជាអ្នកតភ្ជាប់អស់លោកទាំងពីរក្រុមឱ្យជួបគ្នាក្នុងបរិយាកាសជាបងប្អូន,សុំមេត្តាទាក់ទងមកខ្ញុំតាមអសយដ្ឋានអ៊ីម៉េលនេះ: kimphien@gmail.com ខ្ញុំជៀសវាងការប្រើទូរស័ព្ទក្នុងរឿងនេះ (កុំឱ្យមានការយល់ច្រឡំ)។ខ្ញុំនឹងខំបំពេញកិច្ចការនេះឱ្យបាន, សុក្រិត, ប្រពៃ ឬអរិយប្រពៃ ដើម្បីឱ្យបងប្អូនយើងមូលត្រកូលគ្នាឡើងវិញនេះ ជាការចង់បានរបស់អ្នកម្តាយយើងទាំងអស់គ្នា!!។ខ្ញុំបានយល់ថា ការបែកបាក់នេះ នឹងនាំមកនូវផលវិបាកគ្រប់បែបយ៉ាងមកដល់យើងទាំងអស់គ្នាក្នុងបច្ចុប្បន្នហើយកាន់តែខ្លាំងថែមទៀតនៅក្នុងអនាគតរបស់យើង,ជាតិយើង,សាសនារបស់យើង ។ ដោយយល់ដូច្នោះហើយ ទើបខ្ញុំបានលុតជង្គង់ថ្វាយបង្គំបីដងសុំឱ្យអស់លោកមេត្តាស្រុះស្រួលគ្នាដោះស្រាយបញ្ហាដោយសន្តិវិធីតែលោកក្មួយ ងៅ ថាច់ង៉ុក បានឆ្លើយដោយអស់សង្ឃឹមថា: "Too late" =ហួសពេលហើយ!!។ ខ្ញុំរំលឹករឿងនេះមិនមែនខ្ញុំអាក់អន់ចិត្តប៉ុនមួយចំរៀកសក់ជាមួយអង្គប្រជុំ ឬជាមួយលោកក្មួយ ងៅ ថាច់ង៉ុក ទាល់តែសោះ តែខ្ញុំចង់សំដែងក្តីស្មោះត្រង់របស់ខ្ញុំថា នឹងខំឱ្យអស់ពីសមត្ថភាពរបស់ខ្លួនដើម្បីធ្វើឱ្យបងប្អូនទាំងពីរក្រុំអាចរួបរួមគ្នាជួយសង្គ្រោះវត្តអារាមយើងឱ្យបានគង់វង់តទៅមុខទៀតក្នុងភាពសាមគ្គីស្រឡាញ់អាណិតគ្នាទៅវិញទៅមកដូចគ្រាដំបូង ទោះមានការលំបាកយ៉ាងណាក៏ខ្ញុំមិនរាថយឡើយ ។

ចំណែកខ្ញុំបានចុះហត្ថលេខាគាំទ្រការជាប់ឆ្នោតរបស់គណកម្មការថ្មីនោះក៏ដោយសារបានដឹងថា ប្រធានគណកម្មការចាស់អត្តនោម័តិជ្រុល ពេកដឹងថា ការកសាងអាគារថ្មី,ជួសជុលទីធ្លាវត្តវាខុសច្បាប់ក្រិតក្រំ គេព្រមានមួយសារជាពីសារទៅហើយលោកនៅតែខំប្រឹងចរចេសធ្វើសុំឱ្យបើកអង្គប្រជុំដោះស្រាយរឿងវិបត្តិនេះលោកអះអាងថា លោកជាប្រធានទៅហើយ បើលោក

**តទៅទំព័រទី ២១**



# វិស្វកម្មក្នុងចិត្តមនុស្ស
## The human inner engineering

**តពីលេខមុន**

**ក**-បើអ្នកគិតអំពីកិច្ចការណាមួយ

**-មនុស្សសាមញ្ញ :** គេចាត់ទុកខ្លួនគេជាគំនិតនេះ គេស្ថិតនៅក្នុងគំនិតនេះ គេជាអ្នកគិតតែម្តង You are the thumken



និពន្ធដោយ : ម៉ៅ ច័ន្ទសំណុំ

**-អ្នកត្រាស់ដឹងជាន់ទាប :** គេអាចពិនិត្យលំហូរគំនិតបាន គេពុំមែនជាគំនិតទាំងអស់នៅឡើយ គេផ្តាច់ខ្លួនចេញពីលំហូរគំនិតទាំងនោះ ពុំអនុញ្ញាតឱ្យគំនិតណាមួយគ្រប់គ្រងឡើយ គេបានប្រើប្រាស់សិទ្ធជ្រើសរើស និងសម្រេចយកគំនិតណាមួយមកប្រើប្រាស់បាន នេះគឺសេរីភាពរបស់មនុស្សយើង You watch thinking ចំណែកឯមនុស្សសាមញ្ញគេបាត់បង់សេរីភាពនេះទាំងស្រុង ។

**អ្នកត្រាស់ដឹងជាន់ខ្ពស់ផុត :** គេពិនិត្យអ្នកកំពុងតែគិតតែម្តង ឬមួយគេពិនត្យអ្នកត្រាស់ដឹងជាន់ទាបដែលកំពុងតែពិនិត្យលំហូរគំនិតនោះ។ មានន័យថា គេពិនិត្យបន្តលើអ្នកកំពុងតែពិនិត្យ Awareress Over the Awaress មានន័យម្យ៉ាងទៀតថា សតិដឹងរបស់មនុស្សឋិតនៅពីក្រោយអ្វីៗទាំងអស់នោះ។

២- បើអ្នកកំពុងតែខឹង

មនុស្សសាមញ្ញ គេគឺជាកំហឹងនេះឯង គេដើរតួរជាអ្នកខឹងតែម្តងកំហឹងបានដឹកនាំគ្រប់គ្រងរូបគេទាំងស្រុង He identifies with the angen ។

អ្នកត្រាស់ដឹងជាន់ទាប គេអាចពិនិត្យកំហឹងបានគេឈរនៅក្រៅចរន្តកំហឹងគេពុំមែនជាកំហឹងឡើយ កំហឹងឈប់ត្រួតត្រាគេទៀតហើយ គេបានរួចរំដោះអំពីថាមពលកំហឹងនេះ។ (you wath the angen) អ្នកត្រាស់ដឹងជាន់ខ្ពស់ គេអាចពិនិត្យអ្នកដឹងនេះតែម្តង ឬក៏ពិនិត្យអ្នកត្រាស់ដឹងជាន់ទាបដែលកំពុងតែពិនិត្យកំហឹងនោះ ។ មានន័យថា គេពិនិត្យបន្តពីលើអ្នកកំពុងតែពិនិត្យ ដូច្នេះសតិដឹងមនុស្សនៅពីក្រោយអ្វីៗទាំងនោះ ។ លោកអ្នកត្រាស់ដឹងផ្តាច់សតិទាំងស្រុងផុតពីចរន្តចិត្ត និងកាយ ហើយស្ងប់ទាំងស្រុង ។ កំហឹងផុះឡើងក្នុងប្រព័ន្ធកាយ និងចិត្តដាច់ផុតពីរូបអ្នកត្រាស់ដឹងទាំងស្រុងគេប្រៀបរូបអ្នកត្រាស់ដឹងដូចជាកញ្ចក់ទូរទស្សន៍នៅទីនោះ រូបភាពរឿងរ៉ាវជាច្រើនផុះឡើង ដូចជាសង្គ្រាមអគ្គិភ័យការសម្លាប់គ្នាទឹកជំនន់ ។ល។ ហើយរឿងទាំងអស់នោះផុះឡើង ហើយរលាយបាត់ទៅវិញដោយឯកឯងពុំបណ្តាលឱ្យកញ្ចក់ទូរទស្សន៍ឆេះ ឬសើមទទឹកអ្វីឡើយ ។ កញ្ចក់ទូរទស្សន៍នៅតែជាកញ្ចក់គ្មានស្នាមប្រេះស្រាំអ្វីឡើយ ។ គាត់បានរួចរំដោះទាំងស្រុង ។ ចំណែកឯមនុស្សសាមញ្ញវិញ គេតែងតែដើរតួរក្នុងរឿងរ៉ាវលើកញ្ចក់នោះ ដូច្នេះទុក្ខវេទនាកើតឡើងរាល់ពេលចៀសផុតពុំរួច ។ អ្នកត្រាស់ដឹងជាន់ខ្ពស់មើលវត្ថុនានាបាតុភូតនានាតាមសភាពពិតមានន័យថា អ្វីដែលបំរុងនឹងកើតវាត្រូវតែកើត តាមសភាវៈក្រិតក្រំយុត្តិធមិ ហេតុផលជាក់លាក់គាត់ទទួលយកនិងស្វាគមន៍រាល់អ្វីៗដែលកំពុងតែកើតមានក្នុងពេលនេះ ហើយសម្របសម្រួលតាមសភាពជាក់ស្តែងយ៉ាងរលូនយ៉ាងឈ្លាសវៃទទួលលទ្ធផលខ្ពស់ ។ គាត់ពុំមានចេតនាចង់ឱ្យសភាពការណ៍កើតឡើងតាមទំនងណាមួយដែលខុសប្លែកពីផ្លូវធម្មជាតិឡើយ ។ គាត់ចងមិត្តភាពជាមួយនឹងព្រឹត្តិការណ៍ជាក់ស្តែងជានិច្ចជាមួយនិងបច្ចុប្បន្នភាពជានិច្ច។

បើអ្នកជ្រោតជ្រាបអំពីការប្រើសតិដឹងខាងលើនេះអ្នកអាចនឹងឈានទៅប្រើសតិជាមនុស្សអ្នកត្រាសដឹងជាន់ទាប ឬអ្នកត្រាស់ដឹងជាន់ខ្ពស់បានក្នុងកាលៈទេសៈនីមួយៗ។ ខ្ញុំសូមលើកឧទាហរណ៍ជាគំរូមួយសម្រាប់អ្នកប្រើប្រាស់សំរួលជីវិតរំដោះចិត្តភ្លាមៗ ។ បើពេលនេះ ស្ត្រេះផុះឡើងក្នុងខ្លួន តើតភាពច្របូកច្របល់ក្នុងចិត្តនឿយណាយ និងជីវិត ឬអស់សង្ឃឹមទាំងស្រុង ចូរអ្នកប្រណិបត្តិដូចរបៀបខាងក្រោមនេះ:

១-ចូរអ្នកទំលាក់សតិពីក្បាលចុះមកដឹងខ្លួនមានសតិដឹងរាល់វេទនាទាំងឡាយលើរូបកាយមានសតិ ដឹងអំពីលំហូរកំណិត មានសតិដឹងអំពីការប្រតិកម្ម អារម្មណ៍ មនោសញ្ចេតនា បារម្ភ ភ័យ ព្រួយ កំហឹង ភាពជ្រួលច្រាល...ពិត និងជាក់ស្តែងនៅពេលនោះ។

២-អ្នកអាចនឹងរុករកពិនិត្យ និងមានសតិដឹងអំពីជនដែលនៅក្នុងខ្លួនអ្នក ហើយដែលកំពុងទទួលរងគ្រោះទទួលទម្ងន់ពីស្ត្រេះនេះ ។ ឬរបៀបមួយទៀត អ្នកអាចពិនិត្យបន្តពីលើជនដែលកំពុងប្រណិបត្តិសតិដឹងក្នុងជំពូកទី១ខាងលើនេះ។

៣-ក្នុងពេលដែលអ្នកមានសតិដឹង ដូចជំរាបខាងលើ សូមទំលាប់បញ្ឈប់ការបើកចំហរ និងស្វាគមន៍ ចំពោះរាល់រឿងរ៉ាវបាតុភូតនានា (ទាំងល្អទាំងអាក្រក់ដែលកំពុងតែផុះឡើងដែលកំពុងតែប្រព្រឹត្តទៅ។ បើកចំហរ និងស្វាគមន៍ មានន័យថា នៅស្ងៀម) ពុំធ្វើអ្វីឡើយ ពុំប្រតិកម្ម ពុំគិតពិចារណា **តទៅលេខក្រោយ**







# ជោគជតារាសីលោកអ្នក
## ទាំង១២ប្រចាំឆ្នាំរោង

### ឆ្នាំជូត
រាល់ការបំពេញការងារទាំងឡាយលោកអ្នកមិនមានបញ្ហាអ្វីចោទនោះទេ ប៉ុន្តែក្នុងនោះ សូមប្រយ័ត្នកុំយកអាសាមនុស្សសម្បុរសឱ្យសោះ ព្រោះនាំឱ្យកើតរឿងសៅហ្មងទៅថ្ងៃក្រោយ ។ សម្រាប់អ្នកប្រកបមុខរបររកស៊ីជួញដូរវិញ អាចសន្សំទុកបានខ្លះ ។ រីឯបញ្ហាស្នេហាចូរកុំយកភាពមានះចង់ចាញ់ឈ្នះប្រយ័ត្នកើតមានជម្លោះវិវាទឈានដល់ការប្រេះស្រាំ ៕

### ឆ្នាំឆ្លូវ
នៅក្នុងរយៈពេលនេះលោកអ្នកទទួលលាភសក្ការៈពីសាច់ញាតិបងប្អូនដែលជិតស្និទ្ធ ។ ក្រៅពីនោះក៏នៅទទួលបានដំណឹងល្អដែលមានប្រយោជន៍ដល់ជាតិនិងការងាររបស់លោកអ្នកតទៅ អនាគតទៀតផង ។ បើជាអ្នកប្រកបមុខរបររកស៊ីវិញផលកម្រៃទទួលបានកាក់កបគ្រាន់បើ តែហាមកុំជួញដូរផ្លូវឆ្ងាញប្រយ័ត្នមានបញ្ហាដល់ខ្លួន ។ រីឯបញ្ហាស្នេហាគូស្នេហ៍អាចមានការរកាំរកូសគ្នាខ្លះ ប៉ុន្តែមិនធ្ងន់ធ្ងរនោះទេ ៕

### ឆ្នាំខាល
រាល់កិច្ចការដែលលោកអ្នកបំងប្រាថ្នាជាយូរមកហើយនោះក្នុងរយៈពេលនេះ គឺបានសមដូចបំណង ហើយគ្មានអ្វីមករារាំងនោះទេ ហើយរាល់ការបំងយាយីពីមនុស្សដែលមានបំណងមិនល្អមកលើលោកអ្នកនោះក៏មិនបានសម្រេចដែរ ។ បើជាអ្នកប្រកបមុខរបររកស៊ីវិញអាចពង្រីកអាជីវកម្មឱ្យធំបន្ថែមទៀតបាន ។ ឯបញ្ហាស្នេហាគូស្វាមីភរិយាមានភាពសុខដុមរមនាគ្មានផលវិបាកអ្វីឡើយ ៕

### ឆ្នាំថោះ
លោកអ្នកមានភ័ព្វសំណាងល្អក្នុងការងារទទួលរឿងឡើងតួនាទី ឬប្រាក់បៀវត្សរ៍បន្ថែម ។ ជាងនេះទៀតនោះ ប្រសិនបើចង់ពឹងពាក់អ្នកមានយសស័ក្តិខ្ពង់ខ្ពស់ក្នុងរឿងអ្វីមួយនឹងបានដូចបំណងផងដែរ ។ បើជាអ្នកប្រកបមុខរបររកស៊ីវិញអាចរកប្រាក់ចំណូលចិញ្ចឹមគ្រួសារបានដោយស្រួលទេ មិនមានអ្វីមករាំងស្ទះឡើយ ។ រីឯបញ្ហាស្នេហាគូស្នេហ៍រមែងចេះអត់ឱនឱ្យគ្នា ៕

### ឆ្នាំរោង
ក្នុងរយៈពេលនេះលោកអ្នកជួបនឹងបញ្ហាខាងផ្លូវចិត្តមិនសូវជាសប្បាយរីករាយប៉ុន្មាននោះទេ តែប្រសិនបើចង់ទទួលផលពីការងារនោះ ចូរធ្វើចិត្តឱ្យត្រជាក់ ទើបបានសម្រេចដូចបំណង ។ បើជាអ្នកប្រកបរបររកស៊ីជួញដូរវិញ គឺមានការប្រទាំងប្រទើសជាមួយអ្នកមានមុខរបរដូចគ្នា ដូច្នេះគួរបើកចិត្តឱ្យទូលាយ ។ រីឯបញ្ហាស្នេហាមានការកាំចិត្ត ព្រោះតែម្នាក់ៗចង់ចាញ់ឈ្នះគ្នានោះឯង ៕

### ឆ្នាំម្សាញ់
រាល់កិច្ចការសព្វបែបយ៉ាងលោកអ្នកអាចជួបនឹងបញ្ហាខ្លះៗនាគ្រាដំបូង ប៉ុន្តែក្រោយមកមិនមានអ្វីជាឧបសគ្គរារាំងទៀតឡើយ ។ ចំពោះអ្នកប្រកបមុខរបររកស៊ីជួញដូរវិញ មានការទិញចូលលក់ចេញគ្រាន់ បើអាចរកផលកម្រៃត្រឡប់មកផ្ទះវិញយ៉ាងត្រជាក់ចិត្ត ។ រីឯបញ្ហាស្នេហាមានភាពផ្អែមល្ហែម និងស្រស់ស្រាយប្រៀបដូចត្រីក្នុងទឹកនារដូវខែវស្សាដូច្នេះដែរ ៕

### ឆ្នាំមមី
លោកអ្នកគួរប្រុងប្រយ័ត្នចំពោះការនិយាយស្តីបន្តិច ពីព្រោះអាចនឹងមានគូសត្រូវចាំចាប់ទោសកំហុសមួលបង្កាច់បង្ខូចកេរ្តិ៍ឈ្មោះរបស់លោកអ្នកឱ្យប្រែក្លាយទៅជាស្មុយអសោចិ៍ ។ សម្រាប់អ្នកប្រកបមុខរបររកស៊ីជួញដូរវិញមានក្រុមមនុស្សតាមឈ្នានីសច្រើន ដូច្នេះត្រូវប្រយ័ត្នបន្តិចចៀសវាងការបរាជ័យ ។ រីឯបញ្ហាស្នេហាមានភាពចម្រូងចម្រាសដាក់គ្នាបន្តិចបន្តួច ៕

### ឆ្នាំមមែ
រាល់ការស្មុគស្មាញដែលធ្លាប់កើតមានលើលោកអ្នកក្នុងពេលនេះនឹងត្រូវអហោសិកម្មទាំងអស់ ហើយទ្រព្យដែលរបូតចេញពីដៃទៅនឹងវិលត្រឡប់មកវិញយ៉ាងគ្រប់គ្រាន់ ។ ចំពោះអ្នកប្រកបមុខរបររកស៊ីជួញដូរវិញ ត្រូវគិតគូរឱ្យបានច្បាស់លាស់មុននឹងដាក់ទុនថ្មី ទើបមិនខាតបង់រាល់ការចំណាយទាំងនោះ ។ រីឯបញ្ហាស្នេហាត្រូវចេះពូនជ្រោយចំណងស្នេហាដោយមានភាពផ្អែមល្ហែមទើបជាការប្រសើរ ៕

### ឆ្នាំវក
អាចពោលបានថា លោកអ្នកមានសេចក្តីសុខក្នុងជីវិត និងការងារ ព្រោះវិបត្តិ និងភាពស្មុគស្មាញដែលមានកន្លងមកក៏បានធូរស្រាលឡើងវិញមួយកម្រិតផងដែរ ។ បើជាអ្នកប្រកបមុខរបររកស៊ីវិញ ទោះបីជាចេញទៅជួញដូរ នៅទីណាក្តីគួរចៀសវាងការដាក់ទុនថ្មី ព្រោះអាចនាំឱ្យខាតបង់ ។ រីឯបញ្ហាស្នេហាគូស្នេហ៍ច្រើនប្រចណ្ឌខុសរឿង ៕

### ឆ្នាំរកា
លោកអ្នកនឹងទទួលបាននូវលាភសក្ការៈពីភាគហ៊ុនរកស៊ី និងមិត្តរួមការងារយ៉ាងច្រើនគួរឱ្យពេញចិត្ត ។ លើសពីនេះទៅទៀតគម្រោងការដែលបានត្រៀមទុកនឹងបានសម្រេចដូចបំណងទៀតផង ។ បើជាអ្នកប្រកបមុខរបររកស៊ីវិញ គួរជួញដូរនៅទីជិតៗ ទើបសមប្រកប ។ រីឯបញ្ហាស្នេហាគូស្នេហ៍ចេះស្តាប់ឱវាទគ្នា ៕

### ឆ្នាំច
លោកអ្នកអាចនឹងមានអារម្មណ៍ច្របូកច្របល់បន្តិចនៅក្នុងរយៈពេលនេះ ព្រោះកិច្ចការដែលថា នឹងទទួលបានផលល្អនោះ វាអាចមានការប្រែប្រួលដោយសារតែមានការរំខានពីអ្នកដទៃ ។ បើចំពោះអ្នកប្រកបមុខរបររកស៊ីជួញដូរវិញ អាចរកផលកម្រៃគ្រាន់ បើគួរជាទីគាប់ប្រសើរជាងមុន ។ រីឯបញ្ហាស្នេហាពុំមានផលវិបាកអ្វីនោះឡើយ ៕

### ឆ្នាំកុរ
រាល់ការបំពេញការងាររបស់លោកអ្នកក្នុងរយៈពេលនេះសុទ្ធតែផ្តល់នូវអត្ថប្រយោជន៍ គួរឱ្យជាទីពេញចិត្តទាំងអស់គ្មានអ្វីមករាំងស្ទះឡើយ ហើយជាងនេះទៀត នោះគម្រោងការដែលបានត្រៀមទុកជាយូរមក ហើយក៏នឹងបានសម្រេចផងដែរ ។ បើ ជាអាជីវកររកស៊ីវិញ មានការរីកចម្រើនល្ងូតលាស់ទៅមុខជាលំដាប់ ។ រីឯបញ្ហាគូស្នេហ៍ច្រើនយល់ចិត្តគ្នា និងនឹករលឹកគ្នាបើនៅឆ្ងាយ ៕

## តមកពីទំព័រទី ១៩ ដេកមិនលក់ប៉ះពាល់ដល់សុខភាព....

ឬអាចជារៀងរហូតក៏មាន។ ម្យ៉ាងទៀតជម្ងឺអាចមកបៀតបៀនបានយ៉ាងឆាប់រហ័ស ព្រោះសុខភាពចុះទ្រុឌទ្រោម ។ ដេកមិនលក់ជាបញ្ហាមួយដែលកើតចំពោះលោកអ្នកគ្រប់វ័យដោយសារការគិតដែលមានលក្ខណៈផ្សេងៗពីគ្នា។

**វិធីទប់ស្កាត់នៅពេលដេកមិនលក់**

លោកអ្នកមិនគួរគិតច្រើនពេកទេនៅពេលដេកមិនលក់ និងសូមកុំធ្វើសកម្មភាពដែលនាំឱ្យគិតដល់រឿងរ៉ាវដែលអាក្រក់ ចំពោះខ្លួនឯង។ ដើម្បីទប់ស្កាត់បញ្ហាទាំងនោះលោកអ្នកដែលដេកមិនលក់គួរប្រតិបត្តិដូចខាងក្រោមទើបអាចប្រសើរជាងមុន ហើយជួនកាលអាចបំភ្លេចបញ្ហាគ្រប់យ៉ាង និងជួយឱ្យដេកលក់ស្រួលទៀតផង។

-មិនត្រូវទទួលទានអាហារច្រើនហួសកំណត់ឡើយ

-ព្យាយាមរម្ងាប់អារម្មណ៍ចំពោះរឿងរ៉ាវទាំងឡាយដែលពាក់ព័ន្ធនឹងខ្លួនឯង

-ត្រូវគិតមួយរឿងៗឱ្យដាច់ស្រឡះពីគ្នា មិនត្រូវគិតច្របូកច្របល់នូវបញ្ហាទាំងអស់ទេ

-ត្រូវលួងខ្លួនឯងថាអ្វីៗក៏អាចដោះស្រាយបានដែរ ឱ្យតែយើងហ៊ានប្រឈមមុខនឹងការពិត

ប្រសិនបើអាចនិយាយពីរឿងរបស់ខ្លួនបានគួរតែនិយាយប្រាប់អ្នកណាម្នាក់ដែលអ្នកទុកចិត្តបំផុត

បើលោកអ្នកគិតថាខ្លួនមានអាការខុសប្រក្រតី គប្បីលោកអ្នកត្រូវទៅពិភាក្សាជាមួយគ្រូពេទ្យជំនាញ ដើម្បីរកវិធីទប់ស្កាត់ឱ្យទាន់ពេលវេលា។

លោកអ្នកត្រូវគិតថាការបាក់ទឹកចិត្តអ្នកណាក៏ជួបប្រទះដែរ មិនអាចចៀសផុតបានទេ ហើយការបាក់ទឹកចិត្តទាំងនោះក៏ជាចំណែកមួយដ៏ធំធ្វើឱ្យលោកអ្នកដេកមិនលក់។ អ្វីដែលសំខាន់លោកអ្នកត្រូវជួយខ្លួនឯងឱ្យបានចំពោះរឿងដែលកើតឡើងជុំវិញខ្លួន។

**ដំបូន្មានអ្នកប្រឹក្សា**

ជាទូទៅពេលដេកមិនលក់លោកអ្នកមិនគប្បីប្រើថ្នាំរម្ងាប់អារម្មណ៍នោះទេព្រោះអាចប៉ះពាល់ដល់សុខភាពយ៉ាងធ្ងន់ធ្ងរ ។ លោកអ្នកគួរគិតថាជារឿងធម្មតាអ្នកណាក៏ធ្លាប់ជួបប្រទះគ្មានអ្នកណាម្នាក់អាចចៀសរួចឡើយ។ គប្បីបើកចិត្តឱ្យទូលាយដើម្បីទទួលយកអ្វីដែលជាការពិត និងធ្វើការដោះស្រាយដើម្បីឱ្យដេកលក់ស្រួលជាងពេលមុន៕

## តមកពីទំព័រទី ១៨ មហាបាតុកម្មអហឹង្សានៅទីលាន...

**១**-អាជ្ញាធរមូលដ្ឋានរារាំងគំរាមកំហែង ២-ទឹកជំនន់ ៣-ចំណាកស្រុកទៅបរទេសក្រោយពេលបោះឆ្នោត។ បាតុករម្នាក់ៗចំណាយទៅលើចំណីអាហារពី៨ពាន់រៀលទៅ១ម៉ឺនរៀលក្នុង១ថ្ងៃៗ។

-មេដឹកនាំគណបក្សសង្គ្រោះជាតិ បានមកដល់ទីលានប្រជាធិបតេយ្យនៅវេលាម៉ោងប្រ-មាណ២កន្លះរសៀល ហើយបានឡើង ថ្លែងសារនយោបាយនានាពិសេសទាក់ទងនឹងរឿងកិច្ចព្រមព្រៀងទីក្រុងប៉ារីស ២៣ តុលា ១៩៩១។



នៅវេលាម៉ោងប្រមាណជាងពាររសៀលនេះ ក្រុមបាតុករប្រមាណ១ម៉ឺននាក់ ដើរដង្ហែញត្តិពីទីលានប្រជាធិបតេយ្យទៅការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំនៅកម្ពុជា ដោយពុំមានការរារាំងណាមួយពីក្រុមសមត្ថកិច្ចនោះទេ។ ក្រុមសមត្ថកិច្ចក៏បានជួយសម្រួលចរាចរណ៍ដល់ក្បួនដង្ហែដែរ។ គួរកោតសរសើរមែនក្រុមសមត្ថកិច្ច ?

ក្បួនដង្ហែបានទៅដល់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅម៉ោងប្រមាណជាង៤រសៀល ហើយមន្ត្រី អ.ស.ប បានចេញមកទទួលយកញត្តិ។ ក្បួនបាតុករបានត្រឡប់មកកាន់ទីលានប្រជាធិបតេយ្យវិញ បន្ទាប់ពីមានការទទួលយកញត្តិ។

-នៅពេលយប់នៅទីលានប្រជាធិបតេយ្យមានបញ្ហាំងខ្សែភាពយន្តឯកសារការតស៊ូរបស់អ្នក ៕

## តមកពីទំព័រទី ១ ថ្ងៃទី ៥ វិច្ឆិកា ២០១៣ ចុះបើគ្មានខ្មែរ...

សរសេរភាសាខ្មែរចង់ឃើញមានតំណាងខ្មែរត្រូវពលរដ្ឋសញ្ជាតិខ្លួន បញ្ជូនឱ្យទៅកាន់តំណែងកំពូលក្នុងតំបន់ខ្លួន បើមិនបានដល់១ភាគ៣ទេ ក៏មានម្នាក់ឬ២នាក់ដែរ គ្រាន់នឹងពឹងពាក់! តែអ្នកកាសែតតែងតែនឹងទៅដល់គំនិតផ្ទុយមួយដែលថា (ចុះបើគ្មានខ្មែរណាម្នាក់ជាប់ឆ្នោតទៅវិញ តើវាលំបាកប៉ុណ្ណា? ) ។

លំបាកឬ? ខ្មែរពូកែទ្រាំណាស់ ទ្រាំអត់បាយ ទ្រាំឱ្យខ្មែរក្រហមវាយទាល់តែស្ទើរបាត់ពូជ...មកដល់ឡូវែលនៃសហរដ្ឋអាមេរិក តើយើងនៅទ្រាំដល់ណាទៀត? អត់មានតំណាងក្នុងសាលាក្រុងក៏មិនអី នរណាខិតលើ និងត្រូវគេទាញសម្រាតខោឱ្យខ្មាស់គេ! ត្រូវគេឱ្យឈ្មោះថា ពូកែខាងបែកបាក់គ្នាជាកង់ៗច្រើនក្រុមមិនក៏អី! តែកូនចៅជំនាន់ក្រោយកំពុងរងគ្រោះជាទម្ងន់ដោយសារការពូកែខាងទ្រាំយ៉ាងកំសាកនោះរួមទាំងគ្រួសារ ខ្លួនឯងទាំងមូលផង ។

នៅតាមផ្លូវក្នុងមនុស្សដែលជួបបីនាក់យ៉ាងហោចណាស់ក៏មានខ្មែរម្នាក់ដែរនៅឡូវែលនេះ តែនៅកន្លែងធ្វើការសំខាន់ៗពុំមានចំនួនច្រើនយ៉ាងនេះទេ ដូចជាគ្រូបង្រៀន និងនាយប៉ូលិស ការិយាល័យ រដ្ឋបាល សំណង់ ឬមន្ទីរពេទ្យ ពុំសូវមានកូនខ្មែរជោគជ័យ ច្រើននៅក្នុងការសិក្សា តើខ្មែរពុំត្រូវការអាជីពសំខាន់ៗទាំងនោះទេឬ?

ក្នុងស្ថិតិដែល សេងលី និង រីធីត ផ្តល់កាលពីកាសែតលេខមុនបានឱ្យដឹងថា មានខ្មែរទៅចុះឈ្មោះបោះឆ្នោតចំនួនជាង៧ពាន់នាក់ បានន័យថា "អ្នកទាំងនោះចង់ឱ្យកម្លាំងដល់សហគមន៍ ហើយបំពេញករណីកិច្ចជាពលរដ្ឋថ្មី ទើបនាំជីវភាពទៅរកប្រសើរបាន" ហើយបើគ្រាន់តែអ្នកទាំងនោះជុំគ្នាយល់ដូចគ្នាថា "មកពីទីឆ្ងាយត្រូវខំងើបដោយសម្លឹងទៅអនាគតវែងឆ្ងាយ" ក៏អាចធ្វើឱ្យបេក្ខជនខ្មែរទាំងពីររូបជាប់ឆ្នោតបានយ៉ាងងាយស្រួលដែរ ពីព្រោះបើតាមចំនួនសន្លឹកឆ្នោតដែលបោះរួចហើយបេក្ខជនម្នាក់ៗត្រូវការប្រមាណ ៣០០០សម្លេងសម្រាប់ជាប់ឆ្នោត ។

បើពុំមានខ្មែរជាប់ឆ្នោតទៅវិញ បានន័យថា ១-ខ្មែរពុំបានទុកចិត្តទៅលើបេក្ខជនជាសញ្ជាតិខ្លួនទេ ២-បេក្ខជនសាសន៍ដទៃផ្តល់ការទុកចិត្តឱ្យអ្នកបោះឆ្នោតខ្មែរច្រើនជាង ៣-សហគមន៍ខ្មែរគ្មានការណែនាំឱ្យចេះបោះឆ្នោត ឬមិនមកបោះឆ្នោតតែម្តង ៤-អាចនឹងមានគំរូថា "តំណាងខ្មែរដែលធ្លាប់មានមកពីរដងហើយ ពុំបានជាទីពឹងពាក់ដល់សហគមន៍ខ្មែរទេ " ។ល។

បើយ៉ាងនេះមែននៅ២ថ្ងៃមុនម្ចាស់ឆ្នោតទៅចុះឈ្មោះជ្រើសរើសបេក្ខជនដែលគេស្រឡាញ់ - តើបេក្ខជនខ្មែរត្រូវប្រើបច្ចេកទេសនិងទ្រឹស្តីណាដើម្បីឱ្យមានការបង្វែរអារម្មណ៍អ្នកបោះឆ្នោតឱ្យចាប់យកឈ្មោះរបស់ខ្លួនជាអាទិភាពវិញ?

យើងនៅតែយល់ថា "នៅឡូវែលគួរតែមានថ្នាក់ដឹកនាំនៅសាលាក្រុង ឬនៅគណកម្មការសាលារៀនជាខ្មែរ" ទោះតិចតួចក្តី ពីព្រោះជាសម្លេងនៃសហគមន៍ខ្មែរដែលមានវប្បធម៌មិនដូចគ្នានិងសាសន៍ដទៃ ដើម្បីអភិវឌ្ឍន៍ជាមួយសង្គមទាំងមូលបាន បើមិនដូច្នេះទេ យើងនៅតែខូចខាតប្រយោជន៍សម្រាប់ជួយគ្រួសារខ្មែរជួយសហគមន៍ខ្មែរ និងគ្មានការជួយរៀបអនាគតឱ្យជំនាន់ក្រោយខ្មែរទេ ។ ខ្មែរយើងមិនពូកែនិយាយពន្យល់សាសន៍ដទៃឱ្យចេះជួយខ្មែរដល់ជម្រៅនៃវប្បធម៌យើងនៅទីប្រជុំសាលាក្រុង ឬនៅសាលារៀនដូចខ្មែរទៅការពារប្រយោជន៍ខ្មែរដោយខ្លួនឯងទេ ដូច្នេះមានតែពឹងលើសមាណចិត្តនៃបេក្ខជនខ្មែរដែលបានឈរឈ្មោះនោះហើយ បើមិនពេញចិត្តទេ ចាំពីឆ្នាំក្រោយក៏យើងនៅអាចប្តូរដាក់មនុស្សថ្មីបានដែរ ៕

## តមកពីទំព័រទី ៥ ខួបលើកទី១៤ នៃ...

អ៊ីតាលី (Italy) អង់គ្លេស (Britain) ជាដើម ។ មន្ទីរពេទ្យកុមារអង្គរបំពាក់ដោយសម្ភារៈបរិកាសំបូរបែបនិងឧបករណ៍ទំនើប រហូតដល់មានសម្ភារៈសង្គ្រោះបន្ទាន ICU និង ជម៉ូធ្ងន់ ម៉ូនីទ័រ ឧបករណ៍សប់ជំនួយការដកដង្ហើម និងសម្ភារៈមើលឈាមទំនើប ។ ស្របគ្នានោះដែរ មន្ទីរពេទ្យកុមារអង្គរមានគ្រែអ្នកជំងឺចំនួន៨៥មានពេទ្យចំនួន៦០នាក់ និងគិលានុបដ្ឋយិកាចំនួន២០០នាក់ទទួលព្យាបាលអ្នកជំងឺអាចបានដល់ទៅ៥០០នាក់ក្នុងមួយថ្ងៃ ហើយមានលោក ងួន ច័ន្ទភត្រា ជាអនុប្រធានមន្ទីរពេទ្យ ។ គួររំឭកផងដែរមន្ទីរពេទ្យកុមារអង្គរកកើតឡើងនៅឆ្នាំ១៩៩៩ ហើយបច្ចុប្បន្នមន្ទីរពេទ្យនេះមានទទួលពិនិត្យជំងឺផ្តល់សេវាសង្គ្រោះបន្ទាន់២៤ម៉ោងសេវាខាងក្រៅ វះកាត់តូចធំ និងបេះដូងធ្មេញ និងជំងឺធ្មេញ អេដស៍ និងការអប់រំ តាមសហគមន៍ ក៏ដូចជាតាមផ្ទះ។ សេវាទាំងអស់នេះផ្តល់ដល់កុមារដែលទើបកើតរហូតដល់អាយុ១៦ឆ្នាំ ដោយឥតគិតថ្លៃ និងផ្តល់ដល់កុមារទូទៅមិនចំពោះ ៕

**www: angkorhospital.org**


# ក្រុមហ៊ុនធានារ៉ាប់រងដែលបាន បំរើសង្គម២២ឆ្នាំហើយ

## CONWAY INSURANCE



For over 23 years, **Conway Insurance Agency** has been your community's one-stop provider of quality insurance services in New England.
We are a **full-service agency** offering:

- Personal Insurance
  - Autos
  - Homes
  - Apartments
  - Jewelry
  - Fine arts
  - Collectibles
- Business Insurance
  - Property
  - Liability
  - Professional Liability
  - Worker's compensation
  - Bonds
  - Auto, Garage keepers.
  - Disability and life insurance (individual and group products)
  - Other specialty programs

ក្រុមហ៊ុនធានារ៉ាប់រង ផ្ទះ រថយន្ត មុខរបរ និងសុខភាព

**យើងនិយាយភាសាខ្មែរ**

CONWAY INSURANCE AGENCY

P.O. Box 1744
77 E. Merrimack Street
Lowell, MA 01853
Tel: 978-454-5054
Fax: 978-453-2480

**www.ConwayInsurance.com**

សូមសួររក Philip Muth, Philip@ConwayInsurance.com



# MARCOTTE LAW FIRM

## ក្រុមហ៊ុនមេធាវី Marcotte

45 MERRIMACK STREET
LOWELL, MASSACHUSETTS
(978) 458-1229

- សេចក្តីអន្តរាយដល់បុគ្គល
- សំណងបុគ្គល
- ពិការភាពដោយសន្តិសុខសង្គម
- បទព្រហ្មទណ្ឌផ្លូវភេទ និងថ្នាំញៀន
- ច្បាប់គ្រួសារ និងផែនការអចលនទ្រព្យ
- បណ្តឹងវិវាទទូទៅ
- ច្បាប់ធានារ៉ាប់រង
- ការរំលោភបទព្រហ្មទណ្ឌ
- គ្រោះថ្នាក់ចរាចរណ៍
- គ្រោះថ្នាក់នៅការដ្ឋាន
- បំណុលអចលទ្រព្យ
- បើកបរនៅពេលស្រវឹង និងប្រព្រឹត្តបទល្មើសពេលធ្វើចរាចរណ៍

**មានបុគ្គលិកនិយាយភាសាខ្មែរលោកអ្នកអាចហៅទូរស័ព្ទមកក្រុមហ៊ុនយើងខ្ញុំដើម្បីពិគ្រោះ**

(978) 458-1229

www.marcottelawfirm.com

# ខ្មែរអ្នកជាតិនិយម

តពីលេខមុន

លើកតម្កើងកិត្យានុភាពឱ្យស្តេចទាំងឡាយនៅឥណ្ឌូចិន, បង្កើតចលនា យុវជន និងកីឡា ដោយប្រមូលយកយុវជននៃប្រទេសទាំង៣នៅឥណ្ឌូចិនដាក់បញ្ចូលទៅក្នុងចលនាមួយឈ្មោះថា "យុវជនឥណ្ឌូចិន"ដែលគេបានអប់រំបំផុតគំនិតជាអ្នកជាតិនិយមដល់យុវជនទាំងនោះ ដើម្បីបញ្ចៀសពីការទាក់ទាញរបស់ជប៉ុន ។

ប៉ុន្តែ ដឺគូ ពុំបានគិតថា ខ្លួនគាត់កំពុងសំលៀងកាំបិតមុខពីរដោយមិនដឹងខ្លួន ព្រោះនៅកម្ពុជាក្នុងគ្រាដែលលោក សឺន ង៉ុកថាន់ បានធ្វើរដ្ឋប្រហាររំលំរដ្ឋាភិបាល អ៊ឹង អ៊ី ដែលជារណបបារាំងនោះ លោកបានជ្រើសរើសយកពួកអ្នកស្ម័គ្រចិត្តនៅក្នុងចំណោមចលនាយុវជនឥណ្ឌូចិននេះឱ្យធ្វើជាអ្នកដៃដល់រួចទៅហើយ ។ ចំណែកឯនៅប្រទេសយួនវិញ វេជ្ជបណ្ឌិត ថាំ ង៉ុកថាច់ មេចលនាយុវជនឥណ្ឌូចិននេះ ជាសមាជិកសម្ងាត់នៃគណបក្សកុម្មុយនីស្តឥណ្ឌូចិនបានផ្លាស់ឈ្មោះ ចលនានេះឱ្យទៅជា "យុវជនជួរមុខ"ទៅវិញ ។ ពួកយុវជនជួរមុខនេះហើយ ដែលជាក្របខណ្ឌនៃគណបក្សកុម្មុយនីស្តឥណ្ឌូចិនក្នុងសម័យនោះ ។

ទី២-ដឺគូ បានបង្កើតសភាសហព័ន្ធឥណ្ឌូចិនមួយដែលមានយួន៣០នាក់ និងបារាំង២៣នាក់ជាសមាជិក ឯខ្មែរ និងលាវឥតមានសមាជិកនៅក្នុងសហព័ន្ធនោះទេ ។ ប៉ុន្តែនៅប្រទេសខ្មែររ៉េស៊ីដង់ត៍ស៊ុបប៉េរីយើរបារាំង គូជេ នៅតែបង្ខិតបង្ខំតែទម្រង់យ៉ាងតឹងរឹងបំផុត ដែលផ្ទុយពីគំនិតសហព័ន្ធរបស់ដឺគូ ។ មានព្រះរាជបញ្ញត្តិមួយចុះ ថ្ងៃទី១៣ ខែសីហា ១៩៤៣ បង្គាប់ឱ្យឱ្យប្រើអក្សររ៉ូម៉ាំងដើម្បីសរសេរជាអក្សរខ្មែរ ដូចអក្សរយួន ។ រាជបញ្ញត្តិមួយទៀតចុះថ្ងៃទី១៧ ខែកក្កដា ១៩៤៤ បង្គាប់ឱ្យប្រើជាផ្លូវការនូវប្រតិទិនបារាំងក្នុងគោលបំណងចង់បំបាត់បុណ្យចូលឆ្នាំខ្មែរតាមប្រពៃណីពីបុរាណ ។

ទី៣- ដឺគូ ប្រុងប្រៀបជើងព្រួលទុកជាមុនបើកាលណាបណ្តាជនឥណ្ឌូចិនបះបោរ គាត់នឹងលើកបន្ទុបប្រគល់រាជបល្ល័ង្កនៃប្រទេសទាំង៣ឱ្យទៅស្តេចណាដែលគាត់ស្រណុកក្តាប់ក្តោប និងងាយញាក់បត់បែន ។ នៅកម្ពុជាក្រោយពីពេលដែលព្រះបាទស៊ីសុវត្ថិ មុនីវង្ស ចូលទិវង្គត់ទៅនៅថ្ងៃទី២៣ មេសា ១៩៤១ ដឺគូ បានជ្រើសរើសយកទ្រង់នរោត្តម សីហនុ ព្រះជន្ម១៨ឆ្នាំ ដែលកំពុងសិក្សាឯវិទ្យាល័យបារាំងសាស៊្សិលូឡូបា នាក្រុងព្រៃនគរ ឱ្យគ្រងរាជសម្បត្តិ ។ ថ្ងៃទី២៣ តុលា ១៩៤១ នៅក្នុងពិធីរាជាភិសេកដ៏អឺកកធឹកមួយ ដឺគូ បានបំពាក់មកុដរាជ្យថ្វាយទ្រង់នរោត្តមសីហនុ ជាព្រះចៅក្រុងកម្ពុជាដែលស្របនឹងគោលបំណងរបស់ក្រុម សឺន ង៉ុកថាន់ ។

សម្តេច សីហនុ កាលនៅវ័យក្មេងទ្រង់សព្វព្រះទ័យតែនឹងតូរ្យតន្ត្រី, កីឡាជិះសេះផ្តោះរបង និងស្រីស្នំមេទំមេនាង ម្លោះហើយឥតមានខ្វល់ពីរឿងនយោបាយប្រទេសជាតិឡើយ ។ ដូច្នេះកិច្ចការស្រុកទេសទាំងអស់ត្រូវស្ថិតនៅក្រោមកិច្ចដឹកនាំរបស់ព្រះរាជមាតាបិតារបស់ព្រះអង្គដែលជារាជានុសិទ្ធិ មានក្រុមអ្នកជាតិនិយមនៅពីក្រោយជួយបំពេញភារកិច្ចជំនួសមានន័យថា នរោត្តម សីហនុ ជាអ្នកសោយរាជ្យឯក្រុម សឺន ង៉ុកថាន់ ជាអ្នកចាត់ចែងកិច្ចការប្រទេសទាំងស្រុក ។ នៅក្នុងសៀវភៅរបស់សម្តេចសីហនុ ឈ្មោះ "ឥណ្ឌូចិនឃើញពីប៉េកាំង" ទ្រង់បានរៀបរាប់ដូចតទៅ :



ចិត្រដោយ ឡឹក សំអឿន ហៅ "ផ្កាយព្រឹក"

"មុនដំបូងពួកថាន់និយមរីករាយ ដោយឃើញថា រាជបល្ល័ង្កបានមកស្តេចក្មេងដែលខ្លួនគេអាចនឹងអប់រំដឹកនាំទៅកាន់ការតស៊ូ ហើយជារាជវង្សនរោត្តម និងស៊ីសុវត្ថិ ។ ពួកនេះនឹងបាត់ញញឹមយ៉ាងឆាប់រហ័ស ហើយរូបខ្ញុំក៏ដូចគ្នាដែរ ។ ព្រោះពេលដែល គូវជ មកធ្វើជារ៉េស៊ីដង់ត៍ស៊ុបប៉េរីយើរនៅប្រទេសកម្ពុជាយើងក៏បានឃើញនូវអ្វីៗជារបបរបស់ប៉េកាំង គឺរាល់ថ្ងៃអាទិត្យនៅកីឡាស្ថានទស្សនិកជនជនជាតិខ្មែរត្រូវក្រោឈរច្រៀងបទ"សេនាប្រមុខយើងមកដល់ហើយ" មុនពេលប្រកួតបាល់ទាត់ខ្ញុំពិបាកច្រៀងណាស់ ប៉ុន្តែខ្ញុំក៏ត្រូវតែក្រោកឈរទន្ទឹមជើងដូចគេឯងដែរ" ។

នៅពេលដែលឯកឧត្តមនាវី ដឺគូ កំពុងដោះស្រាយបញ្ហានៅឥណ្ឌូចិនក្នុងពេលដែលនៅលើកទង់ជ័យជាតិបារាំងនៅឡើយនោះឧត្តមសេនីយ៍ ដឺហ្គោល (De Gaulle) កំពុងនៅជាមួយពួកអារ៉ាប់កណ្តាលវាលខ្សាច់សាហារា ។ ក្រោយពីបានបង្កើតកងកម្លាំងបារាំងសេរីបានប្រហែល១ខែប៉ុណ្ណោះ ដឺហ្គោល ក៏បង្កើតសភាការពារអាណាចក្រមួយថែមទៀត ។ តាមគំនិតលោភលន់របស់ ដឺហ្គោល ការរំដោះប្រទេសបារាំងចេញពីកណ្តាប់ដៃណាស៊ីអាល្លឺម៉ង់ដ៏ ត្រូវធ្វើជាមួយគ្នានឹងការប្រុងប្រៀបកសាងឡើងវិញនូវអាណាចក្រអាណានិគមនិយមបារាំង ដែលបានរលំរលាយខ្ទាត់ខ្ទាយទៅដោយសារតែការរលំរលាយនៃសាធារណរដ្ឋ ទី៣របស់បារាំង ។ ថ្ងៃទី ២២ កុម្ភៈ ១៩៤១ សភាការពារអាណាចក្របារាំងបានចេញសេចក្តីប្រកាស ទី១របស់ខ្លួនថា ខ្លួននឹងមិនទទួលស្គាល់ការបោះបង់ចោលទឹកដីអាណានិគមបារាំងណាមួយឡើយ ជាពិសេសគឺឥណ្ឌូចិនបារាំង ។ នៅខែមិថុនាឆ្នាំ១៩៤៣ គណៈកម្មាការរំដោះជាតិបារាំងបានត្រូវប្រកាសឡើងនៅឯក្រុងអាល់ហ្សេរ (Alger) ប្រទេសអាល់ហ្សេរី (Algerie) ។

ដឺហ្គោល អាក់អន់ស្រពន់ចិត្តយ៉ាងខ្លាំង ចំពោះអង់គ្លេស និងស.រ.អាជាសម្ព័ន្ធមិត្តដែលបានធ្វើការចរចាជាមួយ ដាឡង់ និងឧត្តមសេនីយ៍ ហ្សិរ្វ តំណាងរដ្ឋាភិបាល ហ៊្វិហ្ស៊ិ ក្នុងករណីដែលត្រូវដាក់កងទ័ពលើទឹកដីអាណាចក្របារាំងនៅអាល់ ហ្សេរិ និងម៉ាដាហ្គាស្ការ (Madagascar) ចំពេលដែលកងកម្លាំងបារាំងសេរីទទួលបរាជ័យក្នុងពេលឡើងគោកនៅប្រទេសស៊ីរី ។ ដឺហ្គោល បានដឹងយ៉ាងច្បាស់ថា ប្រធានាធិបតីសហរដ្ឋអាមេរិក Frankli Roosevelt មិនពេញចិត្តទាល់តែសោះចំពោះគំនិតអាណានិគមនិយមខ្លួនឯង ដើម្បីរក្សាអធិបតេយ្យរបស់ខ្លួននៅឥណ្ឌូចិន ។ នៅខែសីហា ឆ្នាំ១៩៤៤ សន្និសីទពួកសម្ព័ន្ធមិត្តបានបើកសម័យប្រជុំមួយនៅក្រុងកេបិក (Quebec) ប្រទេសកាណាដា បានសម្រេចចិត្តបើកឆាកប្រយុទ្ធមួយទៀត ក្រោមកិច្ចបញ្ជាការនៃឧត្តមនាវីអង់គ្លេសម្នាក់ឈ្មោះ ម៉ោន សន្និន ។ ទីបញ្ជាការនេះឈ្មោះ "ទីបញ្ជាការអាស៊ីភាគអគ្នេយ៍"ដែលមានបេសកម្មធ្វើវិទ្ធង្សនាសឹកនៅគ្រប់ទីកន្លែងដែលជប៉ុនកាន់កាប់រួមទាំងឥណ្ឌូចិនផង ។ នៅពេលនោះ ហើយដែលគណៈកម្មការរំដោះជាតិបារាំងបានខំប្រឹងប្រែងឱ្យគេបញ្ចូលកងឯកភាពរបស់ខ្លួនទៅក្នុងកងបញ្ជាការអាស៊ីភាគអគ្នេយ៍របស់ ម៉ោន មន្និន ដើម្បីឱ្យបារាំងមានឱកាសធ្វើសកម្មភាពផ្សេងៗនៅឥណ្ឌូចិន ហើយក៏បានតែងតាំងវរសេនីយ៍ត្រី ដឺឡង់ក្លាដ (ដែលក្រោយមកជាឧត្តមសេនីយ៍ត្រួតកងទ័ពជើងគោកនៅប្រទេសខ្មែរ) ឱ្យជានាយកទាហានទាក់ទងរវាងកងកម្លាំងនៅស្រុកចិន និងឥណ្ឌូចិន ។

ឧត្តមសេនីយ៍ ម៉ោន មន្និន ដែលមានទីបញ្ជាការនៅកោះសេរីលង្កា ក៏បានយល់ព្រមទទួលយកកងកម្លាំងបារាំងឱ្យចូលរួម ។ នៅពេលនោះឯង ដឺហ្គោល បានបញ្ជាទៅដឺឡង់ក្លាដ ឱ្យបង្កើតក្រុមសម្ងាត់មួយដែលជ្រើសរើសយកទាហានបារាំងណាដែលស្គាល់ភូមិប្រទេសឥណ្ឌូចិនច្បាស់លាស់ឱ្យចូលទៅរៀបចំកងកម្លាំងទ័ពព្រៃដោយសម្ងាត់ ដើម្បីបំផ្លិចបំផ្លាញកងកម្លាំងជប៉ុន ។ ជាមួយគ្នានេះ ដឺហ្គោលបានបញ្ជាឱ្យរៀបចំកងកម្លាំងមួយកងពលធំ ដើម្បីបញ្ជូនទៅចុងបូព៌ាប្រទេសក្រោមកិច្ចបញ្ជាការនៃឧត្តមសេនីយ៍ ម៉ោន មន្និន តែត្រូវសហរដ្ឋអាមេរិក និងអង់គ្លេសជំទាស់ដោយយកលេសថា ឥណ្ឌូចិនកំពុងស្ថិតនៅក្នុងឆាកប្រយុទ្ធរបស់ប្រទេសចិននៃឧត្តមសេនីយ៍ ជាងកៃឆិក (Chiang Kai-shek) ។

ឯបេសកកម្មក្រុមសម្ងាត់របស់បារាំង មានឧបសគ្គច្រើនណាស់ គឺ: ទី១ ដឺគូ មិនចូលចិត្តពួកដឺហ្គោល, ទី២ ដឺគូ យល់ថា សកម្មភាពណាដែលជម្រុញឱ្យជប៉ុនបញ្ឈប់អធិបតេយ្យបារាំងនៅឥណ្ឌូចិនមិនត្រូវអនុវត្តឡើយ ត្រូវតែទុកស្ថានការណ៍ឥណ្ឌូចិនឱ្យនៅដដែល ។ ប៉ុន្តែមេទ័ពបារាំងនៅតុងកឹងឧត្តមសេនីយ៍ ម័រដង់ (Mordan) បានត្រូវគេខ្សឹបឱ្យដឹងនូវបេសកកម្មសម្ងាត់នៅលើទឹកដីរបស់ខ្លួន ក៏យល់ថា ពេលវេលាមកដល់ហើយ គាត់ត្រូវតែចូលរួមជាមួយដឺហ្គោល ។ ម័រដង់ក៏ប្រញាប់បញ្ជូនសារសម្ងាត់ហើយសុំបញ្ជាផ្ទាល់ពីដឺហ្គោល ។ នៅថ្ងៃទី ៦ កក្កដា ១៩៤៤ គឺ ១ខែ ក្រោយដែលកងសម្ព័ន្ធមិត្តបានឡើងគោកនៅន័រម៉ង់ឌី (Normandie) ប្រទេសបារាំង ដឺឡង់ក្លាដ បានលោតឆ័ត្រយោងនៅតុងកឹង ហើយបានជួបម័រដង់ និងភូឈួយរបស់គាត់ គឺឧត្តមសេនីយ៍ អេមៃ នៅហាយហ្វុយ ។ រឿងនេះ ដឺគូពុំបានដឹងទេ ។ បន្ទាប់ពីបានឃើញស្ថានការណ៍ផ្សេងៗនៃការតស៊ូទល់នឹងជប៉ុនមកម័រដង់ និងអេមៃ ក៏សុខចិត្តចូលនៃគ្នា ។

ថ្ងៃទី ២៥ សីហា ១៩៤៤ ដឺហ្គោល ដែលជានាយករដ្ឋាភិបាលបារាំងបណ្តោះអាសន្នបានធ្វើព្យុហយាត្រាដើរចូលក្រុងប៉ារីស តាមដានជើងកងទ័ពសម្ព័ន្ធមិត្ត គឺសហរដ្ឋអាមេរិក និងអង់គ្លេស ជាដំណើរចូលស្រុកដែលជាប់ក្នុងប្រវត្តិសាស្ត្របារាំងរហូត ។ ថ្ងៃទី១២ កញ្ញា ១៩៤៤ ឧត្តមសេនីយ៍ មៃ ដង់ ដែលបានចូលនិវត្តន៍តាំងពីខែកក្កដា ហើយដែលត្រូវបានឧត្តមសេនីយ៍ អេមៃ ជំនួសនោះ បានត្រូវរដ្ឋាភិបាលបណ្តោះអាសន្នរបស់ ដឺហ្គោល តែងតាំងដោយសម្ងាត់ជាអគ្គប្រតិភូនៃរដ្ឋាភិបាលប្រចាំឥណ្ឌូចិនដែលមានរដ្ឋមន្ត្រីក្រសួងអាណានិគមនិយមបារាំង រីណេ ប្ល៉េវែន ជាមេដឹកនាំ ។ រហូតដល់ថ្ងៃទី២៤ តុលា ១៩៤៤ ទើបរដ្ឋាភិបាលបណ្តោះអាសន្នបារាំងបានត្រូវគេទទួលស្គាល់ពីសម្ព័ន្ធមិត្ត គឺអង់គ្លេស,ស.រ.អា, កាណាដា និងរុស្ស៊ី ។ មួយអាទិត្យតមកទៀត ទើបឧត្តមសេនីយ៍ អេមៃ ឱ្យ ដឺគូ ដឹងពីរឿងម័រដង់ត៏តូចចិត្តខ្លាំង ព្រោះ ដឺគូ មិនព្រមនៅក្រោមបញ្ជាការរបស់ ម័រដង់ ។ ដឺគូ ច្រឡោតគោតតូងរួចក៏វាយទូរលេខទៅរដ្ឋាភិបាលបណ្តោះអាសន្នលាឈប់ពីតំណែង ។ ប៉ុន្តែបន្ទាប់ពីបានជួបគ្នា២លើកជាមួយដឺឡង់ក្លាដ មក ដឺគូ ក៏សុខចិត្តនៅជាអគ្គទេសាភិបាលឥណ្ឌូចិនដដែលតែអំណាចទាំងអស់ទាំងទាហានទាំង ស៊ីវិល ត្រូវ ម័រដង់ កាន់កាប់ដើម្បីកុំឱ្យជប៉ុនសង្ស័យ ។

ចាប់តាំងពីខែតុលា ឆ្នាំ១៩៤៤ មកអាកាសយាននៃកងទ័ពអាកាសអង់គ្លេសបានទម្លាក់មនុស្ស និងអាវុធតាមឆ័ត្រយោងនៅប្រទេសលាវ,យួន និងកម្ពុជា ។ មេតស៊ូ និងពលទាហានបារាំងប្រមាណ៥០នាក់ដែលបានលោតឆ័ត្រយោងនៅប្រទេសខ្មែរ ក៏បានត្រូវជប៉ុនចាប់បានទាំងអស់ ហើយយកទៅដាក់គុកនៅក្រោយវត្តឧណ្ណាលោម ក្រុងភ្នំពេញ ។

តទៅលេខក្រោយ


CAMBODIA
PHONE CARD
Veth Ratana
មិនកាត់នាទី និងមិនផុតកំណត់
សម្លេងឮច្បាស់ល្អទូរស័ព្ទទៅស្រុកខ្មែរ
To Call CAMBODIA!
5.3¢ per minute
Buy
Minutes
+10%
$2.00
~~37~~
41
$5.00
~~94~~
103
$10.00
~~188~~
207
Buy today and get 10% more!
Tel: (978) 942 1641/ (978) 656 8141
(267) 253 3947
www.cambodiaphonecard.us



# ទៅកម្សាន្តនៅឧទ្យានជាតិគីរីរម្យ







ឧទ្យានជាតិគីរីរម្យត្រូវបានបង្កើតជារមណីយដ្ឋានសម្រាប់ការលំហែកម្សាន្តនៅថ្ងៃឈប់សម្រាកនានា និងជាទីក្រុងទេសចរណ៍ដ៏មានប្រជាប្រិយភាពមួយ ។ រមណីដ្ឋាននេះត្រូវបានដាក់ឈ្មោះថា "គីរីរម្យ" ដែលមានន័យថា "ភ្នំដ៏រីករាយ" ដោយស្នាព្រះហស្តរបស់ព្រះមហាក្សត្រតាមការស្នើសុំរបស់ព្រះសង្ឃពីទីក្រុងភ្នំពេញ។ ភ្នំគីរីរម្យដែលមានកម្ពស់៧០០ម៉ែត្រគ្របដណ្តប់ផ្ទៃដីចំនួន៣៥.០០០ហិកតា។ គីរីរម្យមានទីតាំងស្ថិតនៅក្នុងស្រុកភ្នំស្រួចខេត្តកំពង់ស្ពឺ និងមានចម្ងាយប្រមាណ១២០គីឡូម៉ែត្រភាគនិរតីទីក្រុងភ្នំពេញ ។ គេអាចធ្វើដំណើរទៅដល់ទីនោះតាមផ្លូវជាតិលេខ៤ ។ រមណីយដ្ឋានធម្មជាតិដ៏ស្រស់ត្រកាលនេះ ជាទីស្ថានដ៏សប្បាយរីករាយសម្រាប់អ្នកទេសចរមកពីគ្រប់ទិសទី ព្រោះមានទឹកជ្រោះល្អាងទឹកក្តៅកន្លែងសម្រាប់ស្រូបយកខ្យល់អាកាសត្រជាក់បរិសុទ្ធ និងដើមស្រល់ជាច្រើនដែលដុះនៅទីនោះ។

រមណីយដ្ឋានឧទ្យានជាតិគីរីរម្យចែកចេញជាពីរផ្នែក គឺខាងលើ និងខាងក្រោម។ នៅផ្នែកខាងលើយើងអាចទស្សនាទេសភាពព្រៃប្រឹក្សា និងស្រូបយកខ្យល់អាកាសធម្មជាតិ ព្រមទាំងលេងកម្សាន្តជាមួយនឹងទឹកជ្រោះផងដែរ។ ចំណែកឯផ្នែកខាងក្រោមយើងអាចចូលទស្សនាដោយគ្រាន់តែទិញសំបុត្រក្នុងតម្លៃថោកសមរម្យ ហើយគយគន់ជាមួយឧទ្យានកែច្នៃដែលក្នុងនោះមានទេសភាពស្រស់បំព្រងជាមួយនឹងការតុបតែងដ៏ស្រស់ស្អាតអាចជាទីចាប់អារម្មណ៍ក្នុងការថតរូបទុកជាអនុស្សាវរីយ៍។ លើសពីនេះនៅទៀតមានកន្លែងសំរាប់ស្នាក់នៅ កន្លែងហាត់ប្រាណកញ្ចុះសំរាប់ទទួលទានអាហារមានកង់សំរាប់ជិះលេងកម្សាន្ត Mini Mart ជាដើម ៕





